ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- កម្ពុជាត្រូវការវិទ្យាស្ថាន-សារមន្ទីរស្តីអំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មួយ
- មជ្ឈមណ្ឌលឯកសារ ខេត្តព្រៃវែង ចុះពិគ្រោះនិងពិនិត្យសុខភាពជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅខេត្តព្រៃវែង និងខេត្តស្វាយរៀង

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៩០ ខែកុម្ភៈ ឆ្នាំ២០២៤

# ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា



ប្លង់វិទ្យាស្ថានស្លឹករឹតនៃមជ្ឈមណ្ឌលឯកសារកម្ពុជា
គូរដោយស្ថាបត្យករ ហ្សាហា ហាឌីដ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## មាតិកា

### សំបុត្រ

◆ កម្ពុជាត្រូវការវិទ្យាស្ថាន- សារមន្ទីរស្តីអំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មួយ៖ ........................ ១

### ផ្នែកឯកសារ

◆ ផន រ៉ាន់ឌី៖ អនុក្រុមរោងចក្រអារឈើ ......... ៦

### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ

◆ «មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងរៀបចំដំណើរទស្សនកិច្ចសិក្សាស្តីអំពី «សន្តិភាព និង....... ១០
◆ សិស្សមកពីវិទ្យាល័យ សម្តេច ហ៊ុន សែន ស្គន់ ចូលរួមវេទិកាអន្តរជំនាន់ស្តីពី «ប្រវត្តិសាស្ត្រ... ១៨
◆ សិស្សថ្នាក់ទី១២ មកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ស្ពឺ ចូលរួមវេទិកាអប់រំសហគមន៍...... ១៩
◆ ខៃ កាន៖ ប្រជាជនក្នុងភូមិចង្អូប ............. ២៥
◆ គីម ហឿន ជនជាតិដើមភាគតិចមិល .........២៧
◆ ផែ ខេន៖ ប្រធានកងតូចនៅភូមិជ្រៃ .........២៩
◆ ជួប ធៀង៖ នារីពេទ្យឃុំ .......................៣១
◆ តឿ ឃ្លឹម៖ ជនជាតិដើមភាគតិចមិល......... ៣២
◆ ឃឹម សាវ៖ អតីតកងទ័ពខ្មែរក្រហម......... ៣៣
◆ រ៉ាន់ ចូវ៖ ប្រធានកងចល័តនៅឃុំត្រមូង..... ៣៥
◆ រ៉ាន់ ឆឹង៖ អតីតពេទ្យ ប៣ តំបន់២១......... ៣៧
◆ ហ៊ុន យ៉ូច៖ អតីតអ្នកដាំបាយនៅពេទ្យ........ ៤០

### ផ្នែកវេទិកាពិភាក្សាសាធារណៈ

◆ មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង រៀបចំវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីអំពីរបបកម្ពុជា ....... ៤២
◆ សិស្សវិទ្យាល័យប៊ុនរ៉ានី ហ៊ុនសែន ដារ ចូលរួមវេទិកាថ្នាក់រៀនស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជា .. ៤៦
◆ សិស្សវិទ្យាល័យតេជោសែន សំរោង ចូលរួមវេទិកាថ្នាក់រៀនស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជា .. ៥១
◆ មជ្ឈមណ្ឌលឯកសារ ខេត្តព្រៃវែង ចុះពិគ្រោះនិងពិនិត្យសុខភាពជូនអ្នករស់រានមានជីវិតពី.... ៥៤

### ផ្នែកស្រាវជ្រាវរកគ្រួសារ

◆ ជីវិតកូនប្រុសពុកក្នុងគុកខ្មែរក្រហម (ត) ... ៥៩

**រក្សាសិទ្ធិ**
មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧៥ព.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្នេរលេខនេះ៖** ម៉ៃឃើល ជី. ខាណារ៉ាស, មីន សាណាស់, មេក វិន, ទូច វណ្ណេត, សាំង ចាន់ធូ, លី ដេវីត, សាន្ត គឹមស៊ីន, ជិន សុខណេង, ឈុំ រ៉ា, ឡាំ ស្រីនីត, វង្ស ស្រីឃីម, ចាន់ណារិទ្ធ, វី ស៊ីថា, ផេង ពង្សរ៉ាស៊ី, ឡុង ដានី, សួត វិចិត្រ និង ហង្ស ឆាំឆាន
**អ្នកនិពន្ធ និងស្រាវជ្រាវ៖** មីន សាណាស់ **អ្នកបកប្រែ៖** លឹម អ៊ិកឹង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន
**ជំនួយការនិពន្ធនាយក៖** ដារ៉ារដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង រ៉េង
Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiasri.org

# កម្ពុជាត្រូវការវិទ្យាស្ថាន-សារមន្ទីរស្តីអំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មួយ៖

## ការបង្កើតវិទ្យាស្ថានស្លឹករឹតនឹងបំពេញនូវតម្រូវការនេះ ព្រមទាំងផ្តល់អត្ថប្រយោជន៍ជាច្រើនផ្សេងទៀត

*ម៉ែរឃើល ឌី. ខាណាទ៉ាស*



*ប្លង់វិទ្យាស្ថានស្លឹករឹតនៃមជ្ឈមណ្ឌលឯកសារកម្ពុជា គូរដោយស្ថាបត្យករ ហ្សាហា ហាឌីដ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ឆ្នាំក្រោយ គឺជាខួបលើកទី៥០ នៃការកាន់កាប់ទីក្រុងភ្នំពេញរបស់កងកម្លាំងខ្មែរក្រហម ដែលរុញច្រានប្រទេសកម្ពុជាឲ្យធ្លាក់ទៅក្នុងនរកនារយៈកាលជិតបួនឆ្នាំបន្ទាប់មក។ ការដឹកនាំរបស់ខ្មែរក្រហមបាននាំកម្ពុជាឈានទៅកាន់ទំព័រប្រវត្តិសាស្ត្រឃោរឃៅដ៏សោកសង្រេង។ យើងអាចនឹងមិនដែលដឹងច្បាស់អំពីចំនួនជាក់លាក់នៃប្រជាជនកម្ពុជាដែលបានបាត់បង់ជីវិត ប៉ុន្តែបើគ្រាន់តែក្រឡេកមើលទៅកាន់ចំនួនប៉ាន់ប្រមាណ ចំនួនប្រជាជនដែលបាត់បង់ជីវិត គឺច្រើនលើសលប់ណាស់ទៅហើយ។ ជាទូទៅ ប្រជាជនកម្ពុជាទាំងអស់ ដែលរួមបញ្ចូលទាំងអតីតកម្មាភិបាលខ្មែរក្រហម គឺសុទ្ធសឹងតែជាជនរងគ្រោះនៃរបបខ្មែរក្រហម។ ខុសប្លែកពីឧក្រិដ្ឋកម្មឃោរឃៅដទៃទៀតដែលប្រព្រឹត្តទៅនៅជុំវិញពិភពលោក ការបាត់បង់ជីវិតរបស់ប្រជាជនកម្ពុជានៅក្នុងរបបខ្មែរក្រហម គឺមិនមែនដោយសារតែការ



ប្លង់វិទ្យាស្ថានស្លឹករឹតនៃមជ្ឈមណ្ឌលឯកសារកម្ពុជា គូរដោយស្ថាបត្យករ ហ្សាហា ហាឌីដ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

សម្លាប់រង្គាលទាំងអស់នោះទេ។ ទោះបីជាយ៉ាងណាក្តី ខណៈដែលព្រឹត្តិការណ៍ឃោរឃៅនានាកើតមានឡើងរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានចាត់ថ្នាក់ថាជារបបដ៏ព្រៃផ្សៃ និងបង្កជាការស្លាប់ក៏ដូចជាបន្សល់ទុកវិនាសកម្មលើជនរងគ្រោះច្រើនបផុតមួយក្នុងចំណោមព្រឹត្តិការណ៍ឃោរឃៅនានាក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ។

កេរដំណែលបន្សល់ដោយរបបប្រល័យពូជសាសន៍ ប៉ុល ពត គឺមិនមែនកើតមានតែចំពោះប្រជាជនកម្ពុជាតែប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងជះឥទ្ធិពលលើមនុស្សជាតិទៀតផង។ គួរឲ្យសោកស្តាយបន្ទាប់ពីរយៈកាលជាងប្រាំទសវត្សរ៍កន្លងមក ប្រទេសកម្ពុជា ពុំទាន់មាន «វិទ្យាស្ថាន-សារមន្ទីរ» សមស្របមួយ ដើម្បីរំឭកដល់ជនរងគ្រោះ ដូចទៅនឹងទីតាំងរំឭកសម្រាប់ជនរងគ្រោះហូឡូខសត៍ (ការសម្លាប់រង្គាលនៅអឺរ៉ុប), អំពើប្រល័យពូជសាសន៍លើជនជាតិអាមេនី, បូជនីយដ្ឋានរំឭកហូឡូដូម័រ សម្រាប់ជនរងគ្រោះពីអំពើប្រល័យពូជសាសន៍លើជនជាតិអ៊ុយក្រែន និងអំពើប្រល័យពូជសាសន៍រ៉្វាន់ដាជាដើម។

ពិចារណាទៅលើព្រឹត្តិការណ៍ដែលកើតមាននៅក្នុងអំឡុងកាលដ៏ខ្មៅងងឹតនៃប្រវត្តិសាស្ត្រកម្ពុជា កម្ពុជាគួរបង្កើតជាទីតាំងប្រកបដោយសោភ័ណភាពតាមបែបបទស្ថាបត្យកម្មដែលទទួលស្គាល់ជាផ្លូវការមួយ។ ទីតាំងនេះ មិនមែនត្រឹមតែមានតួនាទីជាបូជនីយដ្ឋានរំឭកអំពីអតីតកាលតែប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងបម្រើតួនាទីជាសារមន្ទីរមួយ ដូចទៅនឹងសារមន្ទីរដទៃទៀត ដែលតាំងបង្ហាញនូវរូបថត និងវត្ថុតាងនានា។ ប្រទេសកម្ពុជា, ជនរងគ្រោះ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម, កូនចៅជំនាន់ក្រោយរបស់គេ ក៏ដូចជាមនុស្សជាតិ ត្រូវការ «វិទ្យាស្ថាន-សារមន្ទីរ» មួយ ដែលផ្តល់ជាព័ត៌មាន, ជំរុញលើកទឹកចិត្ត និងធ្វើអន្តរកម្មជាមួយនឹងអ្នកទស្សនា និងអ្នកសិក្សាស្រាវជ្រាវនៅទូទាំងសកលលោក។

ទីតាំងនេះ នឹងផ្តល់ជាការពិពណ៌នាអំពីព្រឹត្តិ-



ប្លង់វិទ្យាស្ថានស្លឹករឹតនៃមជ្ឈមណ្ឌលឯកសារកម្ពុជា គូរដោយស្ថាបត្យករ ហ្សាហា ហាឌីដ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ការណ៍ប្រវត្តិសាស្ត្រ ដូចជា តើខ្មែរក្រហមឡើងកាន់អំណាចដោយរបៀបណា? តើរបបកម្ពុជាប្រជាធិប-តេយ្យអនុវត្ត គោលនយោបាយបំផ្លិចបំផ្លាញសង្គមយ៉ាងខ្ទេចខ្ទាំ, បន្សុទ្ធកម្ម, ជម្លោះជាមួយនឹងប្រទេសជិតខាង, អំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិចាម និងជនជាតិវៀតណាម និងការធ្វើទុក្ខបុកម្នេញលើបញ្ញវន្តយ៉ាងដូចម្តេច? ការដួលរលំនៃរបបខ្មែរក្រហម និងចលនាតស៊ូជាច្រើនឆ្នាំក្រោយរបបនេះដួលរលំ រហូតដល់មានវត្តមាននៃសន្ធិសញ្ញាទីក្រុងប៉ារីស និងនៅចុងបញ្ចប់ គឺការបង្ក្រាបចលនា និងអង្គការចាត់តាំងខ្មែរក្រហមទាំងស្រុង។ ទីតាំងនេះ ក៏នឹងបំពេញតួនាទីជាវិទ្យាស្ថានបម្រើដល់ការសិក្សាស្រាវជ្រាវ ការអប់រំ ក៏ដូចជាការរៀបចំជាសន្និសីទ, ពិព័រណ៌ និងព្រឹត្តិការណ៍វប្បធម៌នានា។ ទីតាំងនេះ គួរតែជាបណ្ណសារដ្ឋានតម្កល់នូវប្រវត្តិ-សាស្ត្រផ្ទាល់មាត់ដែរ។ បន្ថែមលើសពីនេះទៅទៀត ទីតាំងនេះ គ្រោបបញ្ចូលនូវកម្មវិធីសាធារណៈ ដែលទាក់ទាញអ្នកសិក្សាស្រាវជ្រាវជំនាញ មកផ្លាស់ប្តូរបទពិសោធន៍។ ទីតាំងនេះ នឹងប្រាស្រ័យទាក់ទងជាមួយនឹងសហគមន៍ ព្រមទាំងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ មិនតែប៉ុណ្ណោះ ទីតាំងនេះ នឹងបង្កើតទំនាក់ទំនងជាមួយនឹងវិទ្យាស្ថាន- សារមន្ទីរដទៃទៀត ក្នុងការចែករំលែកបទពិសោធន៍ និងសម្របសម្រួលដល់កិច្ចខិតខំប្រឹងប្រែងលើកកម្ពស់តម្លាភាព និងដោះស្រាយបញ្ហានិទណ្ឌភាព។

នៅក្នុងប្រទេសកម្ពុជាមានស្តូប និងបូជនីយដ្ឋានរំឭកជាច្រើននៅទូទាំងប្រទេស។ ក្នុងនោះ មានសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលកម្មាភិបាលខ្មែរក្រហមភាគច្រើនត្រូវបានធ្វើទារុណកម្មនិងសម្លាប់។ ក្នុងនាមជាបូជនីយដ្ឋានរំឭក សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង អាចផ្តល់នូវសាច់រឿងមួយចម្រៀកតូចតែប៉ុណ្ណោះ នោះគឺអ្នកទោសចំនួនប្រមាណ១៨ ០០០នាក់បានបាត់បង់ជីវិត។ ដូចគ្នានឹងនេះដែរ មជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក (ជាទូទៅ គឺជាទីតាំងដែលមានតែភ្ញៀវបរទេសចាប់អារម្មណ៍ចំពោះឧក្រិដ្ឋកម្មឃោរឃៅរបស់ខ្មែរក្រហម ទៅទស្សនាតែប៉ុណ្ណោះ) សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង បំពេញមុខងារដ៏សំខាន់ក្នុងការអភិរក្ស និងអប់រំអំពីអ្វីដែលបានកើតមានឡើងនៅទីតាំងនេះ ក៏ប៉ុន្តែ បើយើងពិចារណាអំពីស្ថានទម្ងន់នៃឧក្រិដ្ឋកម្មឃោរឃៅរបបខ្មែរក្រហម សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ពុំអាចផ្តល់ព័ត៌មានប្រកបដោយប្រសិទ្ធភាព និងបានគ្រប់គ្រាន់អំពីព្រឹត្តិការណ៍ទាំងមូល ដូចធនធានដែល «វិទ្យាស្ថាន-សារមន្ទីរ» ស្តីពីឧក្រិដ្ឋកម្មទ្រង់ទ្រាយធំនិងអំពើប្រល័យពូជសាសន៍អាចផ្តល់ជូន។

កិច្ចខិតខំប្រឹងប្រែងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ក្នុងការស្រាយបំភ្លឺអំពីឧក្រិដ្ឋកម្មឃោរឃៅដែលប្រព្រឹត្តទៅ និងនាំយកមេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហមដែលនៅរស់រានមានជីវិត មកកាត់ទោស ជំរុញឲ្យមានមតិយល់ឃើញផ្សេងៗគ្នា ពីព្រោះថាតុលាការ និងសវនាការ អាចផ្តល់ត្រឹមតែជាការពិតអំពីប្រវត្តិសាស្ត្រ

ក៏ប៉ុន្តែមិនអាចដោះស្រាយលើបញ្ហាប្រឈមនានា។ សរុបមក ដែនសមត្ថកិច្ចរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅមានកម្រិត គឺត្រឹមរយៈកាលបន្ទាប់ពីការកាន់កាប់ទីក្រុងភ្នំពេញដោយកងកម្លាំងខ្មែរក្រហមក្នុងឆ្នាំ១៩៧៥ និងនៅពេលរបបខ្មែរក្រហមដួលរលំទៅនៅក្នុងឆ្នាំ១៩៧៩ គឺជាពេលដែលខ្មែរក្រហមបានរត់ភៀសខ្លួនទៅកាន់ព្រំដែនថៃតែប៉ុណ្ណោះ។ សំណុំរឿងទាំងអស់នៅក្នុងអង្គជំនុំជម្រះត្រូវបានដាក់កំហិតឲ្យនៅក្នុងតែរយៈកាលនេះ។ ដើម្បីបណ្តឹងរដ្ឋប្បវេណី ដែលបានផ្តល់សក្ខីកម្មនៅក្នុងសវនាការ ត្រូវបានអនុញ្ញាតឲ្យចែករំលែករឿងរ៉ាវផ្ទាល់ខ្លួនតែបន្តិចបន្តួចៗ ដោយសារមានតែសំណុំរឿងបួនករណី (ហើយមានតែពីរសំណុំរឿងដែលបានឆ្លងកាត់សវនាការ) យើងមិនអាចអះអាងថា បណ្ណសារឯកសាររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចរៀបរាប់សាច់រឿងឲ្យបានពេញលេញទេ ទោះបីជាឯកសារទាំងនោះមានសារសំខាន់ក៏ពិតមែនៗ យើងក៏មិនអាចអះអាងដែរថា សំណង់ជានិមិត្តរូប សម្រេចដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលទទួលបានការសាទរ អាចផ្តល់ជាបរិក្ខារ និងទីតាំងសម្រាប់ថែរក្សាការចងចាំ និងកេរដំណែលនៃឧក្រិដ្ឋកម្មឃោរឃៅរបស់ខ្មែរក្រហមដែរ។ គួរជាទីស្ញប់ស្ញែងចំពោះការបង្កើតជាមជ្ឈមណ្ឌលធនធាន ដែលជាផ្នែកមួយនៃកេរដំណែលរបស់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីបន្តពង្រីកការផ្សព្វផ្សាយ និងអប់រំរបស់ខ្លួន។ មជ្ឈមណ្ឌលធនធាននេះ ពិតជាមានតម្លៃសម្រាប់អ្នកជំនាញ និងអ្នកសិក្សាស្រាវជ្រាវ ក៏ប៉ុន្តែ អាណត្តិ និងសមត្ថភាពនៃមជ្ឈមណ្ឌលធនធាននេះ នៅមានកម្រិតនៅឡើយ។



ប្លង់វិទ្យាស្ថានស្លឹករឹតនៃមជ្ឈមណ្ឌលឯកសារកម្ពុជា គូរដោយស្ថាបត្យករ ហ្សាហា ហាឌីដ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៥ ដោយអ្នកសិក្សាស្រាវជ្រាវមកពីសាកលវិទ្យាល័យ យ៉េល ក្រោមជំនួយឧបត្ថម្ភរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក។ ដំបូងឡើយ មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវបានបង្កើតឡើងដើម្បីប្រមែប្រមូលចងក្រងឯកសារដើម និងវត្ថុតាងដែលពាក់ព័ន្ធទៅនឹងអំឡុងសម័យកាលកម្ពុជាប្រជាធិបតេយ្យ ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ ក្រោយមក មជ្ឈមណ្ឌលឯកសារកម្ពុជា បានប្រែក្លាយខ្លួនទៅជាស្ថាប័នឯករាជ្យស្របច្បាប់មួយនៅក្នុងឆ្នាំ១៩៩៧។ មជ្ឈមណ្ឌលឯកសារកម្ពុជា បានប្រមែប្រមូលចងក្រងតម្កល់នូវឯកសារស្តីពីរបបខ្មែរក្រហមជាច្រើនលើសលប់ ក្នុងនោះរួមមាន សក្ខីកម្ម និងប្រវត្តិសាស្ត្រផ្ទាល់មាត់របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមជាដើម។ អមជាមួយនឹងកម្មវិធីផ្សព្វផ្សាយគួរជាទីស្ញើចសរសើរ ក្នុងការបញ្ជ្រាបចំណេះដឹង និងបណ្តុះបណ្តាលយុវជន-យុវនារីកម្ពុជានៅតាមមូលដ្ឋានទូទាំងប្រទេសកម្ពុជា មជ្ឈមណ្ឌលឯកសារកម្ពុជា ក៏បានរៀបចំជាសន្និសីទនិងពិព័រណ៍នានា។ កម្មវិធីសិក្សារៀបចំឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ផ្តល់ជាព័ត៌មានសព្វជ្រុងជ្រោយ និងគាំពារដល់កម្មវិធីអប់រំនៅសាលារៀនសាធារណៈ ក៏ដូចជាសកម្មភាពលើកកម្ពស់ការយល់ដឹងជាសាធារណៈនៅទូទាំងប្រទេស។ យើងអាចនិយាយដោយសាមញ្ញបានថា មជ្ឈមណ្ឌលឯកសារ

កម្ពុជា បានផ្តល់ជាសេវាកម្មជាច្រើន ដែលជាតួនាទី «វិទ្យាស្ថាន-សារមន្ទីរ»។

សមត្ថភាព និងបរិក្ខាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា នាពេលបច្ចុប្បន្ន នៅមានកម្រិតនៅឡើយ។ មជ្ឈមណ្ឌលឯកសារកម្ពុជា ក៏បានយល់ច្បាស់អំពីចំណុចនេះដែរ។ អាស្រ័យហេតុនេះ មជ្ឈមណ្ឌលឯកសារកម្ពុជា បានចំណាយរយៈពេលជាច្រើនឆ្នាំ លើគម្រោង «វិទ្យាស្ថាន-សារមន្ទីរ» ដ៏មោះមុត និងប្រកបដោយសោភ័ណភាពមួយ នោះគឺ វិទ្យាស្ថានស្លឹករឹត។ បន្ថែមពីលើមុខងារជាបណ្ណសារដ្ឋានតម្កល់ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា វិទ្យាស្ថានស្លឹករឹត នឹងរួមបញ្ចូលនូវបណ្ណាល័យ, គ្រឹះស្ថានឧត្តមសិក្សាស្តីពីអំពើប្រល័យពូជសាសន៍ និងសិទ្ធិមនុស្ស, មជ្ឈមណ្ឌលស្រាវជ្រាវ, មជ្ឈមណ្ឌលព័ត៌មាន និងសាលសហសម័យ។ វិទ្យាស្ថានស្លឹករឹត មានឆន្ទៈឈានទៅសម្រេចបានតួនាទីជា «មជ្ឈមណ្ឌលនាំមុខគេក្នុងទ្វីបអាស៊ី ដែលសិក្សាស្រាវជ្រាវប្រៀបធៀប វិភាគ និងពន្យល់បកស្រាយអំពីអំពើប្រល័យពូជសាសន៍, ជម្លោះ និងសិទ្ធិមនុស្ស» នៅក្នុងទីតាំងមួយដែល «ក្រសោបបញ្ចូលគ្នានូវការចងចាំ, ការធ្វើឲ្យជាសះស្បើយ និងការស្តារឡើងវិញនូវតម្លៃនិងសោភ័ណភាពដ៏អមតៈនៃមនុស្សជាតិនៅក្នុងទ្វីបអាស៊ី»។ ជារួម បេសកកម្មរបស់ វិទ្យាស្ថានស្លឹករឹត គឺ«បង្កើនការយល់ដឹង និងចំណេះដឹងរបស់មនុស្សជាតិទៅលើប្រធានបទនៃឧក្រិដ្ឋកម្មឃោរឃៅ និងនីតិរដ្ឋ» តាមរយៈអ្នកជំនាញ, កម្មវិធីអប់រំ, សេវាកម្ម, កម្មវិធីសិក្សាស្រាវជ្រាវ, កម្មវិធីលើកកម្ពស់ការយល់ដឹងទូទៅរបស់មនុស្ស និងឯកសារប្រវត្តិសាស្ត្រដែលអាចទាញយកបានតាមប្រព័ន្ធអនឡាញជាសាធារណៈ។

វិទ្យាស្ថានស្លឹករឹត អាចនឹងត្រូវចំណាយរយៈពេលជាច្រើនឆ្នាំមុននឹងអាចលេចចេញជារូបរាង។ ការអនុវត្តនូវគម្រោងការនេះ ទាមទារនូវការរៀបចំផែនការល្អិតល្អន់ និងធនធានហិរញ្ញវត្ថុ ក៏ដូចជាការគាំទ្រពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា និងសហគមន៍អន្តរជាតិ។ អស់រយៈកាលជាងមួយទសវត្សរ៍ទៅហើយ ចាប់តាំងពីលោក ឆាំង យុ ដែលជានាយកមជ្ឈមណ្ឌលឯកសារកម្ពុជា បានប្រកាសអំពីគម្រោងវិទ្យាស្ថានស្លឹករឹតនេះ។ លោកបានខិតខំស្វះស្វែង និងបានជំរុញទឹកចិត្តលោកស្រី ហ្សាហា ហាឌីដ ស្ថាបត្យករដ៏មហស្ចារ្យ និងឈ្នះពានរង្វាន់ជាច្រើនលើពិភពលោក ឲ្យរចនាគម្រោងនេះ ដោយមិនគិតកម្រៃ។ ជាអកុសល គម្រោងនេះ ហាក់ដូចជានៅនឹងទ្រឹង ឬមានការវិវត្តទៅមុខដូចជាជំហានសត្វខ្យង។

បញ្ហារាំងស្ទះ គឺជារឿងធម្មតា។ កិច្ចខិតខំប្រឹងប្រែងជំរុញឲ្យគម្រោងប្រភេទនេះចាប់ផ្តើមបាន កុំថាឡើយបញ្ចប់ចប់សព្វគ្រប់ គឺជាកាតព្វកិច្ចដ៏មហិមាមួយ។ អមជាមួយនឹងការគាំទ្រនិងទទួលស្គាល់ជាផ្លូវការ ព្រមទាំងទទួលហិរញ្ញប្បទានពីអ្នកឧបត្ថម្ភបរទេស ក៏ដូចជាតាំងទីនៅក្នុងទីប្រជុំជនធំមួយនៅក្នុងទីក្រុង និងងាយស្រួលសម្រាប់ការចូលទស្សនា វិទ្យាស្ថានស្លឹករឹត គឺជាសេចក្តីសង្ឃឹមដ៏ប្រពៃបំផុត សម្រាប់ «វិទ្យាស្ថាន-សារមន្ទីរ» ស្តីអំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដែលកើតមានក្នុងប្រទេសកម្ពុជា។

តើនេះគឺជាពេលវេលាសក្តិសមសម្រាប់កម្ពុជាក្នុងការរៀបចំបង្កើតជាវិទ្យាស្ថាន-សារមន្ទីរ ដែលបម្រើដល់ការចងចាំអំពីកេរដំណែលនៃរបបកម្ពុជាប្រជាធិបតេយ្យហើយឬនៅ? ចម្លើយនោះគឺ វត្តមាននៃស្ថាប័នសារមន្ទីរនេះ គឺចាំបាច់និងគួរតែកើតឡើងភ្លាមៗ។ ពេលវេលាគឺជាលក្ខខណ្ឌចាំបាច់បំផុត។ នេះគឺជាឱកាសដ៏សក្តិសមបំផុតក្នុងការបង្កើតជាវិទ្យាស្ថានស្លឹករឹតនេះឡើង ខណៈដែលមនុស្សមួយជំនាន់ដែលបានរស់រានមានជីវិតពីរបបខ្មែរក្រហមនៅមានអាយុជីវិតនៅឡើយ ហើយដែលកំពុងឃ្លាតចាកពីយើងទៅជាបន្តបន្ទាប់។ រាជរដ្ឋាភិបាលកម្ពុជា និងសម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីថ្មីនៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាសហគមន៍អន្តរជាតិ គឺជាបុគ្គលដ៏ចាំបាច់ក្នុងការគាំទ្រ និងផ្តល់ជាជំនួយដល់ការបង្កើត និងនិរន្តរភាពនៃវិទ្យាស្ថានស្លឹករឹត។

**ម៉ៃឃើល ជី. ខាណាវ៉ាស**
មេធាវីការពារក្តីព្រហ្មទណ្ឌអន្តរជាតិ
សហមេធាវីការពារក្តីរបស់ អៀង សារី និង មាស មុត

# ផន វ៉ាន់ឌី ៖ អនុក្រុមរោងចក្រអារឈើនៅកំពង់សោម

មីន សាណាស់



ក្រុមជាងកំពុងអារ និងច្រៀកឈើ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។
(ហ្គុនណា បឺយស្រ្តម/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ផនវ៉ាន់ឌី អាយុ២៩ឆ្នាំ (១៩៧៨) ជនជាតិខ្មែរ នៅលីវ មានស្រុកកំណើតនៅភូមិភ្នំធំ សង្កាត់អូរប្រាសាទ ស្រុកមង្គលបូរី ខេត្តបាត់ដំបង។ ខ្ញុំរស់នៅជាមួយឪពុកម្តាយតាំងពីតូច រហូតដល់ឆ្នាំ១៩៥៧ ទើបឪពុកម្តាយរបស់ខ្ញុំបានបញ្ជូនខ្ញុំទៅរៀននៅសាលាបឋមសិក្សាបំពេញវិជ្ជា «ភ្នំធំ» ដែលមានកម្រិតសិក្សាពីថ្នាក់ទី១២ ដល់ថ្នាក់ទី៧ (សង្គមចាស់)។ ពេលខ្ញុំរៀននៅសាលាបឋមសិក្សាបំពេញវិជ្ជាភ្នំធំ ខ្ញុំប្រឡងធ្លាក់ចំនួន២ឆ្នាំ។ នៅឆ្នាំ១៩៦៤ ខ្ញុំត្រូវឡើងមកបន្តការសិក្សានៅវិទ្យាល័យសង្កែ ជា «សាលាឯកជន» ក្នុងក្រុងបាត់ដំបង។ ខ្ញុំរៀននៅវិទ្យាល័យសង្កែបានរយៈពេលមួយឆ្នាំ ហើយដោយគ្មានប្រាក់បង់ថ្លៃសាលា ខ្ញុំក៏ត្រឡប់មកផ្ទះវិញនៅឆ្នាំ១៩៦៥។ នៅឆ្នាំ១៩៦៦ ខ្ញុំចូលធ្វើការជាកម្មករនៅមជ្ឈមណ្ឌលពិសោធន៍ពូជស្រូវមិត្តភាពខ្មែរ-ជប៉ុន «ទួលសំរោង»។ នៅកន្លែងធ្វើការ ខ្ញុំមានមិត្តភក្តិម្នាក់ឈ្មោះ អែម សារូ។ អែម សារូ គឺជាអតីតទាហានឋានន្តរស័ក្តិពលទោ បច្ចុប្បន្នគឺជាប្រជាជនថ្មីរស់នៅភូមិព្រៃទទឹង ស្រុកមង្គលបូរី តំបន់៤។ ខ្ញុំ និង អែម សារូ ធ្វើការនៅជម្មមណ្ឌលពិសោធន៍ពូជស្រូវអស់រយៈពេលមួយឆ្នាំ។

នៅចុងឆ្នាំ១៩៦៦ ជី ចាន់ អតីតភ្នាក់ងារកសិកម្ម បច្ចុប្បន្នក្ដាប់មិនបាន និង ប៉ុល អតីត កុងត្រូលកសិកម្ម បច្ចុប្បន្នក្ដាប់មិនបាន បានហៅខ្ញុំឲ្យមកជួបរួមជាមួយ អែម សារូ ម្នាក់ទៀត។ គោលបំណងគឺ ជី ចាន់ និង ប៉ុល ហៅខ្ញុំ និង អែម សារូ ឲ្យចូលជាសមាជិក សេ-អ៊ី-អា។ នៅឆ្នាំ១៩៦៧ ឈ្មោះ រៀម សុខ អតីតចៅសង្កាត់អូរប្រាសាទ ស្រុកមង្គលបូរី គឺជាអ្នករៀបចំពិធីបញ្ចូលខ្ញុំ និង អែម សារូ ជាសមាជិក សេ-អ៊ី-អា ដើម្បីចូលរួមបំផ្លាញអង្គការបដិវត្តន៍ខ្មែរក្រហម។ ក្រោយចូលជាសមាជិកសេ-អ៊ី-អា រៀម សុខ បានឲ្យខ្ញុំធ្វើសកម្មភាពជាមួយ ណៃម ផែន អតីតជាទាហាន, ស្រី គីមឈឿន ហៅ សួង អតីតជាទាហានព្រិន្ទបាលឯក។

ពីឆ្នាំ១៩៦៨ ដល់ឆ្នាំ១៩៦៩ ខ្ញុំ និង អែម សារូ បានអប់រំ កសាងកម្លាំងបាន ៤នាក់ គឺ ១) ម៉ម សុវណ្ណ ហៅ ថាំង គឺជាអតីតទាហានបច្ចុប្បន្នប្រជាជនថ្មីនៅភូមិព្រៃទទឹង ស្រុកមង្គលបូរី តំបន់៤។ ២) ម៉ម សុផុន គឺជាអតីតទាហានឋានន្តរស័ក្ដិពលទោ បច្ចុប្បន្នគឺជាប្រជាជនថ្មីរស់នៅភូមិព្រៃទទឹង ស្រុកមង្គលបូរី តំបន់៤។ ៣) ជួប ប៊ុនរៀន អតីតជាទាហានពលទោ បច្ចុប្បន្នក្ដាប់មិនបាន និង ៤) យិន ចំណាន អតីតទាហានឋានន្តរស័ក្ដិពលទោ បច្ចុប្បន្នក្ដាប់មិនបាន។ ខ្លឹមសារដែលខ្ញុំពីរនាក់អប់រំទៅកាន់អ្នកទាំង៤ គឺធ្វើយ៉ាងម៉េចប្រឆាំងជាដាច់ខាត កុំឲ្យកងកម្លាំងខ្មែរក្រហមគ្រប់គ្រងប្រទេសបាន។

នៅខែមករា ឆ្នាំ១៩៧០ រៀម សុខ បានហៅសមាជិក សេ-អ៊ី-អា ទាំងអស់ទៅប្រជុំនៅស៊ីសុផុន ដើម្បីក្ដាប់យកផែនការថ្មី និង ណែនាំមេដឹកនាំម្នាក់ទៀតដែលទើបតែចេញមុខ។ សមាសភាពក្នុងអង្គប្រជុំមានសមាជិកចំនួន៧ នាក់គឺ ៖ ប្រាក់ ភុយ អតីតសក្ដិ២ បច្ចុប្បន្នក្ដាប់មិនបាន, ងី សិទ្ធិណារិន អតីតទាហានឋានន្តរស័ក្ដិពលបាលត្រី បច្ចុប្បន្នក្ដាប់មិនបាន, រៀម សុខ, ណៃម ផែន, ស្រី គីមឈឿន, អែម សារូ និង រូបខ្ញុំផ្ទាល់។ ខ្លឹមសារអង្គប្រជុំ គឺត្រូវធ្វើរដ្ឋប្រហារមួយនៅក្នុងក្រុងភ្នំពេញ ហើយត្រូវត្រៀមលក្ខណៈគាំទ្ររដ្ឋប្រហារនេះ និងត្រូវអនុវត្តផែនការនេះឲ្យបានម៉ឺងម៉ាត់។ ការប្រជុំនេះប្រើរយៈពេលមួយម៉ោងពេញ ទើបប្រកាសបិទ ក្រោមបរិយាកាសសប្បាយរីករាយ រួចក៏លាគ្នាទៅអនុវត្តផែនការតាមមុខសញ្ញារៀងៗខ្លួន។

នៅខែកុម្ភៈ ឆ្នាំ១៩៧០ ដដែល ខ្ញុំនិង អែម សារូ បានកសាងកម្លាំងបានបន្ថែម២នាក់ទៀត គឺឈ្មោះ សួស សារ៉េត អតីតធ្វើស្រែចម្ការ បច្ចុប្បន្នក្ដាប់មិនបាន, និង សួស សារឿន អតីតធ្វើស្រែចម្ការ បច្ចុប្បន្នក្ដាប់មិនបាន។ ដល់ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ក៏ស្រាប់តែមានរដ្ឋប្រហារមួយកើតឡើងដើម្បីផ្ដួលរំលំសម្ដេច សីហនុ ។ ដំណឹងនៃការទម្លាក់សម្ដេចព្រះនរោត្តម សីហនុ បានឮខ្ទរទាំងប្រទេស ធ្វើឲ្យកំហឹងប្រជាជនផើបបះបោរគ្រប់ទិសទី។ ចំណែកខ្ញុំ គឺត្រូវមានភារកិច្ចពន្យល់ប្រជាជនថា នេះគឺជារឿងនយោបាយរវាងសម្ដេច សីហនុ និង លន់ នល់។

នៅខែមេសា ឆ្នាំ១៩៧០ ខ្ញុំបាននាំ សួស សារឿន និង សួស សារ៉េត ឲ្យទៅសៀមរាប អង្គរ ក្នុងគោលបំណងបង្កប់ខ្លួនដើម្បីយកព័ត៌មានពីខ្មែរក្រហមតាមបញ្ជារបស់ រៀម សុខ។ ប៉ុន្តែតាំងពីទៅសៀមរាប រហូតមកដល់ថ្ងៃនេះ ខ្ញុំមិនដែលឮ ឬទទួលដំណឹងអ្វីទាល់តែសោះ។

នៅខែកញ្ញា ឆ្នាំ១៩៧០ ខ្ញុំត្រូវចូលធ្វើជាទាហាននៅស្រុកមង្គលបូរី ដោយមានកម្លាំង សេ-អ៊ី-អា ចូលទៅមុនខ្លះដែរ ដូចជាឈ្មោះ ហ៊ូរ៉ុម អតីតទាហានឋានន្តរស័ក្ដិពាក់សក្ដិ២, មាន ឆុំ អតីតទាហានការិយាល័យទី២ឋានន្តរស័ក្ដិពលទោ, ឌិក សារួម ហៅ ទី អតីតទាហាន, សំ ទន អតីតទាហាន។ ខ្ញុំត្រូវរៀនក្បួនយុទ្ធសាស្ត្ររយៈពេលមួយខែ នៅសាលាយុទ្ធសាស្ត្រស៊ីសុផុន។ ចំណែកនៅក្នុងភូមិស្រុក ខ្ញុំមាននាទីដើរបង្កើតល្បែងស៊ីសងគ្រប់ប្រភេទជាមួយភ្នាក់ងារដែលខ្ញុំស្គាល់ថ្មីនេះ និងយកប្រាក់ពីមេៗជូនលោកមេបញ្ជាការ ម៉ម ធុល អតីតស័ក្ដិ២។

នៅដើមឆ្នាំ១៩៧១ ខ្ញុំត្រូវឡើងទៅរៀន

ផ្នែកយុទ្ធសាស្រ្តនៅ ឡាំស៊ើង ប្រទេសវៀតណាម ខាងត្បូង រយៈពេល៣ខែ។ ពេលខ្ញុំឡើងទៅរៀន នៅ ឡាំស៊ើង ខ្ញុំបានស្គាល់មិត្តភក្តិច្រើន។ ខ្ញុំបានអប់រំកសាងបានជាខ្សែរយៈ រួមមាន៖ សៀង អឿម អតីតទាហានឋានន្តរស័ក្តិពលទោ, ប៊ុល រិមឈាន អតីតទាហានឋានន្តរស័ក្តិពលទោ។ ពេលរៀនក្បួនយុទ្ធសាស្រ្តយោធាចប់ខ្ញុំត្រឡប់មកអង្គភាពវិញ ហើយខ្ញុំទទួលបានច្បាប់សម្រាកកន្លះខែ។

នៅខែមេសា ឆ្នាំ១៩៧១ ខ្ញុំត្រូវបានអង្គភាពផ្លាស់មកធ្វើការនៅស្រុកមោងឫស្សី។ នៅពេលនោះ ខ្ញុំអប់រំបានមិត្តភក្តិម្នាក់ទៀតឈ្មោះ សុី ហុងរី គឺជាអតីតទាហាន បច្ចុប្បន្នប្រជាជនថ្មី រស់នៅភូមិរហាត់ទឹក ស្រុកមង្គលបូរី តំបន់៣។ នៅពេលធ្វើការនៅស្រុកមោងឫស្សី ខ្ញុំជួបការលំបាកវេទនាខ្លាំងណាស់ ម្យ៉ាងទៀតខ្មែរក្រហមកំពុងប្រមូលទ័ពមកបន្ថែម ដូច្នេះខ្ញុំក៏សម្រេចចិត្តរត់ចោលសាលាស្រុកមោងឫស្សីមករស់នៅផ្ទះវិញ ព្រោះខ្លាចស្លាប់។

នៅខែមិថុនា ឆ្នាំ១៩៧២ ខ្ញុំចូលធ្វើជាទាហាននៅកងពលតូចពិសេសលេខ១២ នៃវរសេនាតូចផ្នែកគាំទ្រ កងអនុសេនាធំដឹកនាំ។ កងពលតូចនេះ មានវរសេនីយ៍ទោ នង ហ៊ាន និង តាន់យក់សាន អតីតអនុសេនីយ៍ឯក គឺជាមេបញ្ជាការផ្ទាល់។ ក្រោយមក តាន់យក់សានបានឲ្យខ្ញុំទៅរៀនបើកបរឡាននៅកងពលតូចដឹកនាំទី១ ពោធិ៍ចិនតុងរយៈពេល៣ខែ ជាមួយឈ្មោះ ម៉ុត ណារ៉ុង អតីតទាហានឋានន្តរស័ក្តិនាយឯក បច្ចុប្បន្នប្រជាជនថ្មីរស់នៅភូមិព្រៃទទឹង ស្រុកមង្គលបូរី តំបន់៤ គឺជាខ្សែរយៈរបស់ ណែម ដែន។ នៅខែកញ្ញា ឆ្នាំ១៩៧២ ខ្ញុំរៀនចប់ ហើយក៏វិលមកភ្នំធំវិញជាមួយ ម៉ុត ណារ៉ុង ចំណែកអ្នកផ្សេងទៀត ណែម ដែន បាននាំមកវិញមុនអស់ហើយ។

នៅខែកុម្ភៈ ឆ្នាំ១៩៧៣ រៀម សុខ និង ប្រាក់ ភុយ ក្រោយពីទទួលដំណឹងថាកម្លាំងវិលត្រឡប់មកពីរៀនបើកបរ ឡានហើយ ក៏រៀបចំហៅទៅប្រជុំនៅ សិរីសោភ័ណ។ សមាជិកប្រជុំមានគ្នា៧នាក់ គឺ ប្រាក់ ភុយ, រៀម សុខ, ណែម ដែន, ស្រី គីមឈឿន, ម៉ុត ណារ៉ុង, ងី សិទ្ធិណារិន និង រូបខ្ញុំ។ ខ្លឹមសារក្នុងអង្គប្រជុំត្រូវប្រមូលកម្លាំងឡើងវិញ និងធ្វើសកម្មភាពឲ្យបានកាន់តែខ្លាំង បំផុសប្រជាជនដែលមានអាវុធឲ្យប្រយុទ្ធបន្តទៅមុខទៀត។ ក្នុងប្រជុំនេះក៏មានសមាជិកថ្មីដែល អប់រំ កសាងបានពី រៀម សុខ។ សមាជិកថ្មីមានឈ្មោះ ៖ ឌឹម ខត្តម អតីតទាហានឋានន្តរស័ក្តិពលបាលត្រី បច្ចុប្បន្នប្រជាជនថ្មីរស់នៅភូមិព្រៃទទឹង ស្រុកមង្គលបូរី តំបន់៤។ អ៊ិន ង៉ុយ អតីតស្មៀនសហករណ៍ស៊ុយត្រាណ បច្ចុប្បន្នប្រជាជនថ្មីរស់នៅភូមិព្រៃទទឹង ស្រុកមង្គលបូរី តំបន់៤។ ទាន សុន ហៅ លឹម អតីតទាហានឋានន្តរស័ក្តិពលបាលត្រី បច្ចុប្បន្នប្រជាជនថ្មីរស់នៅភូមិបឹងព្រះ ស្រុកមង្គលបូរី តំបន់៣។ ឡោ ហ៊ិតស៊ុយ អតីតស៊ុយត្រាណ បច្ចុប្បន្នប្រជាជនថ្មីរស់នៅភូមិព្រៃទទឹង ស្រុកមង្គលបូរី តំបន់៤។ ឡុង លីណាត អតីតស៊ុយត្រាណ និង ជួញកាំភ្លើង បច្ចុប្បន្នប្រជាជនថ្មីរស់នៅភូមិព្រៃទទឹង ស្រុកមង្គលបូរី តំបន់៤។ ស៊ានរស់ ហៅ ម៉ឹង អតីតទាហាន មេស៊ុយត្រាណ ឋានន្តរស័ក្តិពលបាលត្រី។ យ៉ាន សូរីផន អតីតស៊ុយត្រាណ។ គន់ វ៉ាន់ អតីតស៊ុយត្រាណ។ ពិន ឆាត អតីតមេភូមិ និងជាស៊ុយត្រាណ។ ចូលមកខែមីនា ឆ្នាំ១៩៧៣ ខ្ញុំ និង ម៉ុត ណារ៉ុង បានទៅភូមិតាឡុំ និងស្រះរាំង ដើម្បីយកការណ៍ផ្សេងៗពីខ្មែរក្រហម ព្រមទាំងស្វែងរកកម្លាំងថ្មី។ ប៉ុន្តែគ្មានលទ្ធផលទេ ព្រោះប្រជាជនប្រាប់ថាកម្លាំងខ្មែរក្រហមបានចេញពីភូមិអស់ទៅហើយ។

នៅឆ្នាំ១៩៧៤ ខ្ញុំនៅតែបន្តធ្វើសកម្មភាពទាក់ទងកម្លាំងដដែល។ ក្រៅពីនេះខ្ញុំប្រឹងប្រែងយាមកាមការពារភូមិយ៉ាងហ្មត់ចត់បំផុត។ កម្លាំងថ្មីដែលខ្ញុំទាក់ទងបានរួមមាន៖ ម៉ម គុច អតីតទាហានពលទោ, អ៊ីវ ឌិត ហៅ ទូច អតីតទាហានស៊ុយត្រាណ និង ពិន អឿម អតីតទាហានស៊ុយត្រាណ។ ឈ្មោះខាងលើសុទ្ធតែប្រកាសចូលជាខ្សែបង្កប់ សេ-អ៊ី-អា។

នៅឆ្នាំ១៩៧៥ រៀម សុខ បានហៅខ្ញុំ និង សមាជិក សេ-អ៊ី-អា ទាំងអស់មកប្រជុំដើម្បីលើក

ផែនការអនុវត្តទៅមុខទៀត។ ខ្លឹមសារនៃអង្គប្រជុំគឺ៖ ត្រូវបំផុសចលនាប្រជាជនឲ្យក្រោកឡើងប្រឆាំងខ្មែរក្រហមបន្តទៀត។ ត្រូវអនុវត្តផែនការទី៣ គឺត្រូវចូលខ្លួនក្នុងអង្គការបដិវត្តន៍ ធ្វើសកម្មភាពបំផ្លាញបដិវត្តន៍ និងត្រូវទិកសាងកម្លាំងផ្ទៃក្នុងវាយបដិវត្តន៍វិញ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រទេសកម្ពុជាទាំងមូលត្រូវអង្គការបដិវត្តន៍រំដោះបានទាំងស្រុង។ បន្ទាប់មក ខ្ញុំត្រូវបានអង្គការជម្លៀសឲ្យទៅនៅភូមិបឹងអំពិល សង្កាត់លេខ៥ ស្រុក៧០ តំបន់៣។ ពេលនោះ ខ្ញុំដាច់ខ្សែទាក់ទងអស់ហើយ ព្រោះមិនអាចធ្វើដំណើរទៅណាមកណាបាន។ ខ្ញុំចូលក្នុងបដិវត្តន៍នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ១៩៧៥ នៅក្នុងសង្កាត់លេខ៥ ដោយគណៈឃុំនាំចូល។ អង្គការបដិវត្តន៍ក៏បញ្ជូនខ្ញុំឲ្យទៅធ្វើការនៅក្រសួងពាណិជ្ជកម្មរដ្ឋក្នុងក្រុងកំពង់សោម ដែលមានឈ្មោះ ញ៉ែម ជាប្រធាន។ នៅកន្លែងធ្វើការរបស់ខ្ញុំ មានគ្នា១០០នាក់ ដែលអង្គការចាត់តាំងឲ្យធ្វើផ្ទះគំរូ «មិត្តភាពកម្ពុជាចិន» ដែលមានឈ្មោះ ស៊ាន អតីតប្រធានវរសេនាតូចកម្មករ គឺជាប្រធានក្តាប់ផ្ទាល់។ មិត្ត ស៊ាន ស្រឡាញ់ក្រុមការងារណាស់ ហើយគាត់តែងតែបំប៉នចំណីអាហារដល់ក្រុមការងារមិនឲ្យមានការខ្វះខាតឡើយ។ នៅខែកញ្ញា ឆ្នាំ១៩៧៥ ស៊ាន បានហៅខ្ញុំទៅលេងផ្ទះរបស់គាត់ និងទទួលខ្ញុំដោយក្តីរាក់ទាក់ ព្រមទាំងនិយាយអប់រំខ្ញុំអំពីចំណុចខ្វះខាតរបស់អង្គការ ហេតុដូច្នេះយើងត្រូវបំផ្លាញបដិវត្តន៍តាមគ្រប់សកម្មភាពទាំងអស់។

នៅខែមករា ឆ្នាំ១៩៧៦ ខ្ញុំត្រូវបានអង្គការដកមកឲ្យបំពេញភារកិច្ចនៅរោងចក្រអារឈើវិញ ដើម្បីធ្វើទ្វារ បង្អួច និងមន្ទីរចាត់ការពាណិជ្ជកម្ម ដោយមានឈ្មោះ ស្វ អតីតជាយោធាកងតូច គឺជាអ្នកដឹកនាំ។ ស្វ ក៏ជាខ្សែបង្កប់មួយរូបដែរ។ ក្រៅពីបំពេញភារកិច្ចបដិវត្តន៍ ខ្ញុំនិង ស្វ ធ្វើសកម្មភាពបំផ្លាញបដិវត្តន៍ដែរ។ នៅឆ្នាំ១៩៧៧ ខ្ញុំយកដីខ្សាច់ទៅដាក់នៅក្នុងប្រេងម៉ាស៊ីនអេឡិចទ័រលើកឈើក្នុងរោងចក្រអារឈើ។ ក្រោយមក អង្គការបានបញ្ឈប់ការកាប់ឈើទាំងអស់ ហើយ ខ្ញុំក៏វិលមករស់នៅ និងធ្វើការក្នុងសហជីពវិញ។ ពេលនោះ អង្គការបានចាត់តាំងខ្ញុំឲ្យធ្វើការផ្នែកបន្តុបបង្កើនផល និងបង្រៀន នារីៗ យុវជនដែលមិនចេះអក្សរថែមទៀត។ ក្នុងកងបន្តុបបង្កើនផល ខ្ញុំតែងតែនាំមិត្តដែលធ្វើការជាមួយទៅកាប់អំពៅ ដកដំឡូងហូបយ៉ាងខ្ជះខ្ជាយបំផុត។ នៅពេលបង្រៀន ខ្ញុំតែងតែសម្លុត ស្តីបន្ទោសបងប្អូនខ្លះឲ្យខឹងរហូតដល់ឈប់រៀន។ ខ្ញុំតែងតែលួចធ្វើសកម្មភាពបំផ្លាញបដិវត្តន៍រហូតអង្គការចាប់ខ្លួន នៅថ្ងៃទី៨ ខែតុលា ឆ្នាំ១៩៧៧។

**កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីឯកសារចម្លើយសារភាព J០០០៣៨។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខខ្មែរក្រហម សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថា ចម្លើយសារភាពរបស់ ជន វ៉ាន់ឌី ពិតឬយ៉ាងណានោះទេ។**



កម្មករកំពុងអារឈើនៅក្នុងរបបខ្មែរក្រហម (ពីឆ្នាំ១៩៧៥-១៩៧៩)។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងរៀបចំដំណើរ
## ទស្សនកិច្ចសិក្សាស្តីអំពី «សន្តិភាព និងសិទ្ធិមនុស្ស» ដល់សិស្សវិទ្យាល័យស្រែណូយ

**មេក ទិន**



នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៤ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងរៀបចំដំណើរទស្សនកិច្ចសិក្សាស្តីអំពី «សន្តិភាព និងសិទ្ធិមនុស្ស» ដល់សិស្សានុសិស្សចំនួន៤០នាក់ មកពីវិទ្យាល័យស្រែណូយ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៤ សិស្សានុសិស្សចំនួន៤០នាក់នៃវិទ្យាល័យស្រែណូយ បានចូលរួមដំណើរទស្សនកិច្ចសិក្សាស្តីពី«សន្តិភាព និងសិទ្ធិមនុស្ស» នៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង និងទីតាំងប្រវត្តិសាស្ត្រនៅស្រុកអន្លង់វែង។ ទស្សនកិច្ចសិក្សានេះ ត្រូវបានរៀបចំឡើងដើម្បីលើកកម្ពស់ការយល់ដឹងអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដល់យុវជន ព្រមទាំងឈ្វេងយល់អំពីដំណើរការនៃការកសាងសន្តិភាព និងការផ្សះផ្សា។ មុនពេលចូលរួមដំណើរទស្សនកិច្ចសិក្សានេះ ហៃ សេងហ៊ុង មានអាយុ១៧ឆ្នាំ គឺជាសិស្សវិទ្យាល័យស្រែណូយបាននិយាយថា ខ្លួនធ្លាប់បានដឹងអំពីអន្លង់វែងខ្លះៗដែរថា មានទីតាំងប្រវត្តិសាស្ត្រជាច្រើនដែលបានបន្សល់ទុកពីរបបកម្ពុជាប្រជាធិបតេយ្យ។ ប៉ុន្តែ សេងហ៊ុង មិនដែលបានស្គាល់ ឬឃើញទីតាំងប្រវត្តិសាស្ត្រទាំងអស់នោះទេ។ សេងហុង ចង់ចូលរួមនៅក្នុងដំណើរទស្សនកិច្ចសិក្សានេះ ដើម្បីបានឈ្វេងយល់អំពីប្រវត្តិសាស្ត្រឲ្យកាន់តែច្បាស់។ ចំណែក សួង ចន្នី អាយុ១៧ឆ្នាំ គឺសិស្សវិទ្យាល័យ



*នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២៤ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងរៀបចំដំណើរទស្សនកិច្ចសិក្សាស្តីអំពី «សន្តិភាព និងសិទ្ធិមនុស្ស» ដល់សិស្សានុសិស្សចំនួន៤០នាក់ មកពីវិទ្យាល័យស្រែណូយ។*
*(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ស្រែណូយដែរ ធ្លាប់បានដឹងថា អន្លង់វែងគឺជាទីកន្លែងប្រវត្តិសាស្ត្រដ៏អស្ចារ្យ និងមានភាពទាក់ទាញសម្រាប់ភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិ។

អន្លង់វែង គឺជាទីតាំងតស៊ូចុងក្រោយរបស់ចលនាខ្មែរក្រហមដែលឆ្លុះបញ្ចាំងអំពីបរិបទសង្គ្រាម និងសន្តិភាពនៃប្រទេសកម្ពុជា។ ជាការពិតណាស់ អន្លង់វែង គឺជាសហគមន៍មួយដែលបានបន្សល់ទុកនូវកេរដំណែលនៃការតស៊ូរបស់ខ្មែរក្រហម។ ប៉ុល ពត ក៏ត្រូវបានដឹងថាជាអ្នកប្រព្រឹត្តអំពើរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ បន្ទាប់ពីរបបខ្មែរក្រហមត្រូវបានផ្តួលរំលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ អន្លង់វែង ឬត្រូវបានស្គាល់ថាជា «តំបន់១០០៣» និងតំបន់ផ្សេងទៀតនៅជាប់តាមបណ្តោយព្រំដែនកម្ពុជា-ថៃ ត្រូវបានប្រែក្លាយទៅជាទីតាំងយុទ្ធសាស្ត្រនៃការប្រមូលផ្តុំកងកម្លាំងខ្មែរក្រហមឡើងវិញ។ អង្គការចាត់តាំងរបស់ខ្មែរក្រហមមិនទាន់សាបសូន្យនោះទេ ពោលគឺនៅតែមានវត្តមាន និងបង្កជាសង្គ្រាមទ័ពព្រៃ និងសង្គ្រាមប្រជាជននៅតាមព្រំដែនរហូតដល់ឆ្នាំ១៩៩៨ នៅពេលកងកម្លាំងទាំងអស់របស់ខ្លួនបានធ្វើសមាហរណកម្មជាមួយរាជរដ្ឋាភិបាលកម្ពុជា។

បច្ចុប្បន្ននេះ ទីតាំងនៃការស្លាប់របស់មេដឹកនាំសំខាន់ៗរបស់ខ្មែរក្រហម ក៏ស្ថិតនៅតំបន់អន្លង់វែងដែរ រួមមាន ប៉ុល ពត ដែលជាបងធំទី១ របស់ខ្មែរក្រហម, ឈិត ជឿន ហៅ តាម៉ុកគឺជាមេទ័ពនៅតំបន់អន្លង់វែង និង សុន សេន ព្រមទាំងក្រុមគ្រួសារ ដែលជាអតីតរដ្ឋមន្ត្រីក្រសួងការពារជាតិនាជំនាន់នោះ។

ទីតាំងដំបូងនៃដំណើរទស្សនកិច្ចគឺជាមជ្ឈ-មណ្ឌលសន្តិភាពអន្លង់វែង ដែលជាអតីតផ្ទះប្រជុំតាម៉ុក។ ក្រុមការងារបានរៀបចំពិព័រណ៍រូបថតនៃអំពើប្រល័យពូជសាសន៍ និងសង្គ្រាម ដើម្បីឲ្យសិស្សានុសិស្សបានទស្សនានៅបរិវេណមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ រូបភាពទាំងអស់នោះបង្ហាញអំពីមេដឹកនាំខ្មែរក្រហមដែលភៀសខ្លួនទៅកាន់ព្រំដែន។

យុវជនម្នាក់ក៏បានសួរនាំអំពីដំណើរនៃការបង្កើតជំរំជនភៀសខ្លួននៅតាមព្រំដែន និងមើលឃើញអំពីស្ថានភាពដ៏គួរឲ្យតក់ស្លុតនៃរូបថតចំនួនបីផ្ទាំងដែលរូបទីមួយ គឺជារូបកុមារម្នាក់មានរូបរាងស្គមស្គាំងបានដេកស្លាប់នៅក្នុងព្រៃ ខណៈពេលភៀសខ្លួនទៅតាមព្រំដែន។ ឯរូបទីពីរ គឺជារូបអ្នកទោសដែលត្រូវបានបាញ់សម្លាប់ចំក្បាលពីក្រោយនៅក្នុងគុកទួលស្លែង។ ចំណែកឯរូបទីបី គឺជារូបការជីកកកាយរកគ្រោងឆ្អឹង និងលលាដ៍ក្បាលជនរងគ្រោះដែលបានស្លាប់នៅ



នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២៤ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងរៀបចំដំណើរទស្សនកិច្ចសិក្សាស្តីអំពី «សន្តិភាព និងសិទ្ធិមនុស្ស» ដល់សិស្សានុសិស្ស ចំនួន៤០នាក់ មកពីវិទ្យាល័យស្រែណូយ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





ក្នុងជំនាន់ខ្មែរក្រហម។ បន្ទាប់មកទៀត យុវជនក៏បានមើលពិព័រណ៍មួយផ្នែកទៀត ដែលបង្ហាញអំពីអំពើឧក្រិដ្ឋកម្ម និងភស្តុតាងនៃអំពើប្រល័យពូជសាសន៍ ដែលបន្សល់ទុកពីរបបខ្មែរក្រហមតាមរយៈរូបថតនៃអំពើឃោរឃៅនៅមន្ទីរស-២១ និងរូបអដ្ឋិធាតុជនរងគ្រោះដែលត្រូវបានជីកកកាយដើម្បីតម្កល់ទុកនៅបូជនីយដ្ឋានជាច្រើនកន្លែងក្នុងប្រទេសកម្ពុជា ។ ក្រៅពីនោះ ពិព័រណ៍មួយផ្នែកទៀតក៏បង្ហាញអំពីការរស់ឡើងវិញរបស់ប្រជាជនកម្ពុជាបន្ទាប់ពីថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ រួមមាន៖ ការរស់ឡើងវិញនៃអាជីពការងារ, សិទ្ធិសេរីភាព, វិស័យអប់រំ និងសិក្សាធិការ, ការស្វែងរកយុត្តិធម៌ , ការគោរពប្រណិប័តន៍សាសនា, សកម្មភាពកម្សាន្តនានា និងមាតុភូមិនិវត្តន៍របស់ប្រជាជនទៅកាន់ទីកន្លែងកំណើត តាមរថយន្តដើម្បីជួបជុំសាច់ញាតិ និងក្រុមគ្រួសារ ។ បន្ទាប់ពីទស្សនាពិព័រណ៍រួចរាល់ យុវជនក៏បាននាំគ្នាចូលទៅក្នុងអគាររបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដើម្បីស្តាប់ និងពិភាក្សាអំពីប្រវត្តិសាស្ត្រដែលទីតាំងនេះធ្លាប់តែជាទីកន្លែងប្រជុំរបស់មេដឹកនាំខ្មែរក្រហមអំពីយុទ្ធសាស្ត្រសង្គ្រាម ប៉ុន្តែបច្ចុប្បន្នជាទីកន្លែងអប់រំពីអំពើប្រល័យពូជសាសន៍ និងសន្តិភាព។ បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងបានធ្វើបទបង្ហាញអំពីការកកើតដំបូងនៃបក្សកុម្មុយនីស្តកម្ពុជា ដោយផ្សារភ្ជាប់ជាមួយឈ្មោះមេដឹកនាំសំខាន់ៗនៅអន្លង់វែង, ការទស្សនាវីដេអូ «រឿងរ៉ាវនៅពីក្រោយគុកទួលស្លែង» , បទបង្ហាញអំពីព្រឹត្តិការណ៍ចុងក្រោយដែលឈានដល់ការដួលរលំចលនាខ្មែរក្រហមនៅអន្លង់វែង និងការប្រែមុខមាត់ថ្មីរបស់សហគមន៍អន្លង់វែងដែលជាកន្លែងនៃការបង្រួបបង្រួមជាតិ និងការចែករំលែកគ្នាក្នុងចំណោមយុវជន និងសូម្បីតែអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម អំពីអំពើប្រល័យពូជសាសន៍ សង្គ្រាម និងសន្តិភាពដែលបានមកដោយលំបាក។ ក្រៅពីនេះក៏រួមបញ្ចូលនូវទស្សនទានដែលនឹងប្រែក្លាយតំបន់អន្លង់វែងពីទឹកដីដែលពោរពេញដោយការឈឺចាប់ និងខ្មាំងខ្មោចដោយសារភ្លើងសង្គ្រាម ទៅជាទឹកដីដែលមានការអភិវឌ្ឍន៍ជឿនលឿនទៅមុខ។

**ស្លួង ចន្ធី** ភេទស្រី ក្នុងវ័យ១៧ឆ្នាំ បានបានលើកឡើងថា៖«ខ្ញុំពិតជាមានអារម្មណ៍ត្រេកអរ និងសប្បាយ

ចិត្តដែលបានមកសិក្សាអំពីទីតាំងប្រវត្តិសាស្ត្រនីមួយៗ ដូចជា អតីតផ្ទះប្រជុំតាម៉ុក ជាពិសេស ទីតាំងផ្ទះលាក់ខ្លួនរបស់ ប៉ុល ពត ដែលខ្ញុំមិនដែលធ្លាប់ឃើញនិងដឹងពីមុនមកនោះទេ។ បន្ថែមពីនេះ ខ្ញុំបានសិក្សាឈ្វេងយល់បន្ថែមអំពីខ្លឹមសារផ្ទាំងពិព័រណ៍ទាក់ទងទៅនឹងរបបខ្មែរក្រហម ដែលធ្វើឲ្យខ្ញុំដឹងថានៅពេលដែលកងទ័ពវៀតណាមបានវាយចូលមកធ្វើឲ្យប្រជាជនខ្មែររត់ភៀសខ្លួននៅតាមប្រកព្រំដែន ខ្មែរ-ថៃ ដើម្បីសម្ងំលាក់ខ្លួនក្នុងព្រៃ។ បន្តមកទៀត ខ្ញុំបានដឹងអំពីប្រជាជនដែលបានជាប់ឃុំឃាំងនៅក្នុងគុកទួលស្លែងពិតជាមានភាពលំបាកវេទនា ពីមួយថ្ងៃទៅមួយថ្ងៃ ប្រជាជនរស់នៅក្នុងភាពភ័យខ្លាច។ សូម្បីតែកន្លែងរស់នៅក៏មានភាពស្មោកគ្រោក មានតាំងពីសាកសពអ្នកទោសដែលនៅក្នុងបន្ទប់ជាមួយគ្នាបានស្លាប់ស្អុយរលួយក្បែរនោះៗ ខ្ញុំមិនអាចទទួលយកនូវរឿងរ៉ាវទាំងនោះបានទេ ជាពិសេសការធ្វើទារុណកម្មដ៏សាហាវឃោរឃៅ ហើយខ្ញុំគិតថាអ្នកដែលអាចតស៊ូរស់នៅបានពិតជាអស្ចារ្យណាស់។ ខ្ញុំបានដឹងពីជីវភាពរបស់ប្រជាជនខ្មែរបន្ទាប់ពីបញ្ចប់សង្គ្រាមទៅ គឺប្រជាជនមានជីវភាពខ្វះខាតជាខ្លាំង រហូតនាំគ្នាទៅជីកកកាយរកសាកសពខ្មោចដែលស្លាប់នៅជំនាន់ខ្មែរក្រហម ដើម្បីទទួលបាននូវប្រាក់កម្រៃ និងអង្ករមកផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ។ ចំពោះទីតាំងតំបន់ប្រវត្តិ-សាស្ត្រនៅអន្លង់វែងខ្ញុំចាប់អារម្មណ៍កន្លែងលាក់ខ្លួន ប៉ុល ពត ជាងគេ ពីព្រោះខ្ញុំមិនដែលបានឃើញរូងក្រោមដីបែបនេះពីមុនមកនោះទេ»។

**វែសន សម័យ** អាយុ១៨ឆ្នាំ បានបង្ហាញនូវចំណាប់អារម្មណ៍បន្ទាប់ពីចូលរួមទស្សនកិច្ចសិក្សាថា «ខ្ញុំសប្បាយចិត្តណាស់ នៅពេលដែលបានដឹងដំណឹងថា នឹងបានចូលរួមក្នុងដំណើរទស្សនកិច្ចនៅតំបន់ប្រវត្តិសាស្ត្រអន្លង់វែង។ ការសិក្សាអំពីប្រវត្តិសាស្ត្រនៅថ្ងៃនេះបានធ្វើឲ្យខ្ញុំដឹងកាន់តែច្បាស់ពីការដាក់ទោស ការធ្វើទារុណកម្ម និងការធ្វើបាបទៅលើប្រជាជនខ្មែរក្នុងសម័យខ្មែរក្រហមយ៉ាងសាហាវឃោរឃៅ។ ខ្ញុំបានដឹងនូវព្រឹត្តិការណ៍សំខាន់ៗដូចជា យល់ដឹងអំពីគុកទួលស្លែង យល់ដឹងអំពីការដាក់ទោស ការធ្វើទារុណកម្មលើអ្នកទោស និងវិធីនៃការសួរចម្លើយរបស់ខ្មែរក្រហម។ ការមកសិក្សារៀនសូត្រពីប្រវត្តិសាស្ត្រដល់ទីតាំងផ្ទាល់បែបនេះបានធ្វើឲ្យខ្ញុំមានចំណេះដឹងកាន់តែច្បាស់ដែលអាចចែករំលែកទៅអ្នកដទៃ មិត្តភក្តិ និងក្រុមគ្រួសារបាន»។

**សំអុល និក្កា** ភេទស្រី អាយុ១៦ឆ្នាំ បានបង្ហាញចំណាប់អារម្មណ៍បន្ទាប់ពីចូលរួមទស្សនកិច្ចសិក្សាថា «ការបានមកចូលរួមក្នុងដំណើរទស្សនកិច្ចនេះធ្វើឲ្យខ្ញុំយល់ដឹងអំពីទុក្ខលំបាកប្រជាជននៅក្នុងរបបខ្មែរក្រហម។ ខ្ញុំមានអារម្មណ៍ថាប្រជាជនខ្មែរទាំងអស់ពិតជាទទួលភាពឈឺចាប់ជាខ្លាំងពីការធ្វើទារុណកម្មយ៉ាងព្រៃផ្សៃ។ លើសពីនេះទៅទៀតធ្វើឲ្យខ្ញុំដឹងថានៅក្នុងសម័យនោះបានធ្វើបាបប្រជាជនខ្មែរ និងធ្វើទារុណកម្មលើអ្នកទោសតាមវិធីឆក់ខ្សែភ្លើង ដកក្រចកដៃ ក្រចកជើង និងវាយធ្វើទារុណកម្មយ៉ាងព្រៃផ្សៃ។ ក្រៅពីនេះ ខ្ញុំបានធ្វើដំណើរទៅដល់ទីតាំងបូជាសព ប៉ុល ពត ទីតាំងបូជាសព សុន សេន និងគ្រួសារ ចេតិយតាម៉ុក ជាពិសេសខ្ញុំបានទៅដល់ផ្ទះរបស់តាម៉ុក ដែលបច្ចុប្បន្ននេះជាសារមន្ទីរផ្ទះតាម៉ុក។ ខ្ញុំពិតជាសប្បាយចិត្តដែលបានធ្វើដំណើរមកដល់ដោយផ្ទាល់ ហើយបានមើលឃើញអំពីទេសភាពនៅជុំវិញផ្ទះនេះ សង់ជាប់ពីគ្នា មានសសរធំៗ និងមានទឹកនៅព័ទ្ធជុំវិញ។



នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២៤ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងរៀបចំដំណើរទស្សនកិច្ចសិក្សាស្តីអំពី «សន្តិភាព និងសិទ្ធិមនុស្ស» ដល់សិស្សានុសិស្សចំនួន៤០នាក់ មកពីវិទ្យាល័យស្រែណូយ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សិស្សមកពីវិទ្យាល័យ សម្តេច ហ៊ុន សែន ស្គន់

## ចូលរួមវេទិកាអន្តរជំនាន់ស្តីពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)»

***ទូច វណ្ណាត និង សាំង ចាន់ធូ***



នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានរៀបចំវេទិកាអន្តរជំនាន់ស្តីពី«ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការចុះទស្សនកិច្ចទៅកាន់ស្តូបរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះនៃរបបខ្មែរក្រហមដល់សហគមន៍ស្រុកកោះ សូទិន និង ស្រុកកំពង់សៀម។ (សាំង ចាន់ធូ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានរៀបចំវេទិកាអន្តរជំនាន់ស្តីពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការចុះទស្សនកិច្ចទៅកាន់ស្តូបរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះនៃរបបខ្មែរក្រហមដល់សហគមន៍ស្រុកកោះ សូទិន និងស្រុកកំពង់សៀម ខេត្តកំពង់ចាម។ វេទិកាអន្តរជំនាន់នេះមានការចូលរួមពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម គឺអ្នកស្រី គឹម អាត និងសិស្សានុសិស្សដែលកំពុងសិក្សាថ្នាក់ទី១២ ចំនួន៥០នាក់ មកពីវិទ្យាល័យ ហ៊ុន សែន ស្គន់។ គោលបំណងនៃវេទិកាគឺដើម្បីបង្កើនការយល់ដឹងដល់សិស្សានុសិស្ស អំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងបង្កើតឱកាសឲ្យមានកិច្ចសន្ទនាអន្តរជំនាន់រវាងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងយុវជនជំនាន់ក្រោយ។

ជាកិច្ចស្វាគមន៍លោក ទូច វណ្ណេត បុគ្គលិកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានបង្ហាញដល់សិស្សានុសិស្សអំពី ពិព័រណ៍រូបថតដែលត្រូវបានដាក់តាំងបង្ហាញនៅក្នុងបរិវេណមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រួមមាន ៖ ផ្ទាំងពិព័រណ៍រូបថតប្រវត្តិរូបមេដឹកនាំខ្មែរក្រហម, រូបថតមេដឹកនាំខ្មែរក្រហមដែលត្រូវបានកាត់ទោសនៅតុលាការ, ជីវិតរស់នៅរបស់ប្រជាជនក្នុងរបបកម្ពុជាប្រជាធិបតេយ្យ, ការជម្លៀសប្រជាជន និងការធ្វើការងារហួសកម្លាំងនៅក្នុងការដ្ឋានលើកទំនប់។ នៅក្នុងឱកាសនោះ លោក ទូច វណ្ណេត ក៏បានបង្ហាញយុវសិស្សទាំងអស់នូវពិព័រណ៍ចំនួន៣០ដែលដកស្រង់ចេញពីសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) បោះពុម្ពផ្សាយលើកទី២។

ជាកិច្ចបន្តលោក លី ដេវីត បុគ្គលិកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បន្តដឹកនាំសិស្សចូលទៅទស្សនានៅសាលពិព័រណ៍រូបថត ដែលមានការដាក់តាំងបង្ហាញព្រះឆាយាល័ក្ខណ៍ចំនួន១៨ផ្ទាំង ដែលជាផ្នែកមួយនៃពិព័រណ៍ «ក្តីសុបិនកម្ពុជា» រៀបចំដោយ «ព្រះរាជបណ្ណាល័យ ហ្វូងម៉ែ» នៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ មុននឹងបញ្ចប់នៃការដើរទស្សនា លោក លី ដេវីត បង្ហាញសិស្សានុសិស្សនូវបន្ទប់តម្កល់ឯកសារខ្មែរក្រហម កីតម្បាញសូត្រចាម និងបន្ទប់បណ្ណាល័យតម្កល់សៀវភៅ ទាក់ទងប្រវត្តិ-សាស្ត្រខ្មែរក្រហម។

ក្រោយពីទស្សនាពិព័រណ៍រួច លោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានធ្វើបទបង្ហាញស្តីពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជា-ធិបតេយ្យ (១៩៧៥-១៩៧៩) និងការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម» ដែលផ្តោតទៅលើព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសំខាន់ៗ ដូចជា ៖ រដ្ឋប្រហារទម្លាក់សម្តេច ព្រះនរោត្តម សីហនុ នៅឆ្នាំ១៩៧០, ការផ្ទុះឡើងនូវសង្គ្រាមជិត៥ឆ្នាំ រវាងទាហាន លន់ នល់ និង កងទ័ពខ្មែរក្រហម, ការចូលកាន់កាប់ទីក្រុងភ្នំពេញដោយកងទ័ពខ្មែរក្រហមនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥, ការជម្លៀសប្រជាជនចេញពីទីក្រុង និង ទីប្រជុំជនទៅកាន់ជនបទ, ការបង្ខំប្រជាជនឲ្យធ្វើការងារហួសកម្លាំងនៅតាមការដ្ឋានទំនប់ និងការកាប់សម្លាប់ទៅលើប្រជាជន។ លើសពីនេះទៅទៀត លោក ស៊ាង ចិន្តា បានលើកពីព្រឹត្តិការណ៍ការនៃការជម្លៀសដោយបង្ខំ ដែលមាន៣ដំណាក់កាលធំៗគឺ៖ ដំណាក់កាលទី១) ភ្លាមៗបន្ទាប់ពីចូលកាន់កាប់ទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានចាប់ផ្តើមអនុវត្តការជម្លៀសប្រជាជនដោយបង្ខំពីទីក្រុងនិងទីប្រជុំជននានាឲ្យទៅកាន់ទីជនបទដាច់ស្រយាល។ ដំណាក់កាលទី ២) ចាប់ពីខែកញ្ញាឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៧ ប្រជាជនជាច្រើនក្នុងភូមិភាគកណ្តាល ភូមិភាគនិរតី ភូមិភាគបស្ចិម និងភូមិភាគបូព៌ា (រួមមានខេត្តកណ្តាល កំពង់ធំ តាកែវ កំពង់ស្ពឺ កំពង់ឆ្នាំង និងកំពង់ចាម) ឆ្ពោះទៅកាន់ខេត្តសៀមរាប ព្រះវិហារ និង ភូមិភាគពាយ័ព្យ (រួមមាន ខេត្តបាត់ដំបង ពោធិ៍សាត់ និងបន្ទាយមានជ័យ)។ ដំណាក់កាលទី៣) ការជម្លៀសប្រជាជនពីភូមិភាគបូព៌ាក្នុងឆ្នាំ១៩៧៧ រហូតដល់ចុងឆ្នាំ១៩៧៨។ ប្រជាជននៅភូមិភូមិភាគបូព៌ា ត្រូវបានជម្លៀសចេញពីភូមិកំណើតឆ្ពោះទៅទិសពាយ័ព្យ (ខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង)។

ក្រោយពីស្តាប់បទបង្ហាញរបស់លោក ស៊ាង ចិន្តា រួច សិស្សានុសិស្សមានឱកាសស្តាប់រឿងរ៉ាវពិត និង បទពិសោធន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

អ្នកស្រី គីម អាត បានរៀបរាប់អំពីដំណើរជីវិត និង ចែករំលែកបទពិសោធន៍របស់ខ្លួនដែលជាប្រជាជនជម្លៀសទៅនៅខេត្តបាត់ដំបងទៅកាន់សិស្សានុសិស្ស ដូចខាងក្រោម៖

«ខ្ញុំឈ្មោះ **គីម អាត** ភេទស្រី អាយុ៦៣ឆ្នាំ រស់នៅក្នុងភូមិបឹងកុក២ សង្កាត់បឹងកុក ក្រុងកំពង់ចាម ខេត្តកំពង់ចាម។ ខ្ញុំរៀបការប្តីឈ្មោះ ហម សុខា និងមានកូនប្រុសស្រីចំនួន៤នាក់។ ខ្ញុំកើតនៅភូមិបឹងកុក២ សង្កាត់បឹងកុក ក្រុងកំពង់ចាម នេះតែម្តង។ ឪពុកខ្ញុំឈ្មោះ គីម ច្រឹក និងម្តាយឈ្មោះ វ៉ា អយ ហើយខ្ញុំមានបងប្អូនស្រីចំនួន៥នាក់ ដោយខ្ញុំគឺជាកូនទី៣

ក្នុងចំណោមបងប្អូនទាំងអស់នៅក្នុងគ្រួសារ។ នៅពីក្មេងខ្ញុំបានរៀននៅសាលាបឋមសិក្សាខត្តរ បានត្រឹមថ្នាក់ទី៦ សង្គមចាស់។ នៅពេលដែលមានរដ្ឋប្រហារទម្លាក់សម្តេចឪ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ម្តាយខ្ញុំបានទៅយកខ្ញុំពីខេត្តបាត់ដំបង។ ការធ្វើដំណើរតាមផ្លូវគោក គឺមិនអាចទៅរួចទេ ពីព្រោះតែការផ្តាច់ផ្លូវធ្វើចរាចរ។ នៅឆ្នាំ១៩៧២ បងស្រីខ្ញុំទិញសំបុត្រយន្តហោះបានតែ២នាក់ប៉ុណ្ណោះ ទើបបងស្រី និង ម្តាយខ្ញុំសម្រេចចិត្តវិលត្រឡប់មកកំពង់ចាមមុន។ នៅឆ្នាំ១៩៧៣ ខ្ញុំរស់នៅជាមួយបងថ្លៃ និងបានរត់គេចពីការប្រយុទ្ធគ្នារវាងទាហានលន់ នល់ និងកងទ័ពខ្មែរក្រហម។

នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានវាយដណ្តើមគ្រប់គ្រងខេត្តបាត់ដំបងទាំងអស់។ ខ្ញុំត្រូវបានជម្លៀសពីស្ពានដែកមកនៅខាងអន្លង់វិល ព្រៃចែក និងបានរស់នៅភូមិក្បែរនោះអស់រយៈពេល១ខែ។ បន្ទាប់មក ខ្ញុំត្រូវបានហៅទៅធ្វើប្រវត្តិរូប។ ខ្មែរក្រហមបានសួរខ្ញុំពីមុនធ្វើអ្វី? ឪពុកម្តាយធ្វើអ្វី? តើមានបុណ្យស័ក្តិអ្វី? ខ្ញុំបានឆ្លើយថា គាត់គឺជាអ្នកស្រែចម្ការ អត់មានធ្វើអ្វីនោះទេ។ ខ្មែរក្រហមនៅតែសួរខ្ញុំថាមិនមែនទេ អ្នកឯងមានឪពុកធ្វើមន្ត្រីរាជការ ដែលធ្វើការងារធំ និងមានបងប្អូនធ្វើទាហាន។ ខ្មែរក្រហមសួរច្រើនណាស់។ ខ្ញុំប្រាប់ថាមិនមែនទេ។ ខ្ញុំបានឆ្លើយថា ខ្ញុំគឺជាក្មេងកំព្រារស់នៅជាមួយគេ។ ព្រឹកថ្ងៃបន្ទាប់ ខ្មែរក្រហមបានឲ្យខ្ញុំទៅស្ទូង និងសួរថា ខ្ញុំចេះធ្វើស្រែមែនឬទេ។ ខ្មែរក្រហមបន្តតាមដានខ្ញុំ។ នៅកន្លែងស្ទូងស្រូវ ខ្ញុំមិនចេះស្ទូង ហេតុនេះក៏យកម្រាមដៃទាំង៥ច្រមុចូលដី។ នៅពេលដែលស្ទូងរួច សំណាបអណ្តែតឡើងវិញ។ ប៉ុន្តែសំណាងល្អមានអ៊ំស្រីម្នាក់បានប្រាប់ខ្ញុំអំពីរបៀបស្ទូងស្រូវ។ គាត់ប្រាប់ថា យកម្រាមដៃមេ នឹងម្រាមដៃចង្អុលចាប់សំណាប ហើយម្រាមដៃកណ្តាលកាយដីបិទលើសំណាប។ អង្គការនិយាយថា បើសិនជាកូនអ្នកស្រែចម្ការ ហេតុដូចម្តេចមិនចេះស្ទូង។ ខ្ញុំឆ្លើយថា ទឹកជ្រៅពេកដៃខ្ញុំអត់ដល់។ ខ្មែរក្រហមចេះតែតាមដានខ្ញុំ។ នៅយប់ខ្លះ មានឈ្លបដើរស្ទាត់ៗចាំស្តាប់នៅកៀនផ្ទះ។

នៅឆ្នាំ១៩៧៦ អង្គការបង្ខំខ្ញុំឲ្យរៀបការជាមួយប្តីដែលជាជនពិការនៅប៉ៃលិន។ ខ្ញុំមិនបានដឹងថាខ្មែរក្រហមហៅទៅណាទេកាលនោះ។ ខ្មែរក្រហមគ្រាន់តែប្រាប់ខ្ញុំថាទៅដកដំឡូង ដូច្នេះខ្ញុំក៏ឡើងជិះឡានទៅ។ នៅពេលដែលទៅដល់កន្លែងរៀបចំកម្មវិធីរៀបការ មានតែខ្ញុំម្នាក់ឯង ដែលបានប្រកែកថាមិនទាន់ចង់បានប្តី។ ខ្ញុំទៅនិយាយអង្វរកម្មាភិបាលខ្មែរក្រហម។ កម្មាភិបាលនោះបាននិយាយថា បើមិត្តនារីមិនព្រមយកប្តី ត្រូវទៅដកដំឡូង និងបេះសាវម៉ាវ ជាមួយមិត្តនារី ៣ទៅ៤នាក់ទៀត ដែលគេចមិនព្រមយកប្តី។ បន្ទាប់មក ខ្ញុំត្រូវបានបញ្ជូនទៅធ្វើការងារនៅទីនោះអស់រយៈពេល៦ខែ។ ខ្ញុំត្រូវធ្វើការ និងស្នាក់នៅម្តុំស្រះកែវចំមាត់ផ្លូវ។ នៅពេលយប់ ខ្ញុំឃើញខ្មែរក្រហមយកមនុស្សទៅវាយសម្លាប់ ដោយចងដៃមកក្រោយ និងបណ្តើរទាំងជួរៗ។

នៅឆ្នាំ១៩៧៧ អង្គការចាត់តាំងខ្ញុំឲ្យច្រូតស្រូវដែលមានគ្នាចំនួន២នាក់។ ខ្មែរក្រហមបានដើរមើលរហូត។ ខ្ញុំត្រូវបានខ្មែរក្រហមយកទៅលត់ដំពីកន្លែងមួយទៅកន្លែងមួយទៀតយ៉ាងធ្ងន់ធ្ងរ។ នៅប្រឡាយស្រះកែវ ខ្មែរក្រហមឲ្យខ្ញុំជីកដីក្នុងមួយថ្ងៃ២ម៉ែត្រគុប ហើយហូបតែបបររាវលាយត្រកួន។ ខ្ញុំមិននឹកស្មានថា ខ្ញុំអាចរស់នៅមកដល់សព្វថ្ងៃនេះទេ។ ខ្ញុំទៅរើសកួរស្រូវ ប៉ុន្តែប្រសិនបើអង្គការចាប់បាន នឹងយកទៅលត់ដំឬសម្លាប់ចោល។ ខ្ញុំលួចរើសកួរស្រូវមូលជាមួយចង្កេះខោដើម្បីយកមកបុកនិងដាំបាយហូប។

នៅឆ្នាំ១៩៧៨ ខ្ញុំត្រូវបានបញ្ជូនទៅជីកប្រឡាយទាំងយប់ជាមួយកងចល័តយុវជន និងយុវនារី។ ខ្ញុំត្រូវទៅធ្វើការពីព្រលឹមទល់ព្រលប់។ នៅម៉ោង១២យប់ ខ្ញុំយកខោអាវមួយសម្រាប់បោករួចហើយអាំងភ្លើងឲ្យស្ងួត។ នៅឆ្នាំ១៩៧៩ ខ្ញុំរួចផុតជីវិតពីទុក្ខវេទនា និងការស្លាប់។ ខ្ញុំឆ្អែតនឹងការលើកដី លើកទំនប់ និងការហូបចុកមិនគ្រប់គ្រាន់នៅក្នុងរបបខ្មែរក្រហម។ បន្ទាប់ពីរំដោះឆ្នាំ១៩៧៩ ខ្ញុំក៏បានទៅរស់នៅជំរំសាយធូ ស្ថិតនៅជាយដែនថៃ និងក្រោយមកទៀតបន្តរស់នៅអូរបុកលើភ្នំដងរែក»។

ចុងក្រោយនៃវេទិកា គឺសិស្សានុសិស្សទៅទស្សនកិច្ចស្តូបរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះនៃរបបខ្មែរក្រហមសម្រាប់សហគមន៍ស្រុកកោះសូទិន និងស្រុកកំពង់សៀម ក្រោមការដឹកនាំរបស់លោក សាំង ចាន់ធូ បុគ្គលិកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ ស្តូបរំឭកវិញ្ញាណក្ខន្ធទីមួយគឺស្ថិតនៅកណ្តាលវាលស្រែក្នុងភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម និង ស្តូបរំឭកវិញ្ញាណក្ខន្ធទីពីរ គឺស្ថិតនៅកណ្តាលចម្ការពោតនៅភូមិទី១៣ ឃុំកោះសូទិន ស្រុកកោះសូទិន។ ស្តូបរំឭកវិញ្ញាណក្ខន្ធទាំង២នេះ គឺជាទីកន្លែងដែលផ្តល់ឱកាសដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និយាយប្រាប់អំពីរឿងរ៉ាវ និងបទពិសោធន៍ដែលខ្លួនបានឆ្លងកាត់ក្នុងរបបខ្មែរក្រហមទៅកាន់យុវជនជំនាន់ក្រោយបានសិក្សាបន្ថែម។

ក្រោយវេទិកាអន្តរជំនាន់ស្តីពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការចុះទស្សនកិច្ចទៅកាន់ស្តូបរំឭកវិញ្ញាណក្ខន្ធ ជនរងគ្រោះនៃរបបខ្មែរក្រហម សិស្សានុ សិស្សក៏បានចូលរួមបញ្ចេញមតិយោបល់ដូចខាងក្រោម ៖

**យ៉ាន់ ឈាងអ៊ី ៖** «ក្រោយពេលចូលរួមវេទិកាមួយនេះហើយ ខ្ញុំបានដឹងរឿងរ៉ាវប្រវត្តិសាស្ត្រជាច្រើន រួមមានបទពិសោធន៍របស់អ៊ំស្រី គីម អាត ដែលត្រូវបានទាហានខ្មែរក្រហមចាប់សួរប្រវត្តិរូប និងប្រើទៅស្ទូងស្រូវ ទាំងគាត់មិនចេះស្ទូង។ ខ្ញុំធ្លាប់បានដឹងពីរបបខ្មែរក្រហមខ្លះៗដែរ តាមរយៈការសិក្សា និងតាមការនិយាយប្រាប់ពីលោកតាលោកយាយរបស់ខ្ញុំ ប៉ុន្តែរឿងរ៉ាវដែលខ្ញុំបានស្តាប់នៅថ្ងៃនេះ កាន់តែមានលក្ខណៈពិសេស និង ខុសប្លែកពីរឿងដែលលោកតាលោកយាយខ្ញុំបានប្រាប់ខ្ញុំពីមុន។ អ្វីដែលអាចឲ្យខ្ញុំបានដឹងបន្ថែមទៀតនៅមូលដ្ឋាននោះ គឺ ការជួបសន្ទនាផ្ទាល់ជាមួយអ៊ំប្រុសអ៊ំស្រីនៅស្តូបរំឭកវិញ្ញាណក្ខន្ធ ដែលអ៊ំបានទទួលស្វាគមន៍ និងនិយាយប្រាប់ពីប្រវត្តិសាស្ត្រមូលដ្ឋានបទពិសោធន៍



នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានរៀបចំវេទិកាអន្តរជំនាន់ស្តីពី«ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការចុះទស្សនកិច្ចទៅកាន់ស្តូបរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះនៃរបបខ្មែរក្រហមដល់សហគមន៍ស្រុកកោះ សូទិន និងស្រុកកំពង់សៀម។
(សាំង ចាន់ធូ/មជ្ឈមណ្ឌលឯកសារកម្ពុជា)





និងការបាត់បង់សាច់ញាតិរបស់ខ្លួនក្នុងរបបខ្មែរក្រហម។ អ្វីដែលខ្ញុំទទួលបាន និងយល់ដឹងនៅថ្ងៃនេះ គឺជាចំណេះដឹង និងបទពិសោធន៍ថ្មី ចេញពីការចុះទៅជួប និងទៅដល់ទីតាំងផ្ទាល់ ដែលពន្យល់បន្ថែមទៅលើអ្វីដែលខ្ញុំបានដឹងពីលោកតាលោកយាយ និងការរៀននៅក្នុងថ្នាក់»។

**ចាម ចំណាង** ៖ «វេទិកាថ្ងៃនេះគឺជាកម្មវិធីសិក្សាបន្ថែមដែលមានសារសំខាន់ និងល្អសម្រាប់ខ្ញុំដែលកំពុងសិក្សានៅវិទ្យាល័យ ព្រោះខ្ញុំទទួលបានចំណេះដឹង និងបទពិសោធន៍ថ្មី ចេញពីការមើលរូបភាពឯកសារ ការស្តាប់បទបង្ហាញរបស់លោកគ្រូ និងការចុះទៅកាន់ទីតាំងផ្ទាល់ដែលមានស្តូបរំឭកវិញ្ញាណក្ខន្ធ និងការជួបសន្ទនាជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមសរុបចំនួន៣នាក់ ដែលម្នាក់ៗមានបទពិសោធន៍ក្នុងរបបខ្មែរក្រហមខុសៗពីគ្នាទាំងអស់។ ខ្ញុំធ្លាប់បានដឹងពីរបបខ្មែរក្រហមតាមរយៈការសិក្សា និងតាមរយៈការប្រាប់ពីចាស់ៗនៅផ្ទះ ប៉ុន្តែអ្វីដែលខ្ញុំបានដឹងនៅពេលនេះគឺច្រើន និងមិនដូចរឿងរ៉ាវដែលខ្ញុំបានដឹងពីមុនមកទេ»។








នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានរៀបចំវេទិកាអន្តរជំនាន់ស្តីពី«ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការចុះទស្សនកិច្ចទៅកាន់ស្តូបរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះនៃរបបខ្មែរក្រហម ដល់សហគមន៍ស្រុកកោះសូទិន និងស្រុកកំពង់សៀម។
(សាំង ចាន់ធូ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# សិស្សថ្នាក់ទី១២ មកពីវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន ស្ដី ចូលរួមវេទិកាអប់រំសហគមន៍ ស្ដីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)

*លី ដេវីត*



នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៤ សិស្សានុសិស្សដែលកំពុងសិក្សាថ្នាក់ទី១២មកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុន សែន ស្ដី សរុបចំនួន៥០នាក់ចូលរួមវេទិកាអប់រំសហគមន៍ស្ដីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ក្រោមប្រធានបទ «ការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម» និងការចុះទៅធ្វើទស្សនកិច្ចសិក្សានៅ ទំនប់ដែលត្រូវបានកសាងឡើងនៅក្នុងរបបខ្មែរក្រហម រួមមាន ទំនប់តាកុង ស្ថិតនៅឃុំមៀន ស្រុកព្រៃឈរ (ជាប់ព្រំប្រទល់នឹងស្រុកកងមាស) ខេត្តកំពង់ចាម។ (លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៤ សិស្សានុសិស្សដែលកំពុងសិក្សាថ្នាក់ទី១២ មកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុន សែន ស្ដី សរុបចំនួន៥០នាក់ចូលរួមវេទិកាអប់រំសហគមន៍ស្ដីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ក្រោមប្រធានបទ «ការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម» និងការចុះទៅធ្វើទស្សនកិច្ចសិក្សានៅ ទំនប់ដែលត្រូវបានកសាងឡើងនៅក្នុងរបបខ្មែរក្រហមរួមមាន ទំនប់តាកុង ស្ថិតនៅឃុំមៀន ស្រុកព្រៃឈរ (ជាប់ព្រំប្រទល់នឹងស្រុកកងមាស) ខេត្តកំពង់ចាម។

វេទិកាអប់រំសហគមន៍នេះ រៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម និងមានការចូលរួមពីព្រះតេជគុណកង់ ហៃ ព្រះចៅអធិការវត្តស្វាយតាហែន និងព្រះមេគណៈខេត្តកំពង់ចាម, អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងសិស្សានុសិស្សមកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុន សែន ស្ដី ប្រព្រឹត្តឡើងនៅក្នុងបរិវេណវត្តស្វាយតាហែន ស្ថិតនៅភូមិស្វាយតាហែន ឃុំរកាគយ ស្រុកកងមាស ខេត្តកំពង់ចាម។ ព្រះវិហារ

វត្តស្វាយតាហែន មានរចនាបថយ៉ាងគួរឲ្យចាប់អារម្មណ៍ និងកម្រជួបប្រទះនោះ គឺកំពូលព្រះវិហារមានរាងដូចចេតិយ និងនៅតាមចុងដំបូលនីមួយត្រូវបានដាក់លម្អដោយចេតិយតូចៗ ទាំងអស់សរុបចំនួន១៣។ ព្រះវិហារវត្តស្វាយតាហែនមិនទទួលរងផលប៉ះពាល់ពីការទម្លាក់គ្រាប់បែក និងសង្គ្រាម នៅអំឡុងពេលវាយប្រយុទ្ធគ្នារវាងទាហានលន់ នល់ និងកងទ័ពខ្មែរក្រហមទេ។ នៅពេលដែលកងទ័ពខ្មែរក្រហមឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានបង្ខំព្រះសង្ឃឲ្យសឹក និងឲ្យវិលត្រឡប់នៅរស់នៅភូមិកំណើតវិញ។ បន្ទាប់មកខ្មែរក្រហមបានយកបរិវេណវត្ត និងព្រះវិហារបុរាណនេះប្រើប្រាស់ជាឃ្លាំងសហករណ៍សម្រាប់រក្សាទុកស្បៀងអាហារ រួមមានស្រូវអង្ករ អំបិល ប្រហុក និងចិញ្ចឹមសត្វជាដើម។

ជាកិច្ចចាប់ផ្ដើម លោក ស៊ាង ចិន្ដា នាយកមជ្ឈ-មណ្ឌលឯកសារខេត្តកំពង់ចាម ប្រកាសបើកវេទិកា បន្ទាប់មកលោកធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដែលប្រជាជនកម្ពុជាឆ្លងកាត់ទុក្ខវេទនា ការបែកបាក់គ្រួសារ និងការបាត់បង់ជីវិត។ លោក ស៊ាង ចិន្ដា ផ្ដោតទៅលើព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសំខាន់ៗ ដូចជារដ្ឋប្រហាររបស់ លន់ នល់ នៅឆ្នាំ១៩៧០, ការផ្ទុះឡើងនូវសង្គ្រាមជិត៥ឆ្នាំរវាងទាហាន លន់ នល់ និងកងទ័ពខ្មែរក្រហម, ការចូលកាន់កាប់ទីក្រុងភ្នំពេញដោយកងទ័ពខ្មែរក្រហមនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥, ការជម្លៀសប្រជាជនចេញពីទីក្រុងនិងទីប្រជុំជនទៅកាន់ជនបទ, ការបង្ខំប្រជាជនឲ្យធ្វើការងាររហួសកម្លាំងនៅតាមការដ្ឋានទំនប់ និងការកាប់សម្លាប់ទៅលើប្រជាជន។ លោក ស៊ាង ចិន្ដា បានលើកឡើងអំពីព្រឹត្តិការណ៍ការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម ដែលមានជា ៣ ដំណាក់កាលធំៗដូចខាងក្រោយ៖



- **ដំណាក់កាលទី១ ៖** ភ្លាមៗបន្ទាប់ពីចូលកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានចាប់ផ្ដើមអនុវត្តការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងទៅកាន់ទីជនបទនានា។
- **ដំណាក់កាលទី២ ៖** ចាប់ពីខែកញ្ញា ឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៧ ប្រជាជនជាច្រើនត្រូវបានខ្មែរក្រហមជម្លៀសក្នុងដំណាក់កាលទី២ គឺពីភូមិភាគកណ្ដាល ភូមិភាគនិរតី ភូមិភាគបស្ចិម និងភូមិភាគបូព៌ាឆ្ពោះទៅកាន់ខេត្តសៀមរាប ព្រះវិហារ និង ភូមិភាគពាយ័ព្យ (រួមមាន ខេត្តបាត់ដំបង ពោធិ៍សាត់ និងបន្ទាយមានជ័យ)។
- **ដំណាក់កាលទី៣៖** ការជម្លៀសប្រជាជនពីភូមិភាគបូព៌ាក្នុងឆ្នាំ១៩៧៧រហូតដល់ចុងឆ្នាំ



នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៤ សិស្សានុសិស្សដែលកំពុងសិក្សាថ្នាក់ទី១២មកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ស្ពឺ សរុបចំនួន៥០នាក់ចូលរួមវេទិកាអប់រំសហគមន៍ស្ដីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ក្រោមប្រធានបទ «ការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម» និងការចុះទៅធ្វើទស្សនកិច្ចសិក្សានៅទំនប់ដែលត្រូវបានកសាងឡើងនៅក្នុងរបបខ្មែរក្រហម រួមមាន ទំនប់តាកុដ ស្ថិតនៅឃុំមៀន ស្រុកព្រៃឈរ (ជាប់ព្រំប្រទល់នឹងស្រុកកងមាស) ខេត្តកំពង់ចាម។ (លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

១៩៧៨។ ប្រជាជននៅភូមិភូមិភាគបូព៌ាត្រូវបានជម្លៀសចេញពីភូមិឆ្ពោះទៅទិសពាយ័ព្យ (ខេត្តពោធិសាត់ និងខេត្តបាត់ដំបង)។

លោកស៊ាងចិន្តា ក៏បន្តដឹកនាំកិច្ចពិភាក្សាទៅលើការកសាងប្រព័ន្ធធារាសាស្ត្រក្នុងផែនការ៤ឆ្នាំរបស់ខ្មែរក្រហម ដែលត្រូវបានផ្តោតសំខាន់ទៅលើវិស័យកសិកម្ម ដូចជាការបង្កើនទិន្នផលស្រូវ និងការកសាងទំនប់ ជាដើម។ បន្ទាប់ពីបទបង្ហាញ និងការពិភាក្សាបានបញ្ចប់ សិស្សានុសិស្សបានស្តាប់ការចែករំលែកបទពិសោធន៍របស់អ្នករស់មានជីវិតពីរបបខ្មែរក្រហមចំនួន ២រូប ដូចខាងក្រោម៖

**សួស ឆៃរឿន** អាយុ៧៣ឆ្នាំ អតីតកងចល័តលើកទំនប់ខ្មែរក្រហម រស់នៅភូមិស្វាយតាហែន ឃុំរកាគយ ស្រុកកងមាស បានរៀបរាប់អំពីបទពិសោធន៍ក្នុងរបបខ្មែរក្រហមថា «កាលពីកុមារ ខ្ញុំរៀនសូត្របានត្រឹមថ្នាក់ទី៣ (ចាស់) នៅវិទ្យាល័យព្រះសីហនុ នៅទីរួមខេត្តកំពង់ចាម។ នៅឆ្នាំ១៩៧១ គឺជាឆ្នាំដែលខ្ញុំបានឈប់រៀន ពីព្រោះតែមានភាពចលាចលកាន់តែខ្លាំងឡើង។ ខ្ញុំឈប់រៀន និងវិលមករស់នៅភូមិកំណើតវិញ។ នៅឆ្នាំ១៩៧៣ ភូមិសាស្ត្រជាច្រើននៅខេត្តកំពង់ចាម ត្រូវបានកងទ័ពខ្មែរក្រហមគ្រប់គ្រងបាត់ទៅហើយ។ ភូមិរបស់ខ្ញុំគឺជាសមរភូមិប្រទាញប្រទង់គ្នារវាងទាហាន លន់ នល់ និងកងទ័ពខ្មែរក្រហម។ គ្រួសារខ្ញុំ ត្រូវបង្ខំចិត្តរត់គេចទៅកាន់កោះអណ្តែត នៅស្រុកកោះសូទិន ដែលជាតំបន់រំដោះខ្មែរក្រហម។

នៅឆ្នាំ១៩៧៥ ការធ្វើដំណើរទៅមករវាងកោះអណ្តែត និងពាមជីកង ឬខាងស្រុកកងមាស គឺមានភាពងាយស្រួលនៅឡើយ។ រហូតដល់ឆ្នាំ១៩៧៦ ទើបមានការលំបាកខ្លាំងក្នុងការធ្វើដំណើរចេញចូលភូមិសាស្ត្រទាំង២នេះ និយាយរួមគឺខ្មែរក្រហមហាមមិនឲ្យប្រជាជនទាំងអស់ចេញចូលតែម្តង។ បន្ទាប់មកខ្ញុំត្រូវបានដាក់ឲ្យធ្វើការងារនៅកងចល័ត។ ការងាររបស់ខ្ញុំគឺមិនសូវបានវែកដីច្រើនទេ ព្រោះកម្មាភិបាលខ្មែរក្រហមដឹងថាខ្ញុំមានចំណេះដឹងខ្លះ (គិតលេខ និងសរសេរអក្សរ) ទើបកម្មាភិបាលខ្មែរក្រហមប្រើខ្ញុំឲ្យវាស់ទំហំដី និងដើរដាំបង្គោលសម្គាល់ ដើម្បីចែកឲ្យប្រជាជនជីក និងវែកដីទៅតាមផែនការកំណត់។ នៅពេលនោះ ប្រសិនបើខ្ញុំវាស់ខុសតិចតួចកម្មាភិបាលខ្មែរក្រហមមិនសូវស្តីឲ្យឡើយ ប៉ុន្តែបើមានការវាស់ខុសច្រើន គឺកម្មាភិបាលខ្មែរក្រហមត្រឹមតែស្តីឲ្យខ្ញុំ និងឲ្យខ្ញុំវាស់ឡើងវិញម្តងទៀត។ បន្ទាប់ពីវាស់វែងទំហំដីហើយ កម្មាភិបាលខ្មែរក្រហមមកពីសហករណ៍ចុះមកពិនិត្យសិន ទើបប្រើឲ្យប្រជាជនជីកដីនោះតាមការវាស់វែងរបស់ខ្ញុំ។ ខ្ញុំក៏ត្រូវបានប្រើឲ្យទៅរករុក្ខជាតិ និងដើមឈើមកផ្សាំថ្នាំដែរ។ ដោយសារតែខ្ញុំចេះគិតលេខ កម្មាភិបាលខ្មែរក្រហមតែងតែហៅខ្ញុំទៅជាមួយ។ ខ្ញុំមិនសូវទទួលរងការធ្វើបាបខ្លាំងនោះទេ។

នៅឆ្នាំ១៩៧៨ កម្មាភិបាលខ្មែរក្រហមរៀបចំការប្រពន្ធឲ្យខ្ញុំ។ ពេលនោះ ខ្មែរក្រហមបានសួរខ្ញុំ។ ខ្ញុំឆ្លើយថាព្រមស្ម័គ្រចិត្តរៀបការជាមួយប្រពន្ធរបស់ខ្ញុំ ដែលយើងនៅរួមរស់ជាមួយគ្នារហូតដល់សព្វថ្ងៃនេះ។ ពេលនោះ ខ្ញុំនិងប្រពន្ធរស់នៅស្រុកកោះសូទិន។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅដើមឆ្នាំ១៩៧៩ ខ្ញុំ និងប្រពន្ធបានត្រឡប់មកនៅភូមិកំណើតវិញ និងប្រកបរបរធ្វើស្រែចម្ការ»។

**អ៊ុង មាន** អាយុ៨១ឆ្នាំ អតីតកងចល័តវ័យកណ្តាល រស់នៅភូមិស្វាយតាហែន ឃុំរកាគយ ស្រុកកងមាស រំឭកអំពីបទពិសោធន៍ និងការចងចាំអំពីរបបខ្មែរក្រហមទៅកាន់សិស្សានុសិស្សថា «នៅវ័យកុមារ ខ្ញុំរៀននៅសាលាបឋមសិក្សាកណ្តាលកោះ រហូតដល់ថ្នាក់ទី៧ ចាស់។ នៅពេលនោះ ខ្ញុំត្រូវបានបងថ្លៃយកទៅនៅខេត្តកំពត។ នៅទីនោះ ខ្ញុំចូលរៀន និងប្រឡងនៅវិទ្យាល័យព្រះរាជសម្ភារ ទឹកឈូរ ប៉ុន្តែខ្ញុំប្រឡងធ្លាក់ ទើបខ្ញុំត្រឡប់មករៀន និងប្រឡងនៅពាមជីកងវិញ នៅឆ្នាំ១៩៦៨។ តមក ខ្ញុំរៀននៅវិទ្យាល័យព្រះសីហនុកំពង់ចាម ពេលនោះក៏មានរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។ ខ្ញុំឃើញអ្នកភូមិបានទៅចូលរួមដង្ហែបាតុកម្មប្រឆាំងនឹង លន់ នល់ នៅ



*នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៤ សិស្សានុសិស្សដែលកំពុងសិក្សាថ្នាក់ទី១២មកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុន សែន ស្ទឹ សរុបចំនួន៥០នាក់ចូលរួមវេទិកាអប់រំសហគមន៍ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ក្រោមប្រធានបទ «ការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម» និងការចុះទៅធ្វើទស្សនកិច្ចសិក្សានៅទំនប់ដែលត្រូវបានកសាងឡើងនៅក្នុងរបបខ្មែរក្រហម រួមមាន ទំនប់តាកុដ ស្ថិតនៅឃុំមៀន ស្រុកព្រៃឈរ (ជាប់ព្រំប្រទល់នឹងស្រុកកងមាស) ខេត្តកំពង់ចាម។ (លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

ទីរួមខេត្តកំពង់ចាម។ ខ្ញុំមិនបានចូលរៀនដោយសារចលាចល និងសង្គ្រាម ហើយខ្ញុំក៏មកស្នាក់នៅផ្ទះនៅភូមិកណ្តាលកោះ ឃុំកោះអណ្តែត ស្រុកស្រីសន្ធរ ខេត្តកំពង់ចាមវិញ។

ក្រោយមកទៀត សង្គ្រាមរវាងទាហានលន់នល់ និងកងទ័ពរំដោះខ្មែរក្រហមបានផ្ទុះឡើងជាច្រើនសមរភូមិនៅក្នុងខេត្តកំពង់ចាម។ នៅឆ្នាំ១៩៧១ ខ្ញុំបានរៀបការប្រពន្ធនៅក្នុងភូមិស្វាយតាហែន។ បន្ទាប់ពីរៀបការរួច ខ្ញុំចង់ត្រឡប់ទៅរៀនវិញ ប៉ុន្តែប្រពន្ធមិនទៅជាមួយ ទើបខ្ញុំឈប់រៀន។ នៅចន្លោះឆ្នាំ១៩៧២ និង ឆ្នាំ១៩៧៣ ខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឲ្យសែងអ្នករបួសនិងសាកសពកងទ័ពខ្មែរក្រហមដែលវាយប្រយុទ្ធជាមួយទាហាន លន់ នល់ ពីទីរួមខេត្តកំពង់ចាមដោយជញ្ជូនបណ្តាក់គ្នាពីភូមិមួយទៅភូមិមួយទៀតមកព្យាបាល និងកប់។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ទីក្រុងភ្នំពេញត្រូវបានកងទ័ពរំដោះខ្មែរក្រហមវាយរំដោះ និងគ្រប់គ្រងបានទាំងស្រុង។ ក្រោយពីរំដោះក្រុងភ្នំពេញបានរយៈពេល២ទៅ៣ថ្ងៃ កងទ័ពខ្មែរក្រហមជម្លៀសប្រជាជនដោយបង្ខំចេញពីផ្ទះសម្បែង និងទីក្រុង។ ខ្ញុំបានឃើញប្រជាជនថ្មីជាច្រើនគ្រួសារដែលជម្លៀសមកពីភ្នំពេញ ហើយអ្នកខ្លះមានស្រុកកំណើតនៅ



ស្វាយតាហែន និងខ្លះទៀតត្រូវបានជម្លៀសបន្តទៅកន្លែងផ្សេងទៀត។

នៅឆ្នាំ១៩៧៦ ខ្ញុំត្រូវបានខ្មែរក្រហមដាក់ឲ្យធ្វើការនៅក្នុងកងវ័យកណ្តាល និងភ្ជួរដីដែលពីមុនខ្ញុំមិនចេះភ្ជួរឡើយ។ ខ្ញុំត្រូវបានចាត់តាំងឲ្យភ្ជួររាស់ស្រែ និងភ្ជួរដីចម្ការ។ ខ្ញុំធ្វើការពីព្រឹកព្រលឹម រហូតដល់ម៉ោង១១ ទើបឈប់ហូបបបរ ហើយធ្វើការបន្តពីម៉ោង១ដល់ម៉ោង៥ល្ងាច។ នៅខែខ្លះ ខ្ញុំត្រូវ



នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៤ សិស្សានុសិស្សដែលកំពុងសិក្សាថ្នាក់ទី១២ មកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ស្ពឺ សរុបចំនួន៥០នាក់ចូលរួមវេទិកាអប់រំសហគមន៍ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ក្រោមប្រធានបទ «ការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម» និងការចុះទៅធ្វើទស្សនកិច្ចសិក្សានៅទំនប់ដែលត្រូវបានកសាងឡើងនៅក្នុងរបបខ្មែរក្រហម រួមមាន ទំនប់តាកុដ ស្ថិតនៅឃុំមៀន ស្រុកព្រៃឈរ (ជាប់ព្រំប្រទល់នឹងស្រុកកងមាស) ខេត្តកំពង់ចាម។
(លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

បានចាត់តាំងឲ្យធ្វើការនៅពេលយប់បន្ថែមទៀត ដូចជា ដេញកណ្តុរមិនឲ្យស៊ីស្រូវ និងពោត។ នៅឆ្នាំ១៩៧៧ ខ្ញុំមានកូនចំនួន២នាក់ ចំណែកប្រពន្ធខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឲ្យធ្វើការនៅក្នុងកងត្បាញក្រមា។ បន្ទាប់មកទៀត ខ្ញុំត្រូវបានខ្មែរក្រហមបញ្ជូនទៅជីកប្រឡាយចាប់តាំងពីភូមិស្វាយតាហែន រហូតដល់ភូមិរកាគយ។ បន្ទាប់មក ខ្ញុំទៅលើកទំនប់តាកុដ ដែលមានព្រំប្រទល់រវាងស្រុកកងមាស និងស្រុកព្រៃឈរ។ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ កងទ័ពរណសិរ្សសង្គ្រោះជាតិកម្ពុជាចូលមករំដោះប្រជាជនឲ្យរួចផុតពីសេចក្តីស្លាប់»។

បន្ទាប់ពីស្តាប់សាច់រឿងរបស់អ្នករស់រានមានជីវិតរបបខ្មែរក្រហម ទាំង២រូប ខាងលើ សិស្សានុសិស្សត្រូវបានបែងចែកជាក្រុមពិភាក្សា ដែលក្រុមនីមួយៗទទួលបានប្រធានបទពិភាក្សារៀងៗខ្លួន និងមានរយៈពេល៣០នាទីដើម្បីពិភាក្សា។ តមកសិស្សានុសិស្សទាំងអស់ត្រូវបាននាំទៅទស្សនាទីតាំងទំនប់ខ្មែរក្រហមដោយផ្ទាល់ គឺទំនប់តាកុដ ស្ថិតនៅឃុំមាន ស្រុកព្រៃឈរ ខេត្តកំពង់ចាម ដើម្បីពិនិត្យមើលទិដ្ឋភាពនាពេលបច្ចុប្បន្ន និងសាកស្រមៃមើលអំពីទិដ្ឋភាពដែលប្រជាជនត្រូវបានបង្ខំឲ្យធ្វើការងាររហូសកម្លាំងនៅទំនប់នេះ។

សិស្សានុសិស្សចូលរួមវេទិកាអប់រំសហគមន៍នេះបានបង្ហាញចំណាប់អារម្មណ៍របស់ខ្លួនដូចខាងក្រោម ៖

សិស្សឈ្មោះ **សល់ ស្រីណុច** អាយុ១៧ឆ្នាំ រៀនថ្នាក់ទី១២ នៅវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ស្ពឺ ផ្នែកវិទ្យាសាស្ត្រពិត រៀបរាប់ថា «ខ្ញុំពេញចិត្តយ៉ាងខ្លាំងដែលបានចូលរួមក្នុងវេទិកាអប់រំសហគមន៍ និងទស្សនកិច្ចនៃមជ្ឈមណ្ឌលឯកសារ ខេត្តកំពង់ចាម ព្រោះកម្មវិធីនេះ ផ្តល់ចំណេះដឹងជាច្រើនសម្រាប់ខ្លួនខ្ញុំផ្ទាល់។ ខ្ញុំឈ្លេងយល់រឿងរ៉ាវដែលពាក់ព័ន្ធនឹងប្រវត្តិសាស្ត្រខ្មែរក្រហម ការរស់នៅរបស់ប្រជាជនខ្មែរនាសម័យនោះ ដែលប្រជាជនរងការលំបាកវេទនា។ ខ្មែរក្រហមបានធ្វើបាប និងប្រើឲ្យធ្វើការហួសកម្លាំង និងឲ្យហូបចុកអាហារមិនគ្រប់គ្រាន់ចំណែកប្រជាជនបាក់កម្លាំង និងអ្នកខ្លះត្រូវបាត់បង់ជីវិត។ ខ្ញុំបានស្តាប់រឿងរ៉ាវរបស់លោកតា ដែលបាននិយាយប្រាប់ពីជីវិតរស់នៅក្នុងរបបខ្មែរក្រហម និងមានការបាត់បង់សមាជិកគ្រួសារ”។

សិស្សឈ្មោះ **ផេង ជាទីត** រៀនថ្នាក់ទី១២ នៅវិទ្យាល័យប៊ុនរ៉ានី ហ៊ុនសែនស្ពឺ ផ្នែកវិទ្យាសាស្ត្រពិត រៀបរាប់ថា «ខ្ញុំសប្បាយចិត្ត ហើយក៏ក្តុកក្តួលចិត្តយ៉ាងខ្លាំងដែលបានចូលរួមក្នុងវេទិកាអប់រំសហគមន៍ដែលសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ឬហៅថា របបខ្មែរក្រហម និងបានស្តាប់រឿងរ៉ាវរបស់តាយាយ។ ខ្ញុំបានដឹងពីស្ថានភាពរស់នៅរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ការធ្វើទារុណកម្មពីមេដឹកនាំខ្មែរក្រហម ការបាត់បង់ឪពុកម្តាយ បងប្អូនសាច់ញាតិ ខ្លះភាពកក់ក្តៅ ខ្វះការអប់រំ ជាពិសេស





នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៤ សិស្សានុសិស្សដែលកំពុងសិក្សាថ្នាក់ទី១២ មកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុន សែន ស្ពឺ សរុបចំនួន៩០នាក់ចូលរួមវេទិកាអប់រំសហគមន៍ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ក្រោមប្រធានបទ «ការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម» និងការចុះទៅធ្វើទស្សនកិច្ចសិក្សានៅ ទំនប់ដែលត្រូវបានកសាងឡើងនៅក្នុងរបបខ្មែរក្រហម រួមមាន ទំនប់តាកុង ស្ថិតនៅឃុំមៀន ស្រុកព្រៃឈរ (ជាប់ព្រំប្រទល់នឹងស្រុកកងមាស) ខេត្តកំពង់ចាម។ (លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)



ការហូបចុកមិនគ្រប់គ្រាន់ និងវិស័យសុខាភិបាលមានការខ្វះខាត គ្មានថ្នាំសម្រាប់ព្យាបាល ហើយការព្យាបាលតាមបែបបុរាណ។ ការចងចាំនៃការបាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម និងបានស្តាប់រឿងរ៉ាវអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមពិតជាមានសារសំខាន់ខ្លាំងណាស់សម្រាប់ខ្ញុំគឺជាយុវជនជំនាន់ក្រោយ»។

សិស្សឈ្មោះ **រអេង សូរីកា** រៀនថ្នាក់ទី១២ នៅវិទ្យាល័យប៊ុនរ៉ានី ហ៊ុនសែនស្ពឺ ផ្នែកវិទ្យាសាស្ត្រពិត ឲ្យដឹងថា «ខ្ញុំសប្បាយចិត្តយ៉ាងខ្លាំង ដែលបានចូលរួមវេទិកាអប់រំសហគមន៍ ហើយទទួលបានចំណេះដឹងជាច្រើនព្រមទាំងបទពិសោធន៍ថ្មីៗពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដែលប្រទេសកម្ពុជាធ្លាក់ក្នុងអន្លង់នៃភាពវឹកវរ ទុក្ខវេទនា ដោយសារអ្នកដឹកនាំខ្មែរក្រហម។ ខ្ញុំក៏បានដឹងពីការរស់នៅរបស់ប្រជាជន និងការបង្អត់អាហារប្រជាជន ក្រោមការដឹកនាំរបស់ខ្មែរក្រហម។ ខ្ញុំពិតជាមានអារម្មណ៍សោកស្តាយយ៉ាងខ្លាំងចំពោះការបាត់បង់ជីវិតប្រជាជនស្លូតត្រង់នៅក្នុងរបបខ្មែរក្រហម។ ជាចុងក្រោយ ខ្ញុំសូមអរគុណថ្នាក់ដឹកនាំសាលា និងមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដែលបានរៀបចំកម្មវិធីនេះសម្រាប់ឲ្យយុវជនជំនាន់ក្រោយឈ្វេងយល់ពីប្រវត្តិសាស្ត្រខ្មែរ»។

# ខៃ ភាន ៖ ប្រជាជនក្នុងភូមិចង្អប ក្នុងរបបខ្មែរក្រហម

***សាន្ត គីមស៊ីន***



*ខៃ កាន មានអាយុ ៧០ឆ្នាំ សព្វថ្ងៃរស់នៅភូមិចង្អូប ឃុំក្បាលដំរី ស្រុកអូរគ្រៀងសែនជ័យ ខេត្តក្រចេះ។ (វង្ស ស្រីឃីម/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខៃ កាន ភេទប្រុស អាយុ៧០ឆ្នាំ គឺជាជនជាតិខ្មែរ សព្វថ្ងៃរស់នៅភូមិចង្អូប ឃុំក្បាលដំរី ស្រុកអូរគ្រៀងសែនជ័យ ខេត្តក្រចេះ បានរៀបរាប់ថា នៅឆ្នាំ១៩៧០ ខ្ញុំរៀនថ្នាក់ទី១០ចាស់ ហើយនៅឆ្នាំដដែល ខ្ញុំក៏ឈប់រៀន។ កាលនោះ ខ្ញុំរស់នៅជាមួយអ៊ំ ព្រោះឪពុកម្តាយ និងប្អូនស្រីរបស់ខ្ញុំបានស្លាប់ដោយសារជំងឺ និងគ្មានថ្នាំព្យាបាលតាំងពីសម័យសង្គមរាស្ត្រនិយម។

ចូលមកដល់របបខ្មែរក្រហម ខ្មែរក្រហមបានចាត់តាំង និងបង្ខំខ្ញុំឲ្យចូលធ្វើការងារក្នុងកងចល័ត និងត្រូវជីកដី លើកទំនប់យកទឹកធ្វើស្រែប្រាំងគ្មានពេលសម្រាកឡើយ ចំណែកការហូបចុកគឺមិនបានគ្រប់គ្រាន់ឡើយ។ ខ្មែរក្រហមបានចែកអង្ករមួយកំប៉ុងឲ្យប្រជាជនហូបរួមគ្នាជាច្រើននាក់ ដូច្នេះចុងភៅបានយកអង្ករទៅបបរលាយជាមួយគល់ចេក និងគល់ល្ហុង។ ខ្ញុំរស់នៅពិបាកខ្លាំងណាស់។ លើសពីនេះ ខ្មែរក្រហមបានបែងចែកការងារឲ្យប្រជាជនធ្វើទៅតាមក្រុម មានដូចជា ក្រុមកុមារ ក្រុមយុវជន ក្រុមមនុស្សចាស់ជាដើម ដោយក្នុងក្រុមនីមួយៗមិនបានកំណត់ចំនួនមនុស្សឡើយ។ ខ្មែរក្រហមបានបែងចែកក្រុមទាំងនោះឲ្យទៅធ្វើការងារនៅទំនប់ប៉ាក់ ដែលមានទីតាំងស្ថិតនៅភូមិស្រែជិះ។ សមាជិកគ្រួសារនីមួយៗត្រូវរស់នៅបែកពីគ្នា ព្រោះខ្មែរក្រហមចល័តអ្នកទាំងនោះឲ្យទៅធ្វើការនៅកន្លែងផ្សេងៗគ្នា។

ខ្មែរក្រហមក៏ជម្លៀសប្រជាជនថ្មីមកពីខេត្ត និងតំបន់ផ្សេងៗចម្រុះគ្នា រួមមានជនជាតិខ្មែរ ជនជាតិដើមភាគតិចចាម ឲ្យមករស់នៅក្នុងខេត្តក្រចេះដែរៗ ខ្មែរក្រហមបានបែងចែកប្រជាជនថ្មីទាំងនោះទៅតាមចំនួនគ្រួសារ គឺពី២០ ទៅ ៣០គ្រួសារឲ្យរស់នៅតំបន់ឬភូមិតូចៗ និង ពី៤០ ទៅ ៥០គ្រួសារឲ្យរស់នៅតំបន់ឬភូមិដែលមានទំហំធំៗ ប្រជាជនថ្មីទាំងនោះត្រូវធ្វើដំណើរដោយថ្មើរជើង និងជិះកាណូតៗ ក្រោយពេលប្រជាជនថ្មីមករស់នៅក្នុងភូមិចន្លូប ខ្ញុំសង្កេតឃើញថាប្រជាជនចាស់ និងប្រជាជនថ្មីទាំងនោះ មានទំនាក់ទំនងគ្នាល្អ ហើយពឹងពាក់គ្នាទៅវិញទៅមកៗ

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ នៅដើមឆ្នាំ១៩៧៩ ប្រជាជនក្នុងភូមិចន្លូបខ្លះបានបាត់ខ្លួនដោយសារចូលបម្រើកងទ័ពខ្មែរក្រហម ហើយប្រជាជនខ្លះទៀតបានស្លាប់លើសមរភូមិៗ ចំណែកប្រជាជនថ្មី ឬ ប្រជាជន១៧ មេសា ដែលខ្មែរក្រហមជម្លៀសមកកាន់ភូមិចន្លូប ក៏ធ្វើដំណើរវិលត្រឡប់ទៅស្រុកកំណើតរបស់ខ្លួនវិញៗ ទោះជាយ៉ាងណា មកដល់សព្វថ្ងៃក៏មានប្រជាជនថ្មីមួយចំនួន បានត្រឡប់មកលេងភូមិចន្លូបដែរៗ បច្ចុប្បន្ន ខ្ញុំរស់នៅជុំប្រពន្ធកូន ប៉ុន្តែខ្ញុំមានជំងឺប្រចាំកាយ ដូចជា ឈឺចង្កេះ ឈឺខ្នង និងឈឺតាមសរសៃជាដើម ដែលបណ្តាលមកពីធ្វើការងារធ្ងន់ធ្ងរ ហួសកម្លាំង និងហូបមិនបានគ្រប់គ្រាន់ក្នុងរបបខ្មែរក្រហមៗ



វាលស្រែក្នុងរដូវប្រាំង នៅក្នុងភូមិចន្លូប
ឃុំក្បាលដំរី ស្រុកអូរគ្រៀងសែនជ័យ ខេត្តក្រចេះៗ
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# គីម ហឿន ជនជាតិដើមភាគតិចមិល នៅក្នុងភូមិចង្ហួប

ឌិន សុខ ណេង



គីម ហឿន អាយុ៦៥ឆ្នាំ គឺជាជនជាតិដើមភាគតិចមិល សព្វថ្ងៃរស់នៅភូមិចង្ហួប ឃុំក្បាលដំរី ស្រុកអូរគ្រៀងសែនជ័យ ខេត្តក្រចេះ។ (វង្ស ស្រីឃីម/មជ្ឈមណ្ឌលឯកសារកម្ពុជា)

គីម ហឿន អាយុ៦៥ឆ្នាំ គឺជាជនជាតិដើមភាគតិចមិល សព្វថ្ងៃរស់នៅភូមិចង្ហួប ឃុំក្បាលដំរី ស្រុកអូរគ្រៀងសែនជ័យ ខេត្តក្រចេះ បានរៀបរាប់ថា ខ្ញុំមានបងប្អូន៤នាក់ គឺស្រី៣នាក់ និងប្រុស១នាក់។ នៅពេលខ្មែរក្រហមឡើងគ្រប់គ្រងប្រទេស ខ្ញុំមានអាយុ១៦ឆ្នាំ ត្រូវបានខ្មែរក្រហមប្រើឲ្យទៅលើកទំនប់នៅភ្នំស្រួច។ ខ្មែរក្រហមតម្រូវឲ្យខ្ញុំលើកទំនប់ក្នុងមួយថ្ងៃឲ្យបាន២ទៅ៣ម៉ែត្រគុបជាកំហិត។ នៅសម័យនោះ ខ្ញុំប្រើប្រាស់តែចប និង បង្គីដើម្បីរែកដី ប៉ុន្តែប្រសិនបើខ្ញុំរែកមិនគ្រប់តាមផែនការកំណត់ទេ ខ្មែរក្រហមនឹងធ្វើមីទ្ទីញ (ប្រជុំក្រុម) ឬយកទៅកសាង។ ខ្ញុំឈប់សម្រាកពីធ្វើការងារនៅម៉ោង១១ព្រឹករួចហើយទៅ ហូបបាយដែលចុងភៅចែកឲ្យម្នាក់មួយចាន ជាមួយសម្លស្លឹកដំឡូង ប៉ុន្តែខ្ញុំហូបមិនឆ្អែតទេ។ ខ្ញុំហូបដើម្បីតែរស់មានជីវិតធ្វើការឲ្យខ្មែរក្រហមប៉ុណ្ណោះ។ នៅវេលាម៉ោង១រសៀល ខ្ញុំចាប់ផ្តើមចូលធ្វើការបន្ត។

នៅក្នុងភូមិចង្ហួប ខ្មែរក្រហមបានបែងចែកប្រជាជនឲ្យធ្វើការងារជា៤ក្រុម ដែលក្រុមនីមួយៗមានសមាជិកច្រើននាក់ណាស់ ក្នុងនោះមានប្រជាជនជម្លៀសមកពីភ្នំពេញ និងតំបន់ផ្សេងៗលាយចម្រុះគ្នារួមមាន ជាតិភាគតិចចិន ជនជាតិភាគតិចចាម និងជនជាតិខ្មែរ។ ខ្មែរក្រហមជម្លៀសប្រជាជនទាំងនោះមកភូមិចង្ហួប ដោយដឹកជញ្ជូនតាមរថយន្ត។ ខ្ញុំបាន

ហៅប្រជាជនដែលខ្មែរក្រហមជម្លៀសមកពីភ្នំពេញថា ប្រជាជន១៧ មេសា។ ខ្មែរក្រហមបានចាត់តាំងប្រជាជន ១៧ មេសា ឲ្យទៅធ្វើស្រែ ប៉ុន្តែប្រជាជនទាំងនោះមិនប្រសប់ធ្វើការងារឡើយ និងមានការរអ៊ូរទាំច្រើន ព្រោះមិនធ្លាប់ធ្វើការលំបាកៗពីមុនមក។ ប្រជាជន១៧ មេសា ស្លាប់ច្រើនណាស់ ហើយភាគច្រើនជនជាតិភាគតិចចិន។ ទោះបីយ៉ាងណាប្រជាជន ១៧ មេសា ទាំងនោះគឺជាមនុស្សល្អ។ ខ្ញុំធ្លាប់ធ្វើការលើកទំនប់នៅភ្នំស្រួចជាមួយ ប្រជាជន ១៧ មេសា ហើយយើងហូបបាយជុំគ្នា។ ខ្ញុំបានត្រឹមស្គាល់ជនជាតិភាគតិចចិនប៉ុណ្ណោះ ដោយយើងនិយាយភាសាខ្មែរដើម្បីឆ្លងឆ្លើយគ្នា ប៉ុន្តែនៅពេលប្រជាជន១៧ មេសាទាំងនោះនិយាយជាមួយសមាជិកគ្រួសាររបស់ខ្លួន ទើបនិយាយភាសាចិន។ នៅក្នុងភូមិចង្ហប មានប្រជាជន ១៧ មេសា ស្លាប់ច្រើន ដោយសារជំងឺ និងហូបមិនឆ្អែត។

រឿងដែលខ្ញុំនៅចងចាំមិនអាចបំភ្លេចបាន គឺខ្មែរក្រហមបានប្រើខ្ញុំឲ្យធ្វើការងារធ្ងន់ គ្មានពេលសម្រាក និងមិនមានអាហារហូបគ្រប់គ្រាន់។ មកដល់សព្វថ្ងៃ ខ្ញុំរស់នៅជាមួយប្អូនស្រីខ្ញុំ ហើយខ្ញុំក៏មានជំងឺប្រចាំកាយ ដូចជា ឈឺចង្កេះ ឈឺជង្គង់ រលាកក្រពះ និងពោះវៀន។



ទីតាំងកប់សពរបស់ជនជាតិដើមភាគតិចមិល នៅក្នុងភូមិចង្ហប ឃុំក្បាលដំរី ស្រុកអូរត្រៀងសែនជ័យ ខេត្តក្រចេះ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ផៃ ខេន ៖ ប្រធានកងតូចនៅភូមិជ្រៃ

ឡុង ដានី



ផៃ ខេន អាយុ៨៨ឆ្នាំ សព្វថ្ងៃរស់នៅភូមិជ្រៃ ឃុំត្រមូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ផៃ ខេន អាយុ៨៨ឆ្នាំ មានស្រុកកំណើតនៅភូមិទំព័រ ឃុំត្រមូង ស្រុកមេមត់ ខេត្តកំពង់ចាម។ បច្ចុប្បន្នខ្ញុំរស់នៅភូមិជ្រៃ ឃុំត្រមូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ខ្ញុំមានឪពុកឈ្មោះ សៀវ ផៃ និងម្តាយឈ្មោះ កែ ទៀក។ ឪពុកម្តាយខ្ញុំស្លាប់ក្នុងរបបខ្មែរក្រហមអស់ហើយ។ ខ្ញុំមានប្រពន្ធឈ្មោះ ក្រូច ហ៊ាង និងមានកូនចំនួន៦នាក់។ កូនរបស់ខ្ញុំស្លាប់៣នាក់ និងនៅរស់៣នាក់។

កាលពីក្មេងខ្ញុំចូលរៀនជាមួយព្រះសង្ឃនៅវត្ត ព្រោះចង់បួសនៅវត្តកន្ទួត ដើម្បីបានរៀនសូត្របន្តទៀត។ ខ្ញុំរៀននៅវត្តកន្ទួតរយៈពេល៣ឆ្នាំ គឺរៀនភាសាបាលី លេខ អក្សរ ហើយនៅក្នុងការសិក្សាចែកពេលវេលាផ្សេងៗពីគ្នា។ ពេលព្រឹក ខ្ញុំរៀនអក្សរ ចំណែកពេលយប់ខ្ញុំរៀនធម៌វិន័យ និងភាសាបាលី។ ពេលខ្ញុំអាយុ២០ឆ្នាំ ខ្ញុំចូលប្រឡងអក្ខរកម្មនៅស្រុកមេមត់ ដែលមានមនុស្សចូលរួមប្រឡងចំនួន២៥នាក់ ហើយអ្នកប្រឡងជាប់មានចំនួន៣នាក់ រួមទាំងខ្ញុំម្នាក់ផងដែរ។ ពេលខ្ញុំអាយុ២៥ឆ្នាំ ខ្ញុំរៀបការប្រពន្ធ និងប្រកបរបរធ្វើចម្ការ ដាំស្រូវ ពោត ប៉ុន្តែដាំមិនបានផលទេ ព្រោះសត្វជ្រូកព្រៃទាំងហ្វូងមកកាស់ស៊ីគ្មានសល់ឡើយ។

ក្រោយពេល លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧០ ប្រជាជននៅក្នុងភូមិ ឃុំត្រមូង ធ្វើបាតុកម្មទាមទារសម្តេចព្រះ នរោត្តម សីហនុ ត្រឡប់មកកាន់អំណាចវិញ ព្រោះមិនពេញចិត្តចំពោះលោកសេនាប្រមុខ លន់ នល់។ ខ្ញុំស្ម័គ្រចិត្តទៅប្រមូលប្រជាជនតាមភូមិ និងឃុំមួយចំនួន ឡើងទៅធ្វើបាតុកម្មនៅភូមិខ្នងក្រពើ។ ខ្ញុំជិះឡាននិងមានមេក្រូប្រកាសតាមផ្លូវដើម្បីប្រមូលប្រជាជនទាំងអស់ឲ្យចូលរួមធ្វើបាតុកម្ម។ មួយរយៈក្រោយមក ស្រាប់តែទាហានអាមេរិកទម្លាក់គ្រាប់បែកសម្លាប់កងទ័ពវៀតកុងប៉ុវៀតណាមខាងជើង ដែលចូលមករស់នៅតាមព្រៃជាយៗភូមិ។ ប៉ុន្តែគ្រាប់មួយចំនួនចំភូមិ និងផ្ទះប្រជាជនបណ្តាលឲ្យមនុស្ស៤នាក់ស្លាប់ និងមនុស្ស៤នាក់ទៀតរងរបួស។ ប្រជាជនដែលបានស្លាប់មានឈ្មោះ តាស្តើង តាអ៊ុំ ម៉ែបងយ៉ាន និងឆ្ងួញ។ ពេលនោះខ្ញុំគឺជាមេភូមិជ្រៃ។ បន្ទាប់ពីប្រជាជនក្នុងភូមិរបស់ខ្ញុំស្លាប់ និងរងរបួស ខ្ញុំក៏សម្រេចចិត្តធ្វើដំណើរដោយថ្មើរជើងទៅបន្ទាយទាហានអាមេរិក ដែលមាន

ចម្ងាយប្រមាណ ៣គីឡូម៉ែត្រពីភូមិខ្ញុំ ដើម្បីស្នើសុំឲ្យឈប់ផ្លោងគ្រាប់និងទម្លាក់គ្រាប់មកលើភូមិដែលមានប្រជាជនរស់នៅទៀត។ ពេលដល់បន្ទាយទាហានអាមេរិក ស្រាប់តែទាហានមកភ្ជង់ខ្ញុំ ធ្វើឲ្យខ្ញុំភិតភ័យយ៉ាងខ្លាំង។ ប្រហែល១០នាទីក្រោយ ក៏មានអ្នកបកប្រែភាសាគឺដែលជាខ្មែរកម្ពុជាក្រោមមកដល់ ទើបយើងស្ដាប់គ្នាយល់។ ខ្ញុំបានជម្រាបទៅទាហានអាមេរិកថា សុំស្នើឈប់ទម្លាក់ និងផ្លោងគ្រាប់មកលើភូមិខ្ញុំទៀត ព្រោះមានមនុស្សស្លាប់ រងរបួស និងខូចខាតទ្រព្យសម្បត្តិផ្ទះសម្បែងច្រើន»។

រហូតមកដល់ឆ្នាំ១៩៧៥ ប្រជាជននៅភូមិជ្រៃនាំគ្នាធ្វើការងារប្រវាស់ដៃ បន្ទាប់មកខ្មែរក្រហមក៏បង្កើតជាសហករណ៍ដោយប្រមូលទ្រព្យសម្បត្តិប្រជាជនទាំងអស់ដាក់រួម។ ពេលនោះខ្មែរក្រហមជម្លៀសប្រជាជនពីភ្នំពេញប្រមាណ៣០គ្រួសារមកដាក់ក្នុងភូមិជ្រៃ ដើម្បីបង្កបង្កើតផល។ នៅឆ្នាំ១៩៧៦ ប្រជាជនមកពីភ្នំពេញទាំងអស់ត្រូវបានជម្លៀសចេញពីភូមិជ្រៃឲ្យទៅបង្កបង្កើនផលនៅកន្លែងផ្សេងៗ។

នៅក្នុងរបបខ្មែរក្រហម ខ្ញុំក៏បានចូលរួមអបអរនិងជាសាក្សីក្នុងពិធីមង្គលការរបស់ប្រជាជននៅឃុំត្រមូង ស្រុកត្រមូង ដែរ ព្រោះខ្ញុំគឺជាប្រធានកងតូច។ ពេលនោះ មានប្ដីប្រពន្ធចំនួន២០គូ ត្រូវឡើងប្ដេជ្ញាដើម្បីបញ្ជាក់ពីភាពស្មោះត្រង់ជាមួយអង្គការ និងរួមរស់ជាមួយគ្នារហូតដល់ថ្ងៃស្លាប់។ កម្មវិធីនេះធ្វើពេញមួយថ្ងៃដោយមានកាប់គោមួយក្បាល ធ្វើម្ហូបហូបចុករួមគ្នា។ ក្រោយចប់កម្មវិធីយើងនាំគ្នាត្រឡប់មកសហករណ៍រៀងៗខ្លួន។

នៅឆ្នាំ១៩៧៧ យោធាខ្មែរក្រហម និងកងទ័ពវៀតណាមប៉ះទង្គិចគ្នារាល់ថ្ងៃតាមព្រំដែន ដូច្នេះខ្មែរក្រហមក៏ជម្លៀសប្រជាជនចេញពីភូមិជ្រៃឲ្យទៅរស់នៅស្រុកស្នួល ខេត្តក្រចេះ។ គ្រួសារខ្ញុំត្រូវបានខ្មែរក្រហមឲ្យទៅរស់នៅក្នុងភូមិសំពោច ឃុំឃ្សឹម ស្រុកស្នួល ខេត្តក្រចេះ។ ប្រធានកងតូចនៅភូមិសំពោច ចាត់តាំងខ្ញុំឲ្យធ្វើជាប្រធានមើលការខុសត្រូវគោ ក្របី និងជ្រូក។ ខ្ញុំមិនសូវហត់ទេ ព្រោះខ្ញុំគឺជាអ្នកគ្រប់គ្រង។ ពេលល្ងាច បន្ទាប់ពីសមាជិកកងកៀងសត្វចូលក្រោល ខ្ញុំត្រូវត្រួតពិនិត្យ និងរាប់ចំនួនសត្វ ចៀសវាងបាត់គោ ក្របី និងជ្រូកនៅក្នុងទ្រុង។ ខ្ញុំប្រយ័ត្នប្រយែងណាស់ ប៉ុន្តែថ្ងៃមួយបាត់ជ្រូកចំនួនពីរក្បាល មិនដឹងថានរណាចាប់ឡើយ។ ប្រធានកងតូចហៅខ្ញុំទៅអប់រំ និងណែនាំ ចំណែកខ្ញុំបាននិយាយតាមដំណើររឿងពេលដែលបាត់ជ្រូក។ ប្រធានកងតូចបញ្ជាខ្ញុំឲ្យតាមស៊ើបអ្នកដែលលួចជ្រូក ហើយប្រសិនបើចាប់បាន គឺត្រូវយកទៅសម្លាប់ចោលក្នុងចំណោមមនុស្សជាច្រើនដើម្បីបង្ហាញពីអំពើក្បត់ជាមួយអង្គការ ប៉ុន្តែខ្ញុំរកមិនឃើញឡើយ។

នៅភូមិសំពោចឃុំឃ្សឹម ខ្ញុំមិនមានបាយហូបឆ្អែតទេ។ ចំណែកប្រពន្ធទីមួយខ្ញុំឈ្មោះ វន ទើបសម្រាលកូនបានមួយឆ្នាំ បានធ្វើការងារស្ទូង ដកសំណាប ហើយមិនមានអាហារហូបចុកគ្រប់គ្រាន់បណ្ដាលឲ្យធ្លាក់ខ្លួនឈឺ និងមានរាងកាយស្គមស្គាំង។ ប្រពន្ធរបស់ខ្ញុំមិនមានទឹកទឹកដោះឲ្យកូនបៅឡើយ ហើយក្រោយមកកូនរបស់ខ្ញុំដែលមានអាយុ១ឆ្នាំក៏ស្លាប់។ ចំណែកកូនច្បងខ្ញុំឈ្មោះ ញ៉ា ភេទប្រុស អាយុ១៥ឆ្នាំ គឺជាពេទ្យនៅក្នុងអង្គភាពកងទ័ពខ្មែរក្រហម។

នៅអំឡុងឆ្នាំ១៩៧៨ ពេលមានការប្រយុទ្ធគ្នារវាងយោធាខ្មែរក្រហម និងកងទ័ពវៀតណាម នៅឃុំស្រែរនាម ស្រុកស្នួល ពេលនោះខ្មែរក្រហមចាត់តាំងខ្ញុំឲ្យសែងអ្នករបួសទៅព្យាបាលនៅមន្ទីរពេទ្យស្ថិតនៅឃុំស្វាយជ្រះ។ ពេលនោះកូនប្រុសខ្ញុំម្នាក់ទៀតដែលធ្វើពេទ្យក៏បានស្លាប់នៅឃុំស្រែរនាម ស្រុកស្នួល អំឡុងពេលវាយប្រយុទ្ធគ្នា។ ខ្ញុំមិនបានឃើញមុខកូនទេ គឺបានទទួលដំណឹងពីសមាជិកនៅអង្គភាពទ័ព។ ក្រោយមក ខ្មែរក្រហមជម្លៀសខ្ញុំទៅស្នាក់នៅក្រុងក្រចេះចំនួន៣ថ្ងៃ រួចបន្តដំណើរទៅថ្មក្រែ រង់ចាំកប៉ាល់ឆ្លងទន្លេទៅស្រុកស្ទឹងត្រង់។ បន្ទាប់មក ខ្ញុំទៅរស់នៅស្រុកចំការលើ ខេត្តកំពង់ចាម រហូតដល់របបខ្មែរក្រហមដួលរលំ ទើបត្រឡប់មកស្រុកកំណើតវិញ។

# ជួប ធៀង ៖ នារីពេទ្យឃុំ

ឡាំ ស្រីនិត



ជួប ធៀង ភេទស្រី អាយុ៦៨ឆ្នាំ បច្ចុប្បន្នរស់នៅភូមិក្រពើពីរលើ ឃុំក្រពើពីរ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ជួប ធៀង ភេទស្រី អាយុ៦៨ឆ្នាំ ប្រកបមុខរបរ ដាំពោត និង ដំឡូង។ ខ្ញុំមានស្រុកកំណើតនៅភូមិចំបក់ ឃុំសំរោង ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ។ បច្ចុប្បន្នខ្ញុំរស់នៅភូមិក្រពើពីរលើ ឃុំក្រពើពីរ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ខ្ញុំមានឪពុកឈ្មោះ ជួប (ស្លាប់) និងម្តាយឈ្មោះ អ៊ុយ (ស្លាប់)។ ខ្ញុំមានបងប្អូនចំនួន៤នាក់ គឺស្រី២នាក់ និងប្រុស២នាក់។ សព្វថ្ងៃបងប្អូនខ្ញុំរស់នៅខេត្តកំពង់ស្ពឺទាំងអស់។ ខ្ញុំមានប្តីឈ្មោះ ប៉ិច ទូច អាយុ៦៥ឆ្នាំ។ ក្រោយពេលរៀបការ ខ្ញុំមានកូនចំនួន៤នាក់ ក្នុងនោះគឺស្រីម្នាក់ និងកូនប្រុសចំនួន៣នាក់។

កាលពីកុមារភាព ខ្ញុំមិនបានចូលរៀនសូត្រដូចកុមារដទៃទេ។ ខ្ញុំត្រូវរស់នៅជាមួយពូ ព្រោះម្តាយឪពុកខ្ញុំបានស្លាប់ដោយសារជំងឺតាំងខ្ញុំមិនទាន់ដឹងក្តី។ មកដល់ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ពេលរដ្ឋប្រហារទម្លាក់សម្តេច នរោត្តម សីហនុ ខ្ញុំរស់នៅជាមួយពូក្នុងភូមិដដែល។ ពេលនោះស្រាប់តែមានការទម្លាក់គ្រាប់បែកលើភូមិរបស់ខ្ញុំជាច្រើនថ្ងៃ ហើយខ្ញុំនិងបងប្អូននាំគ្នារត់ចូលលាក់ខ្លួនត្រង់សេ (លេណដ្ឋាន) ក្បែរផ្ទះ។ ការទម្លាក់គ្រាប់បែកធ្វើឲ្យមានការខូចខាតទ្រព្យសម្បត្តិ និងស្លាប់អ្នកភូមិ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមឡើងកាន់អំណាចទាំងស្រុង។ ខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យចូលធ្វើជាពេទ្យព្យាបាលប្រជាជនដែលឈឺនៅឃុំ ប៉ុន្តែខ្ញុំមិនចេះអក្សរទេ។ ខ្ញុំចូលធ្វើការចាប់ពីម៉ោង៧ព្រឹក រហូតដល់ម៉ោង១១ថ្ងៃត្រង់ ទើបឈប់សម្រាកហូបបាយ។ ខ្ញុំចូលធ្វើការវិញនៅម៉ោង១រសៀល រហូតដល់ម៉ោង៥ល្ងាចទើបឈប់សម្រាក។ ចំណែករបបអាហារខ្ញុំបានហូបចុកគ្រប់គ្រាន់។ សម័យនោះ បងប្អូនរបស់ខ្ញុំផ្សេងទៀត ត្រូវបានខ្មែរក្រហមចាត់តាំងឲ្យចូលធ្វើកងទ័ព។

ចន្លោះពីឆ្នាំ១៩៧៦ដល់ឆ្នាំ១៩៧៨ ខ្មែរក្រហមមិនបានជម្លៀសខ្ញុំចេញទៅតំបន់ផ្សេងទេ គឺឲ្យនៅធ្វើជាពេទ្យនៅក្នុងភូមិឃុំដដែល។ ខ្មែរក្រហមមិនដែលប្រើខ្ញុំឲ្យធ្វើការហួសកម្លាំង ឬលើកសែងឡើយ។ ខ្ញុំនៅចាំព្យាបាលអ្នកជំងឺនៅឃុំសំរោង ហើយមានពេលខ្លះប្រធានអង្គភាពរបស់ខ្ញុំបានយកខ្ញុំទៅធ្វើការជាមួយគាត់នៅតំបន់ឆ្ងាយៗ។

នៅដើមឆ្នាំ១៩៧៩ ពេលកងទ័ពវៀតណាមចូលមករំដោះប្រទេសកម្ពុជាឲ្យរួចផុតពីរបប ប៉ុល ពត ខ្ញុំបានរត់ឡើងភ្នំឱរ៉ាល់ជាមួយប្រជាជននៅឃុំសំរោង។ ខ្ញុំរត់គេចពីកងទ័ពវៀតណាមដោយសារព្រការឃោសនាថា កងទ័ពវៀតណាមនឹងចាប់ខ្ញុំយកទៅធ្វើបាប។ ខ្ញុំរស់នៅលើភ្នំអស់រយៈពេលប្រមាណជាង៣ឆ្នាំ។ ខ្ញុំមិនមានអាហារហូបចុកគ្រប់គ្រាន់ទេ គឺត្រូវដើរជីកដំឡូង មើមក្តួចយកមកហូបចម្អែតក្រពះ។ នៅឆ្នាំ១៩៨២ ទើបខ្ញុំទៅរស់នៅព្រំដែនថៃ ហើយខ្ញុំក៏រៀបការជាមួយនឹងប្តីរបស់ខ្ញុំនៅក្នុងឆ្នាំ១៩៨៨ នៅក្នុងទឹកដីថៃ។ នៅឆ្នាំ១៩៩៣ ទើបខ្ញុំនិងប្តីបាននាំគ្នាមករស់នៅ និងប្រកបរបរធ្វើស្រែចម្ការនៅក្នុងភូមិក្រពើពីរវិញ។

# តឿ ឃ្លីម ៖ ជនជាតិដើមភាគតិចមិល នៅភូមិចង្ហូប

**វង្ស ស្រីយីម**



តឿ ឃ្លីម អាយុ៦៣ឆ្នាំ គឺជាជនជាតិភាគតិចមិល សព្វថ្ងៃរស់នៅភូមិចង្ហូប ឃុំក្បាលដំរី ស្រុកអូរគ្រៀងសែនជ័យ ខេត្តក្រចេះ។ (វង្ស ស្រីយីម/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ តឿ ឃ្លីម ភេទប្រុស មានអាយុ ៦៣ឆ្នាំ គឺជាជនជាតិភាគតិចមិល សព្វថ្ងៃរស់នៅភូមិចង្ហូប ឃុំក្បាលដំរី ស្រុកអូរគ្រៀងសែនជ័យ ខេត្តក្រចេះ។ ខ្ញុំមានបងប្អូន៥នាក់ គឺស្រី៣នាក់ និងប្រុស២នាក់។

ពេលខ្មែរក្រហមចូលមកដល់ភូមិចង្ហូប ខ្ញុំទើបមានអាយុ១៨ឆ្នាំប៉ុណ្ណោះ។ ខ្មែរក្រហមបានបែងចែកប្រជាជនក្នុងភូមិឲ្យរស់នៅជាសហករណ៍ ដោយក្នុងមួយសហករណ៍មានប្រជាជនប្រមាណ១០ ទៅ២០គ្រួសារ។ ខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឲ្យរើសអាចម៍គោ កាប់ផ្ការព្រៃតាមវាលស្រែចម្ការ និងលើកទំនប់នៅស្រែចង្ហូប។ ទំនប់ស្រែចង្ហូបមានប្រវែងប្រមាណ៥០០ម៉ែត្រ ហើយសំបូរត្រីណាស់ និងមិនខ្វះទឹកបញ្ចូលស្រែនោះទេ។ មានប្រជាជនច្រើនណាស់ មកលើកទំនប់នៅស្រែចង្ហូប កាលជំនាន់នោះ ហើយមិនមែនមានតែប្រជាជនដែលរស់នៅភូមិចង្ហូបនោះទេ គឺមានប្រជាជន ១៧ មេសា មកពីស្រុកត្រមូង, មកពីភ្នំពេញ រួមមាន ជនជាតិដើមភាគតិចចិន ជនជាតិដើមភាគតិចចាម បុបងប្អូនខ្មែរអ៊ិស្លាម និងប្រជាជនដែលមកពីតំបន់ផ្សេងៗទៀត។ ពេលនោះប្រធានកងខ្មែរក្រហមបានប្រើខ្ញុំឲ្យលើកទំនប់ទាំងយប់ទាំងថ្ងៃ ដោយគ្មានពេលសម្រាកគ្រប់គ្រាន់នោះទេ គឺខ្ញុំចូលធ្វើការតាំងពីព្រឹកព្រលឹម រហូតដល់ម៉ោង១១ ទើបសម្រាកហូបបាយថ្ងៃត្រង់ ហើយម៉ោង ១រសៀល ខ្ញុំចាប់ផ្តើមចូលធ្វើការងារបន្តរហូតដល់ម៉ោង១០ ទៅ ១១យប់ ទើបបានសម្រាកហូបបាយ។ ខ្ញុំនិងកងចល័តលើកទំនប់ទាំងអស់មិនហ៊ានប្រកែកតវ៉ាជាមួយមេកងខ្មែរក្រហមឡើយ ព្រោះខ្លាចមេកងយកទៅរៀនសូត្រ។ ប្រជាជនណាដែលខ្មែរក្រហមយកទៅរៀនសូត្រ ហើយពិសេសអ្នកដែលមានសប្បុរស ដូចជា ជនជាតិភាគតិចចិន ដឹងតែបាត់ខ្លួន និងមិនដែលឃើញត្រឡប់មកវិញទេ គឺមានន័យថាខ្មែរក្រហមយកទៅសម្លាប់ចោលហើយ។ ដោយសារខ្ញុំ និងកងចល័តទាំងអស់ខិតខំប្រឹងប្រែងធ្វើការតាមការបង្គាប់បញ្ជាពីមេកងខ្មែរក្រហម ទើបបណ្តាលឲ្យមានអ្នកស្លាប់ច្រើនភាគច្រើននៃអ្នកស្លាប់ គឺជាប្រជាជន ១៧ មេសា។

បន្ទាប់មកទៀត ខ្ញុំត្រូវបានបញ្ជូនទៅបម្រើកងទ័ពខ្មែរក្រហម និងឈរជើងនៅសមរភូមិផ្សេងៗ ទើបខ្ញុំបានហូបគ្រប់គ្រាន់ មានបាយ និងសម្លម្ជូរត្រី ហើយពេលខ្លះក៏មានសាច់ដែរ។ ខ្ញុំត្រូវឡើងទៅវាយនៅសមរភូមិជួរមុខ ហើយត្រូវគ្រាប់កាំភ្លើងចំម្រាមដៃនាងខាងស្តាំ និងចំលើជើង និងខ្លួនប្រាណរបស់ខ្ញុំជាច្រើនកន្លែងទៀត ដោយសារអំបែងគ្រាប់ខ្ទាតមកចំៗ អំបែងគ្រាប់ទាំងនេះ មិនត្រូវបានយកចេញទេ គឺនៅក្នុងជើង និងខ្លួនប្រាណរបស់ខ្ញុំ។

ថ្វីបើរបបខ្មែរក្រហមត្រូវបានបញ្ចប់ទៅពិតមែន ប៉ុន្តែរបបមួយនេះបានធ្វើបាបប្រជាជន និងបន្សល់ទុករឿងរ៉ាវឈឺចាប់ស្លាកស្នាម និងរបួសនៅលើខ្លួនប្រាណមកទល់សព្វថ្ងៃ។

# យឹម សាវ ៖ អតីតកងទ័ពខ្មែរក្រហម

ចាន់ ណារិទ្ធ



យឹម សាវ អាយុ៧៤ឆ្នាំ កើតនៅភូមិស្រែក្រោ ឃុំធ្លកវៀន ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង។ បច្ចុប្បន្នរស់នៅភូមិក្រពើពីរលើ ឃុំក្រពើពីរ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ យឹម សាវ ភេទប្រុស អាយុ៧៤ឆ្នាំ សព្វថ្ងៃមានមុខរបរធ្វើចម្ការ។ ខ្ញុំមានស្រុកកំណើតនៅភូមិស្រែក្រោ ឃុំធ្លកវៀន ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង។ បច្ចុប្បន្នខ្ញុំរស់នៅភូមិក្រពើពីរលើ ឃុំក្រពើពីរ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ខ្ញុំមានឪពុកឈ្មោះយឹម សូត្រ (ស្លាប់) ចំណែកម្តាយឈ្មោះម៉ែន យឿន (ស្លាប់)។ ខ្ញុំមានបងប្អូន១១នាក់ គឺប្រុស៥នាក់ និង ស្រី៦នាក់។ ខ្ញុំគឺជាកូនទី១នៅក្នុងគ្រួសារ។ ខ្ញុំមានប្រពន្ធ៣នាក់គឺ ប្រពន្ធទី១) ឈ្មោះ យ៉ាន មានកូនចំនួន៥នាក់ (ប្រុស២នាក់និងស្រី៣នាក់) ប្រពន្ធទី២) ឈ្មោះ ញឹម ប៉ិច មានកូន២នាក់ និង ប្រពន្ធទី៣) ឈ្មោះ សួង ប៊ុនធឿន មានកូន៦នាក់ (ប្រុស៤នាក់ និង ស្រី២នាក់)។

ខ្ញុំបានចូលរៀននៅអាយុ១៥ឆ្នាំ។ ខ្ញុំរៀនបានត្រឹមថ្នាក់ទី៣ នៅសាលាដែលមានឈ្មោះថា សាលាបឹងខ្នារ។ គ្រូដែលបង្រៀនខ្ញុំឈ្មោះ គ្រូម៉ែន។ មូលហេតុដែលខ្ញុំឈប់រៀនមកពីគ្រួសារខ្ញុំមានជីវភាពខ្វះខាតខ្លាំងពេក។ បន្ទាប់ពីឈប់រៀន ខ្ញុំមកជួយឪពុកម្តាយដែលប្រកបមុខរបរធ្វើស្រែ និងឃ្វាលគោក្របី។ មួយរយៈក្រោយមក ឪពុកម្តាយខ្ញុំបានជំរុញខ្ញុំឲ្យទៅបួសនៅវត្តធ្លកវៀន។ ខ្ញុំបួសបានរយៈពេល៥វស្សា។

នៅក្នុងឆ្នាំ១៩៧០ ទាហាន លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេច សីហនុ ដែលពេលនោះខ្ញុំនៅបួសជាសង្ឃនៅឡើយ។ ខ្ញុំសឹកវិញនៅចុងឆ្នាំ១៩៧០ ព្រោះប្រទេសកំពុងតែមានសង្គ្រាម។ បន្ទាប់ពីសឹក ខ្ញុំនិងប្រជាជនក្នុងភូមិបានប្រមូលគ្នាឡើងទៅធ្វើបាតុកម្មនៅមុំសាលាលេខ៥ ដើម្បីទាមទារឲ្យសម្តេច សីហនុមកដឹកនាំប្រទេសវិញ។ ជាអកុសលប្រជាជនដែលឡើងទៅធ្វើបាតុកម្មភាគច្រើនត្រូវបានទាហាន លន់ នល់ បាញ់ឲ្យរងរបួស និងស្លាប់។ ប្រជាជនដែលឡើងមកធ្វើបាតុកម្មនៅសាលាលេខ៥ ភាគច្រើនសុទ្ធតែមកពីស្រុកកំពង់ត្រឡាច។ ពេលដែលទាហាន លន់ នល់ បាញ់សន្ធាប់មក ខ្ញុំបានរត់ចូលព្រៃលាក់ខ្លួន និងរត់ឡើងលើភ្នំជម្រាយ។ ខ្ញុំរស់នៅភ្នំជម្រាយបានរយៈពេល២ទៅ៣ខែ ទើបត្រឡប់មករស់នៅភូមិវិញ។

នៅក្នុងឆ្នាំ១៩៧២ កងទ័ពខ្មែរក្រហមដើរឃោសនាតាមភូមិ ដើម្បីឲ្យប្រជាជនងើបឡើងតស៊ូនិងប្រឆាំងទាហាន លន់ នល់។ ថ្នាក់ដឹកនាំដែលមកឃោសនាមានដូចជា តាវង្ស, តាគី, តាសារ៉ុន និង តានាង។ ក្នុងឆ្នាំ១៩៧២ដដែល ខ្ញុំបានចេញពីគ្រួសារមករស់នៅជាមួយតាវង្ស នៅភ្នំជម្រាយ ព្រោះនៅក្នុងភូមិទាហាន លន់ នល់ ដេញ

ចាប់ប្រជាជនខ្លាំងពេក។ ខ្ញុំរស់នៅភ្នំដម្រាយបានរយៈពេល១ឆ្នាំ។ នៅក្នុងឆ្នាំ១៩៧៣ គឺចាប់ផ្ដើមមានការទម្លាក់គ្រាប់បែកពីទាហាន លន់ នល់ មកលើបន្ទាយដែលខ្ញុំរស់នៅ ប៉ុន្តែមិនមានកងទ័ពណាម្នាក់រងរបួសឡើយ ព្រោះមានត្រង់សេសម្រាប់លាក់ខ្លួន។ ខ្ញុំនៅកងតំបន់ទី១ ដែលដកពីភ្នំដម្រាយ មកប្រចាំការនៅខេត្តកំពង់ឆ្នាំង ដែលថ្នាក់ដឹកនាំខ្ញុំឈ្មោះតាមុ ចំណែកមេកងពលឈ្មោះតាយីម។ នៅកងតំបន់ទី១ មានសមាជិកប្រហែល៣៦៨នាក់។ បន្ទាប់ពីមានការទម្លាក់គ្រាប់បែកហើយ ក៏ចាប់ផ្ដើមមានកងទ័ពវៀតណាមខាងជើង (វៀតកុង) និងវៀតណាមខាងត្បូង (ធីវគី) ចូលមកស្រុកភូមិដែលប្រជាជនរស់នៅ។ វៀតណាមខាងត្បូងចំណុះឲ្យអាមេរិក ចំណែកយួនខាងជើងចំណុះឲ្យខ្មែរក្រហម។ ពេលដែលវៀតណាមខាងត្បូង (ធីវគី) ចូលដល់ភូមិស្រុកប្រជាជនរស់នៅម្តងៗ តែងតែដើរប្រមូលសម្ភាររបស់របរយកទៅអស់ ចំណែកស្រីស្អាត គឺធីវគីចាប់ដាក់រថក្រោះយកទៅរំលោភនៅបន្ទាយ។

នៅក្នុងឆ្នាំ១៩៧៤ ថ្នាក់ដឹកនាំកងទ័ពរំដោះខ្មែរក្រហមចាប់ផ្ដើមចាត់តាំងយុវជនយុវនារីឲ្យដើរបំផុសបំផុលតាមភូមិម្តងទៀត ដើម្បីប្រមូលកម្លាំងមកតតាំងជាមួយទាហាន លន់ នល់។ ពេលខ្មែរក្រហមមានកម្លាំងច្រើនក៏ចាប់ផ្ដើមដឹកនាំវាយនៅលង្វែក ស្រែត្រាច សាលាលេខ៥ រហូតដល់ខេត្តកំពង់ឆ្នាំង។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងតំបន់ទី១របស់ខ្ញុំបានវាយចូលដល់ទីក្រុងភ្នំពេញ ពេលនោះកងខ្ញុំឈរជើងនៅតាំងក្រសាំង និងម្តុំបឹងកក់។ ប៉ុន្តែមិនបានឈរជើងស្រួលបួលផង ខ្មែរក្រហមក៏ចាប់ផ្ដើមជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ ប្រជាជនភាគច្រើនត្រូវបានជម្លៀសទៅភ្នំឱរ៉ាល់ កំពង់ចាម តាកែវ កំពង់ឆ្នាំង និង ពោធិ៍សាត់។ មូលហេតុដែលកងទ័ពខ្មែរក្រហមជម្លៀសប្រជាជនចេញ ព្រោះចង់បោសសម្អាតអ្នកដែលពាក់ពន្ធ័ជាមួយលោក លន់ នល់ ហើយម៉្យាងទៀត កុហកថា អាមេរិកនឹងមកទម្លាក់គ្រាប់បែកនៅទីក្រុងភ្នំពេញ។ ប្រជាជនណាដែលរឹងទទឹងមិនព្រមចាកចេញតាមការស្នើសុំរបស់កងទ័ពខ្មែរក្រហមទេ ខ្មែរក្រហមនឹងបាញ់សម្លាប់ ឬបោកគ្រាប់បែកសម្លាប់នៅក្នុងផ្ទះតែម្តង។

នៅឆ្នាំ១៩៧៦ កងតំបន់ទី១របស់ខ្ញុំបានដកចេញពីបឹងកក់ឲ្យមកគ្រប់គ្រងនៅខេត្តពោធិ៍សាត់វិញ ព្រោះមានចលនាខ្មែរសឈរជើងនៅស្រុកពាមព្រូស (ស្រុកវាលវែង)។ សម្រាប់អាហារហូបចុកពេលដែលខ្ញុំមករស់នៅខេត្តពោធិ៍សាត់ ខ្ញុំទទួលបានរបបបាយ ចំណែកប្រជាជនធម្មតាមានពេលខ្លះហូបបាយ ពេលខ្លះហូបបបរ។

រហូតមកដល់ឆ្នាំ១៩៧៧ ខ្មែរក្រហមចាប់ផ្ដើមសម្លាប់ប្រជាជនយ៉ាងច្រើនមកពីខាងបូព៌ា ដោយចោទប្រកាន់ថា ជាប់ទាក់ទងជាមួយ សោ ភឹម មេដឹកនាំនៅបូព៌ាដែលក្បត់។ ប្រជាជនដែលខ្មែរក្រហមជម្លៀសពីបូព៌ា ពិសេសខេត្តស្វាយរៀង គឺភាគច្រើនត្រូវបានដឹកតាមរថភ្លើងមកទម្លាក់នៅខេត្តពោធិ៍សាត់។ តំបន់ដែលខ្មែរក្រហមសម្លាប់ប្រជាជនមកពីខេត្តស្វាយរៀងច្រើនជាងគេ គឺនៅស្តុកប្រវឹក អូរតាប៉ោង ដំណាក់តារ៉ុន ត្រជាក់ចិត្ត និង តាមមាត់ស្ទឹងមោង។

នៅឆ្នាំ១៩៧៨ ខ្ញុំឈប់ពីកងទ័ពហើយមករស់នៅជាប្រជាជនធម្មតាវិញ។ ខ្ញុំធ្វើដំណើរត្រឡប់មករកគ្រួសារខ្ញុំវិញ ប៉ុន្តែពេលមកដល់ស្រុកកំណើត ក្រុមគ្រួសារខ្ញុំត្រូវបានខ្មែរក្រហមជម្លៀសទៅឆ្ងាយហើយ។ ពេលនោះ ខ្ញុំបន្តដំណើរមកខាងរមាសដើម្បីសួរដំណឹងគ្រួសាររបស់ខ្ញុំ។

នៅដើមឆ្នាំ១៩៧៩ ពេលដែលកងទ័ពវៀតណាមចូលរំដោះប្រទេសកម្ពុជាបានទាំងស្រុង ខ្ញុំរត់ចេញពីខេត្តកណ្ដាល មករស់នៅខេត្តកំពង់ឆ្នាំងវិញ។ ពេលនោះ ខ្ញុំបានរៀបការប្រពន្ធទី២ រួចក៏នាំគ្នាប្រកបមុខរបរធ្វើស្រែដើម្បីចិញ្ចឹមជីវិត។ ដោយការរស់នៅមិនចុះសម្រុងគ្នា ខ្ញុំក៏បានលែងលះប្រពន្ធទី២ រួចមកធ្វើការនៅស្រុកវាលវែង ខេត្តពោធិ៍សាត់។ ពេលមកដល់វាលវែងដំបូង ខ្ញុំដើរស៊ីឈ្នួលកាប់ពោត និងកាស់ដំឡូងឲ្យម្ចាស់ចម្ការ។ ខ្ញុំរស់នៅវាលវែងបានមួយរយៈ ក៏បានស្គាល់ប្រពន្ធក្រោយរបស់ខ្ញុំឈ្មោះ សួង ប៊ុនធឿន ហើយក៏ចាប់ដៃគ្នាប្រកបមុខរបរធ្វើស្រែចម្ការរហូតមកដល់សព្វថ្ងៃ។

# វ៉ាន់ ចូវ ៖ ប្រធានកងចល័តនៅឃុំត្រមូង

ឈុំ រ៉ា



វ៉ាន់ ចូវ អាយុ៧២ឆ្នាំ សព្វថ្ងៃរស់នៅក្នុងភូមិជ្រៃ ឃុំត្រមូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ វ៉ាន់ ចូវ អាយុ៧២ឆ្នាំ កើតនៅភូមិម៉ុំ (ភូមិជ្រៃ) ឃុំត្រមូង ស្រុកមេមត់ ខេត្តកំពង់ចាម។ បច្ចុប្បន្ន ខ្ញុំរស់នៅភូមិជ្រៃ ឃុំត្រមូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ខ្ញុំមានឪពុកឈ្មោះ វ៉ាន់ ស្លាប់សម័យ ប៉ុល ពត និងម្ដាយឈ្មោះ មើក តើល ស្លាប់តាំងពីខ្ញុំអាយុ២ឆ្នាំ។ ខ្ញុំមានបងប្អូនចំនួន៦នាក់ ហើយខ្ញុំគឺជាកូនទី២។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានចូលកាន់កាប់ទីក្រុងភ្នំពេញ និងបានជម្លៀសប្រជាជនចេញពីទីក្រុងឲ្យមករស់នៅតាមតំបន់ទីជនបទ។ ពេលនោះ ខ្មែរក្រហមក៏បានជម្លៀសប្រជាជនជាច្រើនគ្រួសារមកពីភ្នំពេញឲ្យមករស់នៅភូមិជ្រៃ ឃុំត្រមូង ស្រុកមេមត់ដែរ។ កាលសម័យខ្មែរក្រហម ឪពុកខ្ញុំធ្វើការនៅស្រុកត្រមូង ហើយឪពុករបស់ខ្ញុំក៏ជាមិត្តភក្តិជាមួយ ម៉ៃផូ គឺជាអ្នកគ្រប់គ្រងនៅស្រុកមេមត់ តំបន់២១ ដែរ។

ខ្ញុំត្រូវបានថ្នាក់លើចាត់តាំងឲ្យធ្វើជាប្រធានយុវជនជ្រើសរើសកងចល័តនៅក្នុងស្រុកត្រមូងតំបន់២១។ ខ្ញុំជ្រើសរើសកងចល័តនៅឃុំត្រមូងចំនួន៣០០នាក់ ទៅលើកទំនប់នៅបឹងក្រចាប់រយៈពេល៣ខែ។ ប្រជាជនមកពីស្រុកមេមត់ ស្រុកត្រមូងរាប់ពាន់នាក់ លើកទំនប់ដែលមានទទឹង៥០ម៉ែត្រ។ ប្រជាជនធ្វើការងាររែកដីលើសកម្លាំង និងមិនមានទឹកស្អាតផឹកគ្រប់គ្រាន់ឡើយ ដូច្នេះក៏នាំគ្នាផឹកទឹកប្រឡាយកខ្វក់បណ្ដាលឲ្យកើតជំងឺ ហើយពេលបត់ជើងតូចម្ដងៗមានឈាមលាយជាមួយទឹកនោម។ ប្រជាជនក្នុងកងចល័តរាករូសស្ទើរគ្រាប់គ្នា។ សម័យនោះ មិនមានគ្រូពេទ្យប្រចាំនៅបឹងក្រចាប់ទេ ដូច្នេះពេលប្រជាជនឈឺគ្រុនល្ហមៗមិនបានបញ្ជូនទៅពេទ្យទេ គឺទុកអ្នកជំងឺទាល់តែស្លាប់នៅកន្លែងធ្វើការក៏មាន។ ទោះបីយ៉ាងណា សមាជិកកងចល័តដែលខ្ញុំដឹកនាំ មិនមានអ្នកណាស្លាប់ឡើយ ព្រោះពេលអ្នកទាំងនោះឈឺគ្រុនម្ដងៗគឺខ្ញុំបញ្ជូនទៅព្យាបាលនៅពេទ្យព២ នៅស្រុកអូររាំងឪ ហើយអ្នកនៅក្នុងកងដែលបានទៅព្យាបាលជំងឺទាល់តែមានការអនុញ្ញាតពីខ្ញុំ។

ខ្ញុំដឹកនាំសមាជិកកងធ្វើការនៅបឹងក្រចាប់អស់រយៈពេល៣ខែ ទើបត្រឡប់មកស្រុកត្រមូងវិញ។ បន្ទាប់មក ថ្នាក់លើបានចាត់តាំងខ្ញុំដឹកនាំកងចល័តទៅច្រូតស្រូវនៅឃុំជាំក្រវៀន។ កាលនោះ ខ្ញុំជិះម៉ូតូសេអិល ហើយមានតែខ្ញុំម្នាក់ទេដែលមានម៉ូតូជិះ។ អំឡុងពេលច្រូតស្រូវ មានផ្ទុះអាវុធតាមព្រំដែនកម្ពុជា និងវៀតណាម គឺកងកម្លាំងខ្មែរក្រហមប្រយុទ្ធគ្នាជាមួយកងកម្លាំងវៀតណាម។ ពេល

នោះ មេបញ្ជាការឈ្មោះ តាសឿង នៅភូមិភាគបូព៌ា មិនឲ្យក្រុមកងចល័តរបស់ខ្ញុំធ្វើដំណើរទៅមុខទៀតទេ គឺឲ្យនៅក្នុងលេណដ្ឋានជាមួយកងទ័ពខ្មែរក្រហម។ ខ្ញុំបានបញ្ជូននីរសារ ឈ្មោះ ប៉ោត ឡូ រាយការណ៍ទៅថ្នាក់ស្រុកដើម្បីជម្លៀសកងចល័តចេញពីព្រំដែន និងដាក់កងទ័ពជំនួយវិញ។ នីរសាររបស់ខ្ញុំបានយកសំបុត្រទៅថ្នាក់ស្រុកបានរយៈពេលមួយថ្ងៃ ទើបខ្ញុំដឹកនាំកងចល័តត្រឡប់មកភូមិវិញ។ នៅពេលកងទ័ពមជ្ឈិមរបស់ខ្មែរក្រហមចូលមក ខ្ញុំបានផ្លាស់ប្តូរទៅគ្រប់គ្រងកងចល័តនៅឃុំត្រមូងវិញ។ ពេលនោះការគ្រប់គ្រងនៅស្រុកត្រមូង រួមមាន៖ ១) ប្រធានគឺជាអ្នកក្តោបក្តាប់រួម ២) អនុប្រធាន គ្រប់គ្រងផ្នែកសេដ្ឋកិច្ច ៣) សមាជិកទីមួយ ផ្នែកសន្តិសុខ ៤) សមាជិកទីពីរ ផ្នែកសង្គមកិច្ច, វប្បធម៌ និងសិល្បៈ ៥) សមាជិកទីបី គ្រប់គ្រងក្រសួងសុខាភិបាល។

ក្រោយមក ខ្មែរក្រហមចាប់ផ្តើមស៊ើបរកអ្នកក្បត់អង្គការ និងអ្នកធ្លាប់ធ្វើជាទាហានសម័យ លន់ នល់ គ្រូពេទ្យ គ្រូបង្រៀនបញ្ញវន្ត និងអ្នកធ្លាប់ធ្វើការក្នុងរបបចាស់។ ខ្មែរក្រហមចោទអ្នករស់នៅបូព៌ាគឺជាអ្នកចូលដៃជើងជាមួយវៀតណាម។ នៅពេលនោះ ខ្ញុំត្រូវបានបញ្ជូនឲ្យទៅមើលការខុសត្រូវប្រជាជននៅភូមិត្រពាំងផើ និងភូមិផើថ្មី ដែលនៅទីនោះមានមន្ទីរសន្តិសុខសម្រាប់ឃុំឃាំងអ្នកប្រព្រឹត្តខុសវិន័យអង្គការ។ ចំណែកមន្ទីរសន្តិសុខមួយកន្លែងទៀត នៅភូមិសំពៅលូន និងភូមិសំបូរ ឃុំដាំតាម៉ៅ។

ខ្ញុំរៀបការក្នុងសម័យខ្មែរក្រហម ជាមួយប្រពន្ធទីមួយឈ្មោះ ឃឹម សាប៊ុម នៅភូមិអណ្តូងញ្ជេរ ឃុំរូង ប៉ុន្តែការរៀបនោះមានតែខ្ញុំមួយគូប៉ុណ្ណោះ ព្រោះមុនការរៀបការរបស់ខ្ញុំមួយខែ ខ្ញុំបានបញ្ជូនឈ្មោះប្រជាជននៅឃុំត្រមូងទៅរៀបការរួចរាល់ហើយ។ ខ្ញុំគឺជាប្រធានកងចល័ត គឺថ្នាក់លើឲ្យខ្ញុំរៀបការតែមួយគូប៉ុណ្ណោះ។ បន្ទាប់ពីរៀបការបានមួយឆ្នាំ ខ្មែរក្រហមជម្លៀសខ្ញុំពីស្រុកកំណើតឲ្យទៅរស់នៅភូមិសំពោច ឃុំយ្សឹម ស្រុកស្ទួល ខេត្តក្រចេះ។ ពេលនោះ ខ្ញុំមានកូនស្រីម្នាក់ស្លាប់នៅភូមិសំពោចដោយសារជំងឺ។

ខ្ញុំត្រូវប្រធានតំបន់ឲ្យទៅដឹកស្រូវពីភូមិដែលមានជនជាតិព្នងរស់នៅ ហើយខ្ញុំត្រូវដេកនៅភូមិជនជាតិរយៈពេលពីរយប់។ ព្រឹកឡើង ខ្ញុំបររទេះដឹកស្រូវមកភូមិសំពោចវិញ ក៏ស្រាប់តែបាត់គ្រួសារខ្ញុំទាំងអស់ ព្រោះខ្មែរក្រហមជម្លៀសចេញទៅតំបន់ផ្សេង ដូច្នេះខ្ញុំមិនបានជួបប្រពន្ធទេ។ ប្រហែលមួយសប្តាហ៍ក្រោយមក ស្រាប់តែមានគ្រាប់បាញ់ពីលើយន្តហោះ ហើយនៅភូមិសំពោច ភូមិស្រែនាម ខ្ញុំឃើញមនុស្សស្លាប់តាមផ្លូវជាហូរហែ។ ខ្ញុំភៀសខ្លួនទៅស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម បន្ទាប់មកជិះឡានទៅខេត្តកំពង់ធំ។ ខ្ញុំជាមួយប្រធានកងតូចនៅវាស់វែងដីស្រែឲ្យប្រជាជនធ្វើនៅខេត្តកំពង់ធំ រហូតដល់ប្រទេសកម្ពុជាត្រូវបានរំដោះនៅដើមឆ្នាំ១៩៧៩ ទើបខ្ញុំត្រឡប់មកភូមិកំណើតវិញ។



វាលស្រែនៅឃុំត្រមូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ផ៉ាន់ ឆឹង ៖ អតីតពេទ្យ ប៣ តំបន់២១ ភូមិភាគបូព៌ា

ទី ស៊ីថា



*ផ៉ាន់ ឆឹង អាយុ៦៧ឆ្នាំ សព្វថ្ងៃរស់នៅក្នុងភូមិជ្រៃ ឃុំត្រមូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខ្ញុំឈ្មោះ ផ៉ាន់ ឆឹង អាយុ៦៧ឆ្នាំ កើតនៅក្នុងភូមិជ្រៃ ឃុំត្រមូង ស្រុកមេមត់ ខេត្តកំពង់ចាម។ បច្ចុប្បន្ន ខ្ញុំរស់នៅក្នុងភូមិជ្រៃ ឃុំត្រមូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ខ្ញុំមានឪពុកឈ្មោះ វុធ ផ៉ាន់ ស្លាប់ក្នុងឆ្នាំ១៩៧៨ ក្នុងភូមិជ្រៃដោយសារកង្វះអាហារហូប។ ចំណែកម្តាយខ្ញុំឈ្មោះ អួង ឆិ ស្លាប់ដោយសារជំងឺបន្ទាប់ពីរបបខ្មែរក្រហមដួលរលំ។ ខ្ញុំមានប្រពន្ធឈ្មោះ ខៀវ សាមុត អាយុ៦៤ឆ្នាំ និងមានកូនចំនួន៧ នាក់។

ខ្ញុំបានចូលរៀននៅពេលអាយុ១២ឆ្នាំហើយ នៅតាមផ្ទះប្រជាជននៅក្នុងភូមិ។ ពេលនោះ មានតែគ្រូម្នាក់ប៉ុណ្ណោះដែលបង្រៀនក្មេងៗនៅក្នុងភូមិជ្រៃ។ គ្រូបង្រៀនឈ្មោះ ឈឹម សៀង ធ្លាប់បួសជាព្រះសង្ឃ។ ខ្ញុំរៀនអក្សរ និងស្រៈ។ ខ្ញុំរៀនបាន៤ឆ្នាំ ក៏ចេះអាន និងចេះសរសេរអក្សរ។ ខ្ញុំឈប់រៀនដោយសារពិបាកធ្វើដំណើរឆ្ងាយ ព្រោះបើខ្ញុំរៀនបន្តទាល់តែខ្ញុំទៅរៀននៅមេមត់ ណាមួយជីវភាពគ្រួសារខ្ញុំខ្វះខាត និងត្រូវជួយធ្វើស្រែចម្ការឪពុកម្តាយ។

នៅឆ្នាំ១៩៧០ លន់ នល់, ចេង ហេង, សិរីមតៈ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ។ បន្ទាប់មកប្រជាជនបានប្រមូលកម្លាំងធ្វើបាតុកម្មទាមទារឲ្យសម្តេចព្រះ នរោត្តម សីហនុមកគ្រប់គ្រងប្រទេសវិញ។ ពេលនោះប្រជាជននៅក្នុងភូមិទៅចូលរួមធ្វើបាតុកម្មដោយស្ម័គ្រចិត្ត និងដោយក្តីគោរពស្រឡាញ់ពេញចិត្តសម្តេចព្រះ នរោត្តម សីហនុ ហើយក៏មានឡានមកដឹកប្រជាជននៅភូមិដែរ។ ក្នុងមួយភូមិមានមនុស្សចំនួន៤ទៅ៥នាក់ ទៅចូលរួមធ្វើបាតុកម្មរហូតដល់ក្រែក ហើយខ្លះទៀតទៅដល់មេមត់ ទើបរត់មកផ្ទះវិញ ព្រោះទាហាន លន់ នល់ បាញ់បំបែកបាតុករនៅខ្នងក្រពើ។ ប្រជាជនដែលទៅធ្វើបាតុកម្មបានរយៈពេលមួយថ្ងៃប៉ុណ្ណោះ ក៏ត្រឡប់មកភូមិវិញ។

កាលនោះកម្លាំងខ្មែរក្រហមក៏មានយូរហើយដែរ ប៉ុន្តែលាក់ខ្លួននៅក្នុងព្រៃ។ នៅពេលរដ្ឋប្រហារឆ្នាំ១៩៧០ កម្លាំងខ្មែរក្រហមក៏ចូលមកក្នុងភូមិដើម្បីជ្រើសរើសកងទ័ពដើម្បីវាយផ្តួលរំលំរបបលន់ នល់។ នៅចុងឆ្នាំ១៩៧០ ខ្ញុំឃើញវត្តមានទាហានអាមេរិក និងកងទ័ពវៀតណាមខាងជើងនៅក្នុងភូមិដែរ។ ពេលនោះប្រជាជនចាប់ផ្តើមភ័យខ្លាច និងនាំគ្នាជីកត្រង់សេ ឬលេណដ្ឋានជិតៗផ្ទះដែលមានបណ្តោយ២ម៉ែត្រ និងទទឹង១ម៉ែត្រកន្លះ ហើយកាប់ឫស្សី និងឈើក្រាលពីលើ រួចយកដីមកចាក់បន្ថែមដោយទុកតែរន្ធតូចមួយសម្រាប់ចេញចូលលាក់ខ្លួន។

នៅក្នុងឆ្នាំ១៩៧១ ទាហានអាមេរិកផ្លោងគ្រាប់

ចំនួនពីរលើក ដាក់ទាហានវៀតកុង (វៀតណាមខាងជើង) ដែលលាក់ខ្លួននៅក្នុងភូមិ ប៉ុន្តែត្រូវចំប្រជាជនបណ្តាលឲ្យស្លាប់ចំនួន៦នាក់ ខណៈពេលដែលប្រជាជនទាំងនោះពួននៅក្នុងលេណដ្ឋានៗ នៅក្នុងឆ្នាំ១៩៧២ ភូមិជ្រៃមិនទាន់មានពេទ្យទេ ដូច្នេះនៅពេលឈឺថ្កាត់ម្តងៗប្រជាជនត្រូវទៅរកគ្រូខ្មែររកថ្នាំបុសឈើ និងទៅបន់ស្រន់អារក្ស អ្នកតា។

នៅឆ្នាំ១៩៧៣ ទើបខ្មែរក្រហមសង់មន្ទីរពេទ្យចល័ត ហើយខ្ញុំត្រូវបានខ្មែរក្រហមជ្រើសរើសឲ្យទៅរៀនពេទ្យ នៅមន្ទីរពេទ្យប្រកគ្រាវ ក្នុងស្រុកមេមត់។ ខ្ញុំរៀនពេទ្យបានរយៈពេល៦ខែ ដោយគ្រូបង្រៀនបានបង្រៀនខ្ញុំអំពីរបៀបពិនិត្យជំងឺ របៀបប្រើឱសថ របៀបចាក់ថ្នាំ និងមេរៀនពេទ្យនៅក្នុងក្រសួងសុខាភិបាល។ ពេលថ្ងៃខ្ញុំត្រូវអនុវត្តផ្ទាល់ ហើយពេលល្ងាចទើបខ្ញុំចូលរៀនពេទ្យ។ នៅពេលខ្ញុំរៀនពេទ្យចប់ មន្ទីរពេទ្យបានចេញសញ្ញាបត្រឲ្យខ្ញុំ ដោយខ្ញុំរៀនផ្នែកជំនួយបឋម។ កាលខ្ញុំនៅរៀនពេទ្យ គឺមានសិស្សពេទ្យប្រមាណ៥០០នាក់ ហើយជនជាតិវៀតណាម គឺជាគ្រូបង្រៀន ព្រោះខ្មែរពុំមានអ្នកចេះជំនាញពេទ្យច្បាស់លាស់ទេ។ វេជ្ជបណ្ឌិតវៀតណាមឈ្មោះ ឡេ ហ៊ាន ចេះគ្រប់ឯកទេសបានមកបង្ហាត់បង្រៀនដល់ខ្ញុំ។

ពេលខ្ញុំរៀនចប់ ខ្មែរក្រហមបានបញ្ជូនខ្ញុំឲ្យទៅនៅ និងធ្វើការនៅតាមសហករណ៍ ចំណែកវេជ្ជបណ្ឌិត ឡេ ហ៊ាន ត្រូវបានចាប់ខ្លួន។ ខ្ញុំបានមកប្រចាំការនៅឃុំត្រមូង ដែលក្នុងមួយឃុំគឺមានពេទ្យចំនួន២នាក់។ កាលនោះ មានខ្ញុំ និងពេទ្យឈ្មោះ ណាត មកពីឃុំដាំក្រវៀន ប្រចាំការនៅឃុំត្រមូង ប៉ុន្តែគ្មានថ្នាំពេទ្យគ្រប់គ្រាន់ឡើយ។ ខ្ញុំនៅប្រចាំការនៅឃុំត្រមូងបានរយៈពេល៦ខែ ខ្មែរក្រហមស្នើខ្ញុំតាមរយៈឃុំ យកទៅធ្វើពេទ្យនៅតំបន់២១ ឬ «ពេទ្យ ប៣»។ «ពេទ្យ ប៣» ស្ថិតនៅក្នុងសាលាមេមត់ និងមានប្រធានពេទ្យឈ្មោះ វ៉ង់ សារិន មកពីស្រុកឆ្លូង ខេត្តក្រចេះ។ ខ្ញុំធ្វើការនៅពេទ្យ ប៣ ដោយដាក់វេនគ្នារង់ចាំមើលថែអ្នកជំងឺ ចាក់ថ្នាំ និងលាងរបួសឲ្យអ្នកជំងឺ។

នៅដើមឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសប្រជាជនចេញពីភ្នំពេញឲ្យមករស់នៅក្នុងភូមិជ្រៃ។ ប្រជាជនមកពីភ្នំពេញត្រូវស្នាក់នៅតាមផ្ទះជាមួយប្រជាជនចាស់នៅក្នុងភូមិជ្រៃ បើផ្ទះណាមានសមាជិកតិច ខ្មែរក្រហមដាក់ឲ្យប្រជាជនមកពីភ្នំពេញនៅជាមួយ មួយទៅពីរគ្រួសារ។ ពេលនោះឪពុកម្តាយខ្ញុំធ្វើចម្ការដាំស្រូវ ចំណែកខ្ញុំធ្វើការនៅពេទ្យ-ប៣ នៅមេមត់បានរយៈពេល២ឆ្នាំ។

នៅឆ្នាំ១៩៧៧ ខ្មែរក្រហមដកខ្ញុំចេញពីពេទ្យ-ប៣ ឲ្យទៅនៅកងចល័តនៅភូមិគោកស្រុក ក្នុងស្រុកតំបែរ ខេត្តកំពង់ចាម ដើម្បីធ្វើស្រែចម្ការ។ ក្នុងកងចល័តរបស់ខ្ញុំមានសមាជិកចំនួន៣០០នាក់ និងមានប្រធានក្រុមឈ្មោះ មឿន អាយុ៤០ឆ្នាំ គឺជាអ្នកស្រុកតំបែរ។ ខ្ញុំស្នាក់នៅជាមួយកងចល័តតាមវាលស្រែ ហើយខ្ញុំត្រូវដឹកគោទៅភ្ជួរស្រែដោយគោមួយនឹមត្រូវភ្ជួរដីស្រែឲ្យហើយក្នុងមួយហិកតាក្នុងមួយព្រឹក។ ពេលភ្ជួរស្រែគ្រប់តាមចំនួនដែលប្រធានកងកំណត់ហើយ នៅពេលល្ងាចខ្ញុំត្រូវធ្វើដីទៀត។ រាល់ថ្ងៃ មុនពេលទៅធ្វើការ ប្រធានកងតែងប្រជុំរាប់ចំនួនមនុស្សថាតើមានសមមិត្តឈឺប៉ុន្មាននាក់ ហើយមិនឈឺប៉ុន្មាននាក់។ នៅក្នុងមួយក្រុមមានសមាជិកចំនួន១២នាក់ ទោះបីជាឈឺ២នាក់ក៏ត្រូវតែធ្វើឲ្យហើយតាមផែនការរបស់ប្រធានកងកំណត់ដែរ។ អ្នកដែលឈឺ គឺខ្មែរក្រហមឲ្យឈប់សម្រាក និងមានពេទ្យមកចែកថ្នាំឲ្យលេប។ នៅពេលប្រជុំម្តងៗ ប្រធានកងលើកយកពីការខិតខំធ្វើការងារ ត្រូវគោរពតាមគោលការណ៍របស់បក្ស។ ចំណែកការហូបចុក គឺហូបតែបបរលាយជាមួយទឹកប្រហុក។ នៅក្នុងមួយឆ្នាំ ខ្មែរក្រហមចែកសម្លៀកបំពាក់ឲ្យពីរសម្រាប់ក្នុងម្នាក់។

នៅខែសីហា ឆ្នាំ១៩៧៨ ខ្ញុំដើរពីភូមិគោកស្រុកត្រឡប់មកភូមិវិញ។ នៅតាមផ្លូវខ្ញុំជួបកងទ័ពខ្មែរក្រហម ប៉ុន្តែខ្ញុំគេចខ្លួនមិនឲ្យកងទ័ពខ្មែរក្រហមឃើញឡើយ។ ខ្ញុំឈប់សម្រាកនៅកំព្រើស ក្នុងស្រុកមេមត់មួយយប់ បន្ទាប់មកខ្ញុំមកស្នាក់នៅឃុំរំចេកមួយយប់ទៀត។ តមកខ្ញុំមកនៅផ្ទះក្នុងភូមិជ្រៃបានមួយយប់ ទើបខ្មែរក្រហមបញ្ជូនខ្ញុំ និងប្រជាជននៅក្នុងភូមិឲ្យទៅនៅស្វាយជ្រះ ដោយនិយាយថា ខ្លាចវៀតណាម

សម្លាប់ៗ ខ្មែរក្រហមជម្លៀសខ្ញុំរហូតដល់មណ្ឌលគិរី ចំណែកឪពុកម្ដាយខ្ញុំនៅត្រើមស្វាយជ្រះ ខេត្តក្រចេះ។ ពេលខ្ញុំទៅដល់ខេត្តមណ្ឌលគិរី ខ្មែរក្រហមចាត់តាំងខ្ញុំឲ្យធ្វើជាយោធា ប៉ុន្តែនៅផ្នែកដាំបាយឲ្យកងទ័ព។ ទោះបីខ្ញុំជាអ្នកដាំបាយ ប៉ុន្តែអង្គការឲ្យខ្ញុំកាន់កាំភ្លើងអាកា ក្នុងមួយបង់មាន៣០គ្រាប់ ហើយក្នុងនោះមាន៣បង់ទៀតដែលស្មើនឹង១២០គ្រាប់។ ប្រធានអង្គភាពទ័ពឲ្យចំហុយបាយដាក់ឡាំងស៊ីងសម្រាប់មួយវរសេនាតូចមានសមាជិក៣០០នាក់។ ប្រធានរោងដាំបាយឈ្មោះ មិល គឺជាជនជាតិភាគតិចស្ទៀង និងមានសមាជិកចំនួន៣០នាក់ ដាំបាយឲ្យកងទ័ពក្នុងមួយថ្ងៃពីរពេល។ នៅទីនោះ ប្រធានរោងបាយហៅប្រជុំជារៀងរាល់ថ្ងៃ គឺឲ្យយើងដាំបាយឲ្យមានអនាម័យ និងគោរពតាមគោលការណ៍របស់អង្គភាព។

ថ្ងៃមួយពេលខ្ញុំកំពុងតែដាំបាយ ឈ្លបខ្មែរក្រហមម្នាក់បានគេអូជូនដំណឹងដល់ឈ្លបប្រចាំការនៅកន្លែងថា «វៀតណាមវាយចូលមកហើយ» ពេលនោះខ្ញុំបានឮសំឡេងយន្តហោះទម្លាក់គ្រាប់គ្រាំងៗ។ កងទ័ពខ្មែរក្រហមបានរត់ចេញពីស្នាក់ការ ហើយមេបញ្ជាកងទ័ពរបស់ខ្មែរក្រហមបានប្រកាសឲ្យអ្នកនៅស្រុកណាត្រូវត្រឡប់ទៅនៅស្រុកនោះវិញ។ ខ្ញុំបានរត់ពីមណ្ឌលគិរីមកជួបឪពុកម្ដាយខ្ញុំនៅថ្មគ្រែ បន្ទាប់មកយើងជិះស្រឡាងឆ្លងមកស្រុកស្ទឹងត្រង់។ ខ្ញុំបានបែកចេញពីគ្រួសារ ទៅរស់នៅខេត្តកំពង់ធំ ដោយខ្ញុំធ្វើការនៅកងចល័ត និងស្នាក់នៅជិតសាលារៀនតាំងគោក។ ប្រធានកងចាត់តាំងខ្ញុំឲ្យបោកស្រូវ ចំណែកអ្នកប្រូតស្រូវគឺប្រធានកងដាក់កំណត់ឲ្យ១០នាក់ត្រូវប្រូតស្រូវឲ្យហើយក្នុងមួយហិកតាក្នុងមួយថ្ងៃ។ នៅតាំងគោក ខេត្តកំពង់ធំ ខ្ញុំបានហូបបាយ ប៉ុន្តែមិនបានឆ្អែតទេ។ ខ្ញុំរស់នៅទីនោះរហូតដល់កងទ័ពវៀតណាម វាយចូលមកជិតដល់ខេត្តកំពង់ធំ ទើបខ្ញុំត្រឡប់មកភូមិកំណើតវិញ។ ដំបូងខ្ញុំ ចេញដំណើរពីតាំងគោកមកឈប់សម្រាកនៅត្រើងមួយយប់ ទើបសុំរថយន្តកងទ័ពវៀតណាមជិះមកឈប់សម្រាកនៅស្រុកមេមត់មួយយប់ទៀត ទើបខ្ញុំធ្វើដំណើរមកភូមិជ្រៃ។ នៅអំឡុងពេលធ្វើដំណើរត្រឡប់មកផ្ទះ តាញ៉ៃបានចូលទៅបត់ជើងស្រាប់ តែដើរជាន់មីនផ្ទុះស្លាប់នៅភូមិដាំទ្រៀក។ ពេលខ្ញុំមកដល់ភូមិជ្រៃ ខ្ញុំឃើញសុទ្ធតែព្រៃដុះព័ទ្ធជុំជិត ពេលនោះខ្ញុំនិងអ្នកភូមិនាំគ្នាដើរដោះមីន បន្ទាប់មកទើបឲ្យសមាជិកគ្រួសារខ្ញុំមករស់នៅតាមក្រោយ។ ខ្ញុំជាមួយគ្រួសារបានសង់ផ្ទះ និងរស់នៅក្នុងភូមិនេះរហូតមកដល់សព្វថ្ងៃ។


សំណង់នៅក្នុងចម្ការកៅស៊ូ ដែលសេសសល់ពីសម័យបារាំង ស្ថិតនៅក្នុងឃុំត្រមូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ហ៊ុន យ៉ូច ៖ អតីតអ្នកជាំបាយនៅពេទ្យស្រែស្បូវ

*ឌិន សុខ ណេង*



ហ៊ុន យ៉ូច អាយុ៦៩ឆ្នាំ គឺជាជនជាតិដើមភាគតិចមិល សព្វថ្ងៃរស់នៅភូមិចង្អប ឃុំក្បាលដំរី ស្រុកអូរគ្រៀង សែនជ័យ ខេត្តក្រចេះ។ (វ៉ង់ ស្រីឃីម/មជ្ឈមណ្ឌលឯកសារកម្ពុជា)

មុនសម័យខ្មែរក្រហម ហ៊ុន យ៉ូច កំពុងសិក្សាថ្នាក់ទី៣។ នៅពេលខ្មែរក្រហមចូលមកគ្រប់គ្រងភូមិចង្អប ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ ខ្មែរក្រហមបង្ខំគាត់ឲ្យបោះបង់ការសិក្សា ហើយទៅធ្វើការងាររើសអាចម៍គោធ្វើជីដាក់ស្រែ។ ក្រោយមកទៀត ខ្មែរក្រហមចាត់តាំងគាត់ឲ្យចូលក្នុងកងចល័ត និងទៅលើកទំនប់អូរគ្រៀង។ បន្ទាប់ពីធ្វើការងាររួចហើយ ខ្មែរក្រហមមិនបានផ្តល់របបអាហារ ឬបាយឲ្យគាត់ហូបឆ្អែតនោះទេ។ ខ្មែរក្រហមបានផ្តល់អាហារឲ្យគាត់ហូបក្នុងមួយថ្ងៃ២ពេល គឺពេលព្រឹកហូបបបរក្នុងម្នាក់មួយកូនចានចង្កឹះ និងពេលល្ងាចឲ្យហូបបាយជាមួយសម្លត្រកួន និងពេលខ្លះមានត្រី និងសាច់ម្តងម្កាលដែរ។ គាត់ឈឺពោះរាករូសអំឡុងពេលធ្វើការងារលើកទំនប់ ហើយប្រធានកងបានបញ្ជូនគាត់ឲ្យទៅមន្ទីរពេទ្យដើម្បីព្យាបាលជំងឺ។ ពេទ្យខ្មែរក្រហមបានឲ្យគាត់លេបថ្នាំខ្មៅៗ ដែលគាត់ហៅថាថ្នាំអាចម៍ទន្សាយ និងមានថ្នាំចាក់ផងដែរ ប៉ុន្តែគាត់មិនដឹងថាថ្នាំនោះនាំមកពីណានោះទេ។

ហ៊ុន យ៉ូច រៀបរាប់បន្តថា នៅពេលលើកទំនប់ម្តងៗមានប្រជាជនប្រមាណពី៤០ទៅ៥០នាក់ និងមានបង្គី ឬពលៃ ដែលត្បាញពីឫស្សីឲ្យវែង និងដាក់ដើមឫស្សីកណ្តាលសម្រាប់សែងដី។ ការលើកទំនប់នៅអូរគ្រៀងពេលនោះគឺគ្មានប្រជាជនស្លាប់ឡើយ។

បន្ទាប់មកទៀត ខ្មែរក្រហមបានបញ្ជូនគាត់ឲ្យទៅធ្វើការងារនៅមន្ទីរពេទ្យស្រែស្បូវ។ នៅទីនោះមានប្រជាជនស្លាប់ច្រើនណាស់ គឺក្នុងមួយយប់ មានអ្នកស្លាប់ចាប់ពី២ទៅ៣នាក់ ដោយសារធ្វើការងារធ្ងន់ និងហូបមិនឆ្អែត ពិសេសអ្នកមកពីខាងបូព៌ា។ គាត់ភ័យខ្លាចខ្លាំងណាស់។ នៅមន្ទីរពេទ្យស្បែស្បូវ គាត់មានតួនាទីជាំបាយ ពុះអុស និងដងទឹក។ ដោយសារសម័យខ្មែរក្រហមមិនចាយលុយ ដូច្នេះពេលដល់ខែខ្មែរក្រហមចែកសំពត់ ខោអាវខ្មៅ ស្បែកជើងកង់ឡាន និងក្រមាសខ្មៅ ក្នុងម្នាក់មួយសម្រាប់ឲ្យគាត់។ ក្រុមគ្រួសាររបស់គាត់មិនបានជួបជុំគ្នាទេ។ គាត់រស់នៅនិងធ្វើការនៅមន្ទីរពេទ្យ ចំណែកឪពុករបស់គាត់រស់នៅ និងធ្វើការងារនៅកន្លែងផ្សេងៗ។ សមាជិកគ្រួសារខ្លះធ្វើការងារគ្មានពេលសម្រាកនោះទេ និងបែកទៅតាមកន្លែងផ្សេងៗរហូតពេលយប់ទើបជួបគ្នា។ នៅសម័យនោះ ខ្មែរក្រហមបានជម្លៀសប្រជាជនថ្មីពីភ្នំពេញឲ្យមករស់នៅភូមិអូរតាណើង រួមមាន ជនជាតិដើមភាគ

តិចចិន និងជនជាតិដើមភាគតិចចាម។ គាត់ចាំថា មានគ្រួសារបងប្អូនជនជាតិដើមភាគតិចចិន ឈ្មោះ ទ្រី, គុយ, អៀង, កុក ហើយឪពុករបស់ កុក ឈ្មោះ តារ៉ុង។

នៅដើមឆ្នាំ១៩៧៩ ពេលកងទ័ពវៀតណាមវាយចូលមក គាត់បានរត់គៀសខ្លួនទៅតាមអ្នកភូមិដោយគ្មានគោលដៅ និងគ្មានពេលសម្រាកទាំងយប់ទាំងថ្ងៃ ហើយគាត់ក៏មិននឹកស្មានថាអាចរស់មកដល់សព្វថ្ងៃដែរ។

ក្រោយរបបខ្មែរក្រហមបញ្ចប់ គាត់រស់នៅជាមួយទុក្ខសោកដោយបងស្រីរបស់គាត់ឈ្មោះ ហ៊ុន យ៉េង ត្រូវឡានបុកស្លាប់ ហើយប្អូនស្រីរបស់គាត់ឈ្មោះ ហ៊ុនវ៉ៃន បានស្លាប់នៅពេលសម្រាលកូន ចំណែក ប្តីរបស់គាត់ឈ្មោះ ស៊ិប ហេម បានស្លាប់ដោយសារជំងឺ តាំងពីកូនៗរបស់គាត់នៅតូចម្ល៉េះ។

សព្វថ្ងៃ គាត់អាយុ៦២ឆ្នាំ គឺជាស្ត្រីមេម៉ាយ និងមានជំងឺប្រចាំកាយ ដូចជា ឈឺសន្លាក់ដៃ ជើង គ្រុនពោះវៀនរលាកក្រពះ និងស្រវាំងភ្នែក។ គាត់ស្នាក់នៅភូមិចង្អូប ឃុំក្បាលដំរី ស្រុកអូរគ្រៀងសែនជ័យ ខេត្តក្រចេះ ជាមួយក្មួយស្រីដើម្បីព្យាបាលជំងឺ។ ម្តងម្កាល មិត្តភក្តិចាស់នៅក្នុងរបបខ្មែរក្រហម ឈ្មោះ កុក គឺជាជនជាតិភាគតិចចិនកាលជំនាន់នោះ មកលេង និងសួរសុខទុក្ខគាត់ដែរ។



ប្រព័ន្ធធារាសាស្ត្រសាងសង់នៅឆ្នាំ១៩៦១ ស្ថិតនៅឃុំក្បាលដំរី ស្រុកអូរគ្រៀងសែនជ័យ ខេត្តក្រចេះ ដែលជាស្នាព្រះហស្តរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង រៀបចំវេទិកា ថ្នាក់រៀនចុងសប្តាហ៍ស្តីអំពីរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដល់សិស្សវិទ្យាល័យអន្ករស

ផេង ពង្សរ៉ាស៊ី







សិស្សានុសិស្សសរុបចំនួន៤០នាក់មកពីវិទ្យាល័យ អន្ករស ស្រុកមេសាង ខេត្តព្រៃវែង ចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ នៅថ្ងៃទី១១ ខែកុម្ភៈឆ្នាំ២០២៤ នៅការិយាល័យមជ្ឈមណ្ឌលឯកសារ ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

សិស្សានុសិស្សសរុបចំនួន៤០នាក់មកពីវិទ្យាល័យ អន្ករស ស្រុកមេសាង ខេត្តព្រៃវែង បានមកចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៤ នៅការិយាល័យមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។ វេទិកានេះប្រព្រឹត្តទៅមួយថ្ងៃ។ ពេលព្រឹក គឺជាពេលដែលសិស្សានុសិស្សទាំងអស់ សិក្សាឈ្វេងយល់ពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រទាក់ទងនឹងការជម្លៀសប្រជាជនដោយបង្ខំរបស់ខ្មែរក្រហម និងវិធីសាស្ត្រចាំបាច់មួយចំនួនក្នុងការចូលរួមទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅកម្ពុជា ហើយពេលរសៀល គឺជាពេលដែលសិស្សអាចជួបជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅលើទីតាំងអតីតវាលពិឃាតខ្មែរក្រហមនៅវត្តទួលជ្រៃ ស្រុកពាមរក៍ ខេត្តព្រៃវែង។

គោលបំណងចម្បងនៃការអនុវត្តវេទិកាថ្នាក់រៀនចុងសប្តាហ៍នេះគឺ ដើម្បីបង្កើនការចងចាំពីប្រវត្តិសាស្ត្រនេះដល់មនុស្សជំនាន់ក្រោយ និងដើម្បីទប់ស្កាត់ការវិលត្រឡប់វិញនៃរបបខ្មែរក្រហម។ ដើម្បីសម្រេចបានគោលបំណងខាងលើ វេទិកាថ្នាក់រៀននេះបានកំណត់កម្មវិធីបង្រៀនដល់សិស្សដោយ៖ ១) ពន្យល់សិស្សានុសិស្សឲ្យឈ្វេងយល់ពីព្រឹត្តិការណ៍ជម្លៀសប្រជាជនដោយបង្ខំ ពីឆ្នាំ១៩៧៥ ដល់ ចុង

ឆ្នាំ១៩៧៧។ ២) បង្ហាញដល់សិស្សានុសិស្សឲ្យឈ្វេងយល់ពីរបៀប និងមូលហេតុនៃការជម្លៀសប្រជាជនដោយបង្ខំ។ ៣) លើកទឹកចិត្តសិស្សឲ្យបង្កើនការសន្ទនាអន្តរជំនាន់អំពីបទពិសោធន៍នៃការជម្លៀសដោយបង្ខំរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និង ៤) លើកទឹកចិត្តសិស្សឲ្យបង្កើនការត្រិះរិះពិចារណាក្នុងការរារាំងអំពើហិង្សាដែលអាចឈានដល់ការប្រព្រឹត្តអំពើប្រល័យពូជសាសន៍នៅកម្រិតបុគ្គល គ្រួសារ សហគមន៍ និងប្រទេសជាតិ។

នៅក្នុងឱកាសនោះសិស្សានុសិស្សមានឱកាសជួបជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅលើទីតាំងអតីតវាលពិឃាតខ្មែរក្រហមនៅវត្តទួលជ្រៃ គឺអ្នកស្រី យឹម សុវណ្ណ ត្រូវបានជម្លៀសដោយបង្ខំក្នុងរបបខ្មែរក្រហម។ អ្នកស្រី យឹម សុវណ្ណ បានពិពណ៌នាអំពីការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញថា ៖ នៅម៉ោងប្រហែល៣រសៀល ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដំបូងឡើយឪពុករបស់ខ្ញុំបានបដិសេធក្នុងការចាកចេញ។ ខ្មែរក្រហមកាន់កាំភ្លើងវែងមកជាមួយ ព្រមទាំងអន្ទរមួយចំនួន រួចប្រាប់ឪពុកខ្ញុំថា «មិត្តត្រូវតែចាកចេញ អាមេរិកាំងនឹងទម្លាក់គ្រាប់បែកលើទីក្រុងភ្នំពេញ។ ឪពុករបស់ខ្ញុំប្រញាប់ប្រញាល់រៀបចំកាបូប និងប្រមែប្រមូលស្រូវខ្លះនៅមុនពេលចាកចេញពីផ្ទះរបស់យើង។ ពេលនោះ គឺជាការចាកចេញដ៏សោកសង្រេងមួយ។ ខ្មែរក្រហមទាំងនោះសុទ្ធតែមានប្រដាប់អាវុធ ទាំងស្រី ទាំងប្រុស។ អ្នកទាំងនោះស្លៀកពាក់ពណ៌ខ្មៅ និងបង់ក្រមាពណ៌ក្រហម។ អ្នកទាំងនោះបានប្រាប់ក្រុមគ្រួសាររបស់ខ្ញុំ ហើយស្នើឲ្យគ្រួសារខ្ញុំចាកចេញ និងត្រូវធ្វើដំណើរទៅកាន់ភូមិកំណើតរបស់ខ្ញុំរយៈពេលបីថ្ងៃ បើមិនដូច្នេះអាមេរិកាំងនឹងទម្លាក់គ្រាប់បែក និងសម្លាប់គ្រួសាររបស់ខ្ញុំ។ កងទ័ពទុកពេលឲ្យយើងត្រឹមតែ១៥នាទីប៉ុណ្ណោះដើម្បីចាកចេញ ហើយបើយើងបដិសេធ វិធានការណ៍ផ្សេងៗនឹងត្រូវធ្វើឡើង។ ខ្ញុំបានឃើញកងទ័ពបាញ់បំបែកមេសោជាប់នឹងទ្វារផ្ទះមួយខ្នង ក្នុងផ្សារអូរឫស្សី។ បន្ទាប់មកកងទ័ពបានបាញ់មនុស្សម្នាទាំងឡាយដែលបានរត់ចេញពីក្នុងផ្ទះនោះ។ ទាហាន លន់ នល់ រងរបួសនៅឯមន្ទីរពេទ្យយោធាក្នុងបុរីកីឡា ដែលជាកម្មសិទ្ធិរបស់យោធា លន់ នល់ ត្រូវកងទ័ពខ្មែរក្រហមបានរុញទាហានទាំងនោះទម្លាក់ពីលើគ្រែ។ អ្នករងរបួសខ្លះ ត្រូវបានបញ្ជូនទៅឲ្យសាច់ញាតិ ចំណែកអ្នកឯទៀត ត្រូវបានទុកចោលដល់ស្លាប់។ អ្នកដែលបានស្លាប់ក្នុងអំឡុងពេលជម្លៀស ពុំទទួលបានការរៀបចំបុណ្យសពទេ។ សាកសពត្រូវបានទម្លាក់ទៅក្នុងប្រឡាយ ឬទុកចោលនៅតាមផ្លូវ។

លោក ជុំ សុខា ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងសំណុំរឿង០០២ បានរៀបរាប់ថា ខ្ញុំបានឃើញសាកសពនៅតាមបណ្តោយផ្លូវ អមជាមួយនឹងភ្លើងហ្វារបស់យានយន្ត ក៏ដូចជាផ្ទះ ដែលឆេះហុយផ្សែង ព្រមទាំងសាកសពដែលត្រូវបានដុតនៅជុំវិញអាកាសយានដ្ឋានពោធិ៍ចិនតុង និងនៅខាងមុខនាយកដ្ឋានដឹកជញ្ជូន។ ខ្ញុំ ម្តាយ ប្អូនស្រី ឪពុកមា និងជីដូនជីតា បានធ្វើដំណើរដោយថ្មើរជើងទៅមុន។ ចំណែកឯឪពុក និងឪពុកមាម្នាក់ទៀត មកតាមក្រោយ។ បន្ទាប់ពីក្រុមខ្ញុំធ្វើដំណើរបានប្រមាណ២គីឡូម៉ែត្រ ឪពុករបស់ខ្ញុំបានមកទាន់និងបានប្រាប់ថា «ខ្លួនគាត់ស្ទើរតែនឹងត្រូវឃុំខ្លួន តែគាត់សម្គាល់ឃើញ



សិស្សានុសិស្សសរុបចំនួន៤០នាក់មកពីវិទ្យាល័យអង្គរស ស្រុកមេសាង ខេត្តព្រៃវែង ចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៤ នៅការិយាល័យមជ្ឈមណ្ឌលឯកសារ ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




សិស្សានុសិស្សសរុបចំនួន៤០នាក់មកពីវិទ្យាល័យ អង្គរស ស្រុកមេសាង ខេត្តព្រៃវែង ចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៤ នៅការិយាល័យមជ្ឈមណ្ឌលឯកសារ ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ថាមនុស្សម្នាត្រូវបានចងភ្ជាប់គ្នាជាខ្សែ ដូច្នេះគាត់ក៏បានគេចខ្លួន និងប្រាប់ក្រុមគ្រួសារឲ្យប្រញាប់ចេញទៅ»។ ក្រុមគ្រួសារខ្ញុំនៅឯវត្តអង្គក្រូចរយៈពេលប៉ុន្មានថ្ងៃ ដោយសារតែប្អូនស្រីរបស់ខ្ញុំហើមជើង និងមិនអាចដើរបាន។ ក្រោយមក អង្គការបានប្រាប់ក្រុមគ្រួសាររបស់ខ្ញុំថា «គាត់ទាំងអស់ត្រូវបានអនុញ្ញាតឲ្យត្រឡប់ទៅកាន់ភូមិកំណើតរបស់ខ្លួន គឺនៅភូមិត្បូងក្តី ខេត្តព្រៃវែងវិញ»។ ប្អូនស្រីរបស់ខ្ញុំនៅតែមានបញ្ហាជើង ដូច្នេះម្តាយរបស់ខ្ញុំបានដោះដូរគ្រឿងអលង្ការ និងសម្លៀកបំពាក់ល្អៗមួយចំនួន ដើម្បីអាចឲ្យប្អូនស្រីធ្វើដំណើរតាមរទេះ។ បន្ទាប់មក ក្រុមគ្រួសារខ្ញុំបានមកដល់ភូមិមួយនៅក្បែរទន្លេបាទី រួចក៏បានសម្រាកនៅទីនេះមួយយប់ នៅមុនពេល បន្តដំណើរទៅកាន់ភូមិបឹងខ្វក។ បន្ទាប់ពីចំណាយពេលជាងមួយខែធ្វើដំណើរចេញពីទីក្រុងភ្នំពេញ ក្រុមគ្រួសារខ្ញុំបានមកដល់ភូមិត្បូងក្តី ខេត្តព្រៃវែង ដែលជាភូមិកំណើតរបស់ក្រុមគ្រួសារខ្ញុំ។

លោក **ស៊ឹម សុត** ហៅ **កុយ** គឺជាអ្នករស់រានមានជីវិតម្នាក់ទៀត ព្រមទាំងធ្លាប់ជាអ្នកធាក់ស៊ីក្លូនៅក្នុងទីក្រុងភ្នំពេញបានរំឭកឡើងវិញពីហេតុការណ៍ដែលគាត់បានឃើញក្នុងអំឡុងពេលជម្លៀសថា «នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំបានចេញដំណើរទៅប្រកបរបរដូចធម្មតា។ ពីរទៅបីម៉ោងក្រោយមក ខ្ញុំឃើញកងទ័ពខ្មែរក្រហមធ្វើដំណើរមកភ្នំពេញ។ ប្រជាជនបានចេញមកក្រៅ ហើយគ្រវីក្រណាត់ស និងអាវសស្វាគមន៍ខ្មែរក្រហម។ ភ្លាមៗនោះ ពួកគេបានបាញ់កាំភ្លើងទៅលើអាកាស បញ្ជូប្រជាជនឲ្យចាកចេញពីទីក្រុងដោយអះអាងថាអាមេរិកាំងនឹងមកទម្លាក់គ្រាប់បែក។ ដូចអ្នកឯទៀតដែរ ខ្ញុំបានប្រញាប់ប្រញាល់ធ្វើដំណើរចាកចេញនៅម៉ោងដប់ជាមួយបងប្រុសខ្ញុំ មិត្តភក្តិនៅវត្តជាមួយខ្ញុំ និងព្រះសង្ឃ។ នៅលើផ្លូវដ៏ណែនណាន់តាន់តាប់ ខ្ញុំឮសូរសំឡេងមនុស្សម្នា ស្រែកហៅរកឪពុកម្តាយបងប្អូន និងសម្រែកក្មេងៗយំទាររកបាយ ។ ខ្មែរក្រហមបានរឹបអូសយករបស់របរប្រជាជន។ អ្នកដែលជំទាស់មិនព្រមឲ្យនឹងត្រូវសម្លាប់ ឬក៏ចាប់ខ្លួនយកទៅបាត់។ នៅពេលដែលខ្ញុំកំពុងតែដើរ កងទ័ពខ្មែរក្រហមស្រីម្នាក់បានទាញកអាវខ្ញុំហើយសួរខ្ញុំថាជាអតីតទាហាន





សិស្សានុសិស្សសរុបចំនួន៤០នាក់មកពីវិទ្យាល័យ អន្លង់វែង ស្រុកមេសាង ខេត្តព្រៃវែង ចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៤ នៅការិយាល័យមជ្ឈមណ្ឌលឯកសារ ខេត្តព្រៃវែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ឬ? គាត់រុញខ្ញុំថយក្រោយ នៅពេលដែលខ្ញុំប្រាប់គាត់ថាខ្ញុំជា កូនសិស្ស។ ខ្ញុំក៏បានបន្តដំណើររបស់ខ្ញុំទៅក្រុងតាខ្មៅ។ នៅតាមផ្លូវ ខ្ញុំបានឃើញសាកសពដែលទើបតែហើមថ្មីៗជាច្រើន។ បន្ទាប់ពីបានធ្វើដំណើរអស់រយៈពេលបីថ្ងៃ ខ្ញុំបានមកដល់ខេត្តតាកែវ។

អ្នកស្រី **ឡាយ ប៊ុនធី** គឺជាដើមបណ្តឹងរដ្ឋប្បវេណីនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងសំណុំរឿង០០២ ក៏បានផ្តល់សក្ខីកម្ម ស្តីពីការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញដែរ ដោយបានលើកឡើងថា «ទាហានខ្មែរក្រហមបានប្រាប់ប្រជាជនឲ្យចាកចេញតាមវិធីសាស្ត្រដែលខ្លួនអាចធ្វើទៅបាន។ ខ្មែរក្រហមមិនបានប្រាប់ប្រជាជនថារបស់របរអ្វីដែលគួរយកទៅតាមខ្លួនឡើយ។ ក្រុមគ្រួសាររបស់ខ្ញុំមិនបានយកអង្ករទៅតាមទេ។ ក្រុមគ្រួសារខ្ញុំយកទៅតែប្រាក់កាស ដែលខ្ញុំគិតថាអាចប្រើប្រាស់បាននៅតាមផ្លូវ។ ទាហានខ្មែរក្រហម មិនបានប្រាប់ថាប្រាក់កាសគ្មានប្រយោជន៍ទេ។ ខ្ញុំប្រែជាអស់សង្ឃឹមនៅពេលបានដឹងរឿងនេះនៅតាមផ្លូវ។ មនុស្សម្នាដែលមិនអាចធ្វើដំណើរដោយខ្លួនឯងបាន ដូចជាអ្នកជំងឺដែលសម្រាកនៅមន្ទីរពេទ្យ ត្រូវរុញដោយប្រើប្រាស់គ្រែអ្នកជំងឺរបស់មន្ទីរពេទ្យ ឬសែងដោយស្នែង ឬអង្រឹង។ អ្នកខ្លះឈឺធ្ងន់ ត្រូវដឹះលើខ្នងម្នាក់ទៀត ដែលអាចដើរបាន។ ប្រជាជនដែលត្រូវជម្លៀសអាចពុះសម្រែកថ្ងូររបស់អ្នកសម្រាលកូននៅតាមដងផ្លូវ ហើយនៅទីបំផុតអ្នកដែលត្រូវជម្លៀស ទាំងនោះក៏រកបានឆ្មបម្នាក់មកជួយសម្រាលកូនឲ្យស្ត្រីជាម្តាយ។ ខ្ញុំត្រូវបានជម្លៀសដោយបង្ខំ ជាមួយនឹងកូនស្រីអាយុ៥ឆ្នាំម្នាក់។ កូនស្រីរបស់ខ្ញុំបានធ្លាក់ខ្លួនឈឺអស់រយៈពេលប៉ុន្មានថ្ងៃមកហើយ។ នាងរាករូសយ៉ាងខ្លាំង ខ្ញុំត្រូវបានគេបង្គាប់ឲ្យរកស្លឹករុក្ខជាតិមកព្យាបាលជំងឺរបស់នាង។ សមាជិកគ្រួសាររបស់ខ្ញុំម្នាក់ៗ សុទ្ធតែក្តៅខ្លួន។ នៅពេលដែលម្តាយមីងរបស់ខ្ញុំមកលេង ហើយឃើញស្ថានភាពនេះ គាត់ចង់យកកូនខ្ញុំទៅនៅជាមួយគាត់ដើម្បីព្យាបាលនាង។ ខ្ញុំយល់ព្រមឲ្យគាត់យកនាងទៅ។ ខ្ញុំជឿជាក់ថាកូនស្រីរបស់ខ្ញុំនឹងត្រូវបានព្យាបាល ឬមើលថែទាំបានត្រឹមត្រូវ ប៉ុន្តែក្រោយមកទើបខ្ញុំដឹងថា នាងបានស្លាប់បាត់ទៅហើយ។ ខ្ញុំក៏ត្រូវបានបង្ខំឲ្យផ្លាស់ទីម្តងទៀតពីស្រុកខ្សាច់កណ្តាលទៅខេត្តពោធិ៍សាត់។ អ្នកដែលត្រូវជម្លៀសនានា ហូបអាហារនៅតាមផ្លូវ ហើយអាហារទាំងនោះមិនល្អចំពោះយើងទេ វាបណ្តាលឲ្យពោះយើងមានបញ្ហា។

# សិស្សវិទ្យាល័យប៊ុន រ៉ានី ហ៊ុន សែន ដារ ចូលរួម

## វេទិកាថ្នាក់រៀនស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥ - ១៩៧៩) និងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ» រៀបចំដោយមជ្ឈមណ្ឌលឯកសារកោះថ្ម

**ឡុង ដានី**







នៅព្រឹកថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៤ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម បានរៀបចំវេទិកាថ្នាក់រៀនស្តីអំពី «ប្រវត្តិសាស្ត្រខ្មែរក្រហម (១៩៧៥ - ១៩៧៩) និងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ" លើប្រធានបទការជម្លៀសប្រជាជនចេញពីទីក្រុង ការជម្លៀសដោយបង្ខំ និងការសម្លាប់រង្គាលនៅទួលពោធិ៍ជ្រៃ ដល់សិស្សចំនួន៥៣នាក់ (ស្រី៣៨នាក់) មកពីវិទ្យាល័យប៊ុន រ៉ានី ហ៊ុន សែន ដារ ស្ថិតនៅក្នុងឃុំដារ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅព្រឹកថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៤ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម រៀបចំវេទិកាថ្នាក់រៀនស្តីអំពី«ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ» លើប្រធានបទការជម្លៀសប្រជាជនចេញពីទីក្រុង ការជម្លៀសដោយបង្ខំ និងការសម្លាប់រង្គាលនៅទួលពោធិ៍ជ្រៃ ដល់សិស្សចំនួន៥៣នាក់ ក្នុងនោះមានស្រី៣៨នាក់ មកពីវិទ្យាល័យប៊ុន រ៉ានី ហ៊ុន សែន ដារ ស្ថិតនៅក្នុងឃុំដារ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ។

គោលបំណងនៃការរៀបចំវេទិកាថ្នាក់រៀនគឺចង់ឲ្យយុវជនរៀនសូត្របន្ថែមអំពីបរិបទប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងនិយមន័យការទប់ស្កាត់អំពើប្រល័យពូជសាសន៍ និងកត្តាគ្រោះថ្នាក់នានាដែលនាំឲ្យកើតមានអំពើនេះនាពេលអនាគត។ យុវជនក៏អាចផ្លាស់ប្តូរការគិតពីការប្រព្រឹត្តអំពើហិង្សា មកជាការកសាងសន្តិភាព ក្នុងកម្រិតបុគ្គល គ្រួសារ សហគមន៍ និងប្រទេសជាតិ។

ជាកិច្ចចាប់ផ្តើមលោក ឈុំ រ៉ា បុគ្គលិកមជ្ឈមណ្ឌលឯកសារកោះថ្ម បានដឹកនាំសិស្សដើរទស្សនាពិព័រណ៍រូបថត ស្តីអំពីសង្គ្រាមកាលពីចុងទសវត្សរ៍ឆ្នាំ១៩៦០ រូបថតអំពីរបបខ្មែរក្រហម (១៩៧៥-១៩៧៩) រូបថតអំពីជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាបន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ រូបថតភស្តុតាងអំពីឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយរបបខ្មែរក្រហម (១៩៧៥-១៩៧៩) រូបគំនូរ និងផែនទីបង្ហាញផ្លូវនៃដំណើររបស់សម្តេចតេជោ ហ៊ុន សែន និងយុទ្ធមិត្ត៤រូបចេញទៅប្រទេសវៀតណាមនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ ដើម្បីកសាងកងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជាវាយផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត សង្គ្រោះអាយុជីវិតប្រជាជនកម្ពុជាប្រមាណ៥លាននាក់ឲ្យរួចផុតពីសេចក្តីស្លាប់។

បន្ទាប់មកលោក ឡុង ដានី នាយកមជ្ឈមណ្ឌលឯកសារកោះថ្ម ធ្វើបទបង្ហាញដល់យុវជនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) លើប្រធានបទការឡើងកាន់អំណាចរបស់ខ្មែរក្រហម៖ ការជម្លៀសប្រជាជនចេញពីទីក្រុង ការជម្លៀសដោយបង្ខំ និងការសម្លាប់រង្គាលនៅទួលពោធិ៍ជ្រៃ។ លោក ឡុង ដានី បានលើកយកវិធីសាស្ត្រ K-W-L (ដឹង, ចង់ដឹង, បានដឹង) មកបង្រៀនសិស្ស និងចាប់ផ្តើមដោយសួរសំណួរទៅសិស្សទាំងអស់ថា តើប្អូនៗបានដឹងអ្វីខ្លះអំពីរបបខ្មែរក្រហម? តមកលោក ឡុង ដានី សួរសំណួរបន្ថែមទៅកាន់សិស្សទាំងអស់ថា តើប្អូនៗចង់ដឹងអ្វីខ្លះអំពីរបបខ្មែរក្រហម? ចុងក្រោយ លោក ឡុង ដានី បានធ្វើបទបង្ហាញអំពីការជម្លៀសប្រជាជនចេញពីទីក្រុង ការជម្លៀសដោយបង្ខំ និងការសម្លាប់រង្គាលនៅទួលពោធិ៍ជ្រៃ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ខ្មែរក្រហមបានជម្លៀសប្រជាជនដោយបង្ខំ មានបីដំណាក់កាលដូចខាងក្រោម៖



នៅព្រឹកថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៤ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មបានរៀបចំវេទិកាថ្នាក់រៀនស្តីអំពី «ប្រវត្តិសាស្ត្រខ្មែរក្រហម (១៩៧៥ - ១៩៧៩) និងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ” លើប្រធានបទការជម្លៀសប្រជាជនចេញពីទីក្រុង ការជម្លៀសដោយបង្ខំ និងការសម្លាប់រង្គាលនៅទួលពោធិ៍ជ្រៃ ដល់សិស្សចំនួន៥៣នាក់ (ស្រី៣៨នាក់) មកពីវិទ្យាល័យប៊ុនរ៉ានី ហ៊ុនសែន ដារ ស្ថិតនៅក្នុងឃុំដារ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)







នៅព្រឹកថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៤ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មបានរៀបចំវេទិកាថ្នាក់រៀនស្តីអំពី «ប្រវត្តិសាស្ត្រខ្មែរក្រហម (១៩៧៥ - ១៩៧៩) និងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ” លើប្រធានបទការជម្លៀសប្រជាជនចេញពីទីក្រុង ការជម្លៀសដោយបង្ខំ និងការសម្លាប់រង្គាលនៅទួលពោធិ៍ជ្រៃ ដល់សិស្សចំនួន៥៣នាក់ (ស្រី៣៨នាក់) មកពីវិទ្យាល័យប៊ុនរ៉ានី ហ៊ុនសែន ដារ ស្ថិតនៅក្នុងឃុំដារ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

១) នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បន្ទាប់ពីកងទ័ពខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ បានរយៈពេល២ទៅ៣ម៉ោង មេដឹកនាំខ្មែរក្រហមបានបញ្ជាឲ្យកងទ័ពខ្មែរក្រហមចាប់ផ្តើមជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ និងប្រជុំជននានា ទៅធ្វើការងារពលកម្មដ៏លំបាកវេទនានៅតាមវាលស្រែក្នុងតំបន់ដាច់ស្រយាលនៃប្រទេសកម្ពុជា។ កងទ័ពខ្មែរក្រហមបានយកលេសក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញថា សហរដ្ឋអាមេរិកនឹងមកទម្លាក់គ្រាប់លើទីក្រុងភ្នំពេញ។ ប្រជាជននឹងជម្លៀសចេញពីទីក្រុងភ្នំពេញតែរយៈពេល៣ថ្ងៃនឹងបានវិលត្រឡប់មកផ្ទះវិញហើយ ដូច្នេះប្រជាជនទាំងអស់មិនចាំបាច់យកទ្រព្យសម្បត្តិច្រើនទៅតាមខ្លួន និងចាក់សោផ្ទះទេ។ ប៉ុន្តែការពិតខ្មែរក្រហមមិនបានអនុញ្ញាតឲ្យប្រជាជនត្រឡប់មកផ្ទះវិញពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥ - ១៩៧៩)។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ប្រជាជនជម្លៀសច្រើនលើសលប់បានស្លាប់ដោយសារការសម្លាប់ ធ្វើការងារហួសកម្លាំង និងអត់អាហារ។

២) ចាប់តាំងពីចុងឆ្នាំ១៩៧៥ ខ្មែរក្រហមបានផ្លាស់ទីប្រជាជនជាពិសេសជម្លៀសប្រជាជនថ្មីដោយបង្ខំពីទីជនបទមួយទៅទីជនបទមួយទៀតម្តងហើយម្តងទៀត នៅភូមិភាគកណ្តាល ភូមិភាគនិរតី ភូមិភាគបស្ចិម ភូមិភាគបូព៌ា (រួមបញ្ចូលទាំងការផ្លាស់ទីតាមរយៈរថភ្លើងពីភូមិភាគនិរតី និងភូមិភាគបស្ចិមទៅកាន់ភូមិភាគពាយ័ព្យ)។ ការផ្លាស់ទីប្រជាជននេះពុំមានជូនដំណឹងជាមុនឡើយ បង្កជាទុក្ខវេទនា និងភាពលំបាកលំបិនដល់ប្រជាជន និងសហគមន៍ជាខ្លាំង។

៣) ចាប់តាំងពីរបបខ្មែរក្រហមធ្វើសង្គ្រាមតាមព្រំដែនជាមួយប្រទេសវៀតណាម នៅចុងឆ្នាំ១៩៧៧ ខ្មែរក្រហមចាប់ផ្តើមលែងទុកចិត្តលើកម្មាភិបាល យុទ្ធជន និងប្រជាជននៅភូមិភាគបូព៌ា។

ប្រជាជនភូមិភាគបូព៌ា ត្រូវបានខ្មែរក្រហមចោទប្រកាន់ថាជាមនុស្សដែលមានក្បាលយួនខ្លួនខ្មែរ។ ប្រជាជនភូមិភាគបូព៌ា ទាំងអស់ជាគោលដៅនៃការជម្លៀសដោយបង្ខំចេញពីភូមិភាគបូព៌ាទៅភូមិភាគពាយ័ព្យ ភូមិភាគកណ្ដាល និងភូមិភាគឧត្តរ។ ការជម្លៀសដោយបង្ខំនេះបានបណ្ដាលឲ្យប្រជាជនភូមិភាគបូព៌ាជាច្រើន បានស្លាប់ដោយសារខ្មែរក្រហមសម្លាប់ អត់អាហារ ជំងឺ និងគ្មានថ្នាំព្យាបាល។

ជាកិច្ចបន្ត លោក ឡុង ដានី បានបង្ហាញយុវជនអំពីទីតាំងទួលពោធិ៍ជ្រៃ គឺជាទីវាលធំមួយ ស្ថិតនៅកៀកទៅនឹងបឹងទន្លេសាប និងជាប់តំបន់ព្រៃរនាម ក្នុងភូមិសាស្ត្រស្រុកកណ្ដៀង ខេត្តពោធិ៍សាត់។ ទីតាំងទួលពោធិ៍ជ្រៃនេះត្រូវបានគេស្គាល់ថា គឺជាកន្លែងដែលខ្មែរក្រហមសម្លាប់ទាហាន លន់ នល់ និងជនស៊ីវិលរាប់ពាន់នាក់ក្នុងអំឡុងនៃការជម្លៀសដោយបង្ខំជាទ្រង់ទ្រាយធំលើកដំបូងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។

នៅចុងបញ្ចប់វេទិកាថ្នាក់រៀន លោក ឡុង ដានី បានធ្វើបទបង្ហាញជាសង្ខេបអំពីដំណើរការអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សំណុំរឿង ០០១ និងសំណុំរឿង ០០២ (សំណុំរឿង០០២ វគ្គទី១ និងសំណុំ០០២ វគ្គទី២)។ និយមន័យអំពើប្រល័យពូជសាសន៍ ធាតុផ្សំនៃអំពើប្រល័យពូជសាសន៍ និងការទប់ស្កាត់ប្រល័យពូជសាសន៍។

នៅក្នុងឱកាសនោះ សិស្សដែលចូលរួមវេទិកាថ្នាក់រៀននៅថ្ងៃនេះ បានបង្ហាញចំណាប់អារម្មណ៍ដូចខាងក្រោម ៖

១) ខ្ញុំឈ្មោះ **លឿន រចនា** ភេទប្រុស គឺជាសិស្សមកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ដារ។ ខ្ញុំពិតជាសប្បាយរីករាយយ៉ាងខ្លាំង ដែលខ្ញុំបានចូលរួមដំណើរទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលឯកសារកោះថ្ម។ វេទិកាថ្នាក់រៀនស្តីអំពីរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ធ្វើឲ្យខ្ញុំបានដឹងថា របបនេះពិតជាឃោរឃៅ សាហាវយង់ឃ្នង ពិបាកក្នុងការរស់នៅ និងគ្មានសិទ្ធិសេរីភាព។ បន្ទាប់ពីខ្ញុំបានរៀនជាមួយលោកគ្រូខ្ទេសរួចមក ខ្ញុំពិតជាមិនចង់ឲ្យរបបនេះវិញត្រឡប់មកម្ដងទៀតទេ ព្រោះវាបានធ្វើឲ្យយើងបាត់បង់គ្រួសារ ធ្វើឲ្យប្រទេសជាតិគ្មានការរីកចម្រើន។

ក្នុងនាមខ្ញុំជាសិស្សមួយរូប ខ្ញុំនឹងខិតខំរៀនសូត្រឲ្យមានចំណេះដឹង ដើម្បីជួយសង្គមនិងខ្លួនឯង។ មិនតែប៉ុណ្ណោះ ត្រូវលុបបំបាត់ការរើសអើងផ្សេងៗ និងអំពើហិង្សា។ ជាចុងក្រោយខ្ញុំសូមសុំណូមពរដល់មជ្ឈមណ្ឌលឯកសារកោះថ្មឲ្យរៀបចំកម្មវិធីទស្សនកិច្ចសិក្សានេះជាបន្តទៀត ដើម្បីឲ្យក្មេងៗជំនាន់ក្រោយបានសិក្សារៀនសូត្រអំពីរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) បន្ថែមទៀត និងឲ្យដឹងពីប្រវត្តិសាស្ត្ររបស់ខ្លួនកាន់តែច្បាស់។

២) ខ្ញុំឈ្មោះ **អន ស្រីឡេង** ភេទស្រី មកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ដារ។ ខ្ញុំមានបងប្អូនចំនួនពីរនាក់ គឺស្រីទាំងពីរ។ ខ្ញុំមានម្ដាយឈ្មោះ ឌុច លី និងឪពុកឈ្មោះ ឌឹម អន។ សព្វថ្ងៃនេះ ឪពុកម្ដាយរបស់ខ្ញុំប្រកបរបរធ្វើស្រែចម្ការ។ ថ្ងៃនេះ ខ្ញុំពិតជាសប្បាយចិត្តណាស់ដែលបានមកទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលឯកសារកោះថ្ម និងតំបន់ប្រវត្តិសាស្ត្រឃោធា អ៊ិច-១៦។ នៅវេលាព្រឹកនេះពិតជាពិសេសណាស់ ដែលខ្ញុំបានមកសិក្សា និងបានយល់ដឹងអំពីរបបកម្ពុជាប្រជាធិបតេយ្យ។ ម្យ៉ាងទៀតបានធ្វើឲ្យខ្ញុំយល់ដឹងអំពីប្រវត្តិសាស្ត្រ និងបទពិសោធន៍ថ្មីៗជាច្រើនទៀត។ មួយវិញទៀតលោកគ្រូខ្ទេសបានពន្យល់ណែនាំខ្ញុំយ៉ាងក្បោះក្បាយទាក់ទងទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ព្រមទាំងមានការសួរសំណួរ និងការឆ្លើយសំណួរជាច្រើន។

៣) នាងខ្ញុំឈ្មោះ **ណាក់ ណារី** ភេទស្រី គឺជាសិស្សមកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ដារ។ ថ្ងៃនេះខ្ញុំពិតជាសប្បាយរីករាយណាស់ដែលបានមកទស្សនកិច្ចនៅមជ្ឈមណ្ឌលឯកសារកោះថ្ម។ កាលពីមុនចំណេះដឹងដែលខ្ញុំធ្លាប់មានអំពីរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ពិតជាតិចតួចណាស់។ ខ្មែរក្រហមជម្លៀសប្រជាជនចេញពីទីក្រុង

ភ្នំពេញដោយបង្ខំក្នុងរយៈពេលតែបីថ្ងៃតែប៉ុណ្ណោះ ហើយមិនឲ្យយកអីវ៉ាន់ទៅជាមួយទេ ព្រោះអង្គការទទួលខុសត្រូវក្នុងការហូបចុក និងយកលេសថាអង្គការចង់បោសសម្អាតទីក្រុង ព្រោះខ្លាចអាមេរិកទម្លាក់គ្រាប់បែកៗ ប៉ុន្តែនៅពេលខ្មែរក្រហមជម្លៀសប្រជាជនចេញទៅតាមជនបទរួច ខ្មែរក្រហមពុំមានសមត្ថភាពដឹកជញ្ជូនស្បៀងឲ្យប្រជាជនទេ។ ទាំងនេះជាកត្តាដែលធ្វើឲ្យរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដួលរលំ។ ចំណែកប្រជាជនមិនពេញចិត្តជាមួយរបបកម្ពុជាប្រជាធិបតេយ្យដែលកាប់សម្លាប់ប្រជាជនយ៉ាងឃោរឃៅទេ។ ខ្មែរក្រហមលែងទុកចិត្តគ្នាឯងដូចមានពាក្យពោលថា «ទុកក៏មិនចំណេញ ដកចេញក៏មិនខាត»។ ខ្មែរក្រហមបានបញ្ជូនកងកម្លាំងឲ្យទៅធ្វើសង្គ្រាមនៅតាមព្រំដែនជាមួយវៀតណាមៗ នៅពេលដែលនាងខ្ញុំបានមកទស្សនកិច្ចនៅក្នុងមជ្ឈមណ្ឌលឯកសារកោះថ្ម គឺខ្ញុំមានការចាប់អារម្មណ៍ទៅលើការតាំងពិព័រណ៍រូបថត និងការពន្យល់ណែនាំរបស់គ្រូខ្ទេសយ៉ាងក្បោះក្បាយអំពីសាច់រឿងដែលខ្ញុំមិនធ្លាប់សិក្សាពីមុនមកៗ ខ្ញុំទទួលបាននូវចំណេះដឹងថ្មីៗអំពីប្រវត្តិសាស្ត្រ ដែលខ្ញុំពុំធ្លាប់បានដឹងពីមុនមកៗ ខ្ញុំសំណូមពរមជ្ឈមណ្ឌលឯកសារកោះថ្មឲ្យបន្តរៀបចំកម្មវិធីសិក្សាអំពីរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដើម្បីអនុញ្ញាតឲ្យសាលា និងសិស្សានុសិស្សផ្សេងទៀតបានចូលរួមដូចខ្ញុំដែរ។



នៅព្រឹកថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៤ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម បានរៀបចំវេទិកាថ្នាក់រៀនស្តីអំពី «ប្រវត្តិសាស្ត្រខ្មែរក្រហម (១៩៧៥ - ១៩៧៩) និងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ” លើប្រធានបទការជម្លៀសប្រជាជនចេញពីទីក្រុង ការជម្លៀសដោយបង្ខំ និងការសម្លាប់រង្គាលនៅទួលពោធិ៍ជ្រៃ ដល់សិស្សចំនួន ៥៣នាក់ (ស្រី៣៨នាក់) មកពីវិទ្យាល័យប៊ុនរ៉ានី ហ៊ុនសែន ដារ ស្ថិតនៅក្នុងឃុំដារ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# សិស្សវិទ្យាល័យគេជោសែន សំរោង ចូលរួមវេទិកា ថ្នាក់រៀនស្ដីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥ - ១៩៧៩)» រៀបចំដោយមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង

**មេក វិន និង សួគ វិចិត្រ**



មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានរៀបចំវេទិកាថ្នាក់រៀនស្ដីអំពី«ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ដល់សិស្សានុសិស្សវិទ្យាល័យគេជោសែន សំរោង ចំនួន៤០នាក់ នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង រៀបចំវេទិកាថ្នាក់រៀនស្ដីអំពី«ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ដល់សិស្សានុសិស្សវិទ្យាល័យគេជោសែន សំរោង ចំនួន៤០នាក់ នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២៤។ វេទិកាថ្នាក់រៀននេះ មានគោលបំណងលើកកម្ពស់ការអប់រំ និងចងចាំអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងការទប់ស្កាត់កុំឲ្យមានអំពើប្រល័យពូជសាសន៍កើតមានឡើងនាពេលអនាគត។ វេទិកាថ្នាក់រៀននេះបានផ្ដោតសំខាន់ទៅលើប្រធានបទ«ការជម្លៀសដោយបង្ខំនៅក្នុងរបបខ្មែរក្រហម»។ ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនាថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ត្រូវបានខ្មែរក្រហមរៀបចំឡើងនៅក្នុងស្ថានភាពចលាចលគួរឲ្យភ័យខ្លាច និងដោយបង្ខំ។ ប្រជាជនបានចាកចេញពីផ្ទះសម្បែងរបស់ខ្លួនជាមួយភាពសោកស្ដាយ និងនឹកអាល័យ។ ខ្មែរក្រហមបានកុហកប្រជាជនថា ការជម្លៀសប្រជាជនចេញពីទីក្រុងដើម្បីសម្អាត រៀបចំទីក្រុងសារជាថ្មី និងខ្លាចអាមេរិកាំងទម្លាក់គ្រាប់បែក។ នៅចន្លោះពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ ប្រជាជនកម្ពុជាត្រូវរស់នៅក្នុងសហករណ៍ដើម្បីធ្វើការងាររួមនៅតាមទីជនបទដាច់ស្រយាល។

នៅក្នុងវេទិកាថ្នាក់រៀន សិស្សានុសិស្សក៏បានសួរសំណួរសំខាន់ៗមួយចំនួនដូចជា៖ ១) តើប្រវត្តិសាស្ត្រកម្ពុជាក្នុងចន្លោះពី១៩៧៥ ដល់ឆ្នាំ១៩៧៩ មានអ្វីកើតឡើងខ្លះ? ២) តើនរណានៅពីខាងក្រោយ និងគាំទ្រខ្មែរក្រហម? ៣) តើហេតុអ្វីបានជាអ្នកដឹកនាំខ្មែរក្រហម ហ៊ានលើកដៃសម្លាប់ប្រជាជនខ្មែរខ្លួនឯង? ៤) តើហេតុអ្វីបានជាមេដឹកនាំរបបខ្មែរក្រហមអះអាងថា ខ្លួនមិនបានធ្វើបាបប្រជាជន? ៥) តើមេដឹកនាំខ្មែរក្រហមបានធ្វើអ្វីខ្លះដែលផ្តល់ផលប្រយោជន៍ដល់ប្រទេសជាតិនៅចន្លោះពីឆ្នាំ១៩៧៥-១៩៧៩? ៦) តើប្រជាជនទាំងអស់ត្រូវតែចាកចេញពីផ្ទះសម្បែងប៉ុយ៉ាងណានៅក្នុងរបបខ្មែរក្រហម? ៧) តើហេតុអ្វីបានជាខ្មែរក្រហមសម្លាប់អ្នកមានចំណេះដឹង? ៨) តើការដឹកនាំក្នុងរបបកម្ពុជាប្រជាធិបតេយ្យផ្តល់គុណវិបត្តិអ្វីខ្លះដល់ប្រទេសជាតិ និងប្រជាជនខ្មែរ? ៩) តើហេតុអ្វីបានជាមេដឹកនាំខ្មែរក្រហមមិនបញ្ឈប់ការគ្រប់គ្រងរបបតាមបែបផ្តាច់ការ? ១០) តើកត្តាអ្វីខ្លះដែលធ្វើឲ្យមេដឹកនាំខ្មែរក្រហមក្បត់សម្តេចព្រះនរោត្តម សីហនុ ហើយកាន់កាប់អំណាចដោយខ្លួនឯង?





នៅផ្នែកចុងក្រោយនៃវេទិកាថ្នាក់រៀន គឺបានផ្តោតលើប្រធានបទការទប់ស្កាត់អំពើប្រល័យពូជសាសន៍នាពេលអនាគត ដោយក្នុងនាមជាយុវជនម្នាក់ៗអាចចូលរួមនៅក្នុងសកម្មភាពសង្គម ដើម្បីកុំឲ្យរបបនេះវិលត្រឡប់មកវិញម្តងទៀត។ សិស្សានុសិស្សមួយចំនួនបានយល់ឃើញថា ការរៀនសូត្រអំពីប្រវត្តិសាស្ត្រ និងការផ្សព្វផ្សាយប្រវត្តិសាស្ត្រ គឺជាការទប់ស្កាត់អំពើប្រល័យពូជសាសន៍ក្នុងពេលដែលអ្នកផ្សេងទៀតយល់ថា ការប្រឆាំងអំពើហិង្សាក្នុងគ្រួសារ សហគមន៍ និងសង្គម, ការដោះស្រាយជម្លោះដោយសន្តិវិធី, ការការពារសិទ្ធិជាបុគ្គល និងការលុបបំបាត់ការរើសអើង ក៏ជាវិធីសាស្ត្រមួយក្នុងការទប់ស្កាត់អំពើប្រល័យពូជសាសន៍ដែរ។





មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានរៀបចំវេទិកាថ្នាក់រៀនស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ដល់សិស្សានុសិស្សវិទ្យាល័យតេជោសែនសំរោង ចំនួន៤០នាក់ នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានរៀបចំវេទិកាថ្នាក់រៀនស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» សម្រាប់សិស្សានុសិស្សវិទ្យាល័យតេជោសែន សំរោង ចំនួន៤០នាក់ នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បន្ទាប់មកសិស្សានុសិស្សក៏បានបង្ហាញនូវចំណាប់អារម្មណ៍ផ្សេងៗពីគ្នាក្រោយពីបានចូលរួមក្នុងវេទិកាថ្នាក់រៀននៅថ្ងៃនេះ ៖

**វ៉ុន ថាវ៉ូ** ភេទប្រុស អាយុ១៧ឆ្នាំ គឺជាសិស្សវិទ្យាល័យតេជោសែន សំរោង បានរៀបរាប់ថា «ខ្ញុំពិតជាមានការត្រេកអរជាខ្លាំង នៅពេលបានមកចូលរួមវេទិកាថ្នាក់រៀននេះ។ បន្ទាប់ពីខ្ញុំបានរៀនសូត្រពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រខ្មែរក្រហម ធ្វើឲ្យខ្ញុំដឹងថា ខ្មែរក្រហមបានបោកបញ្ឆោតទាហានរបបសាធារណរដ្ឋខ្មែរជាច្រើននាក់យកទៅសម្លាប់ចោលរួមជាមួយនឹងប្រជាជន ជាពិសេសអ្នកមានចំណេះដឹង។ ខ្ញុំគិតថាវេទកានេះមានសារសំខាន់ព្រោះបានធ្វើឲ្យខ្ញុំដឹងអំពីទីតាំងប្រវត្តិសាស្ត្រសំខាន់ៗ ដូចជា ផ្ទះតាម៉ុក បានឃើញរថយន្តផ្សាយវិទ្យុរបស់ខ្មែរក្រហម ផ្ទាំងគំនូរប្រាសាទអង្គរវត្ត ប្រាសាទព្រះវិហារ ដែលស្ថិតនៅសារមន្ទីរផ្ទះតាម៉ុក» ។

**រុំ ចាន់រ៉ា** ភេទស្រី អាយុ១៦ឆ្នាំ បានលើកឡើងថា «បន្ទាប់ពីខ្ញុំបានចូលរួមវេទិកាថ្នាក់រៀននេះរួចមក ខ្ញុំបានដឹងអំពីការរៀបចំគម្រោងការរបស់ខ្មែរក្រហមដើម្បីសម្លាប់ទាហានរបបសាធារណរដ្ឋខ្មែរ។ ខ្ញុំស្គាល់ផ្ទះតាម៉ុក ហើយខ្ញុំឃើញផ្ទាំងរូបគំនូរ និងរូបថតជាច្រើនដែលអាចឲ្យយើងសិក្សា និងឈ្វេងយល់អំពីរបបខ្មែរក្រហម ដូចជា ការធ្វើសង្គ្រាម និងបានយល់ដឹងអំពីមេដឹកនាំនាសម័យនោះ ហើយក៏បានធ្វើឲ្យខ្ញុំយល់អត្ថន័យនៃពិព័រណ៍តាមផ្ទះនីមួយៗនៅសារមន្ទីរផ្ទះតាម៉ុក។ វេទិកានេះគឺពិតជាមានសារសំខាន់ណាស់ព្រោះអាចឲ្យខ្ញុំយល់ដឹងប្រវត្តិសាស្ត្រកាន់តែច្បាស់» ។

**ថុន សុភ័ក្ត្រា** ភេទប្រុស អាយុ១៧ឆ្នាំ រៀបរាប់ថា «បន្ទាប់ពីខ្ញុំបានចូលរួមក្នុងវេទិកាថ្នាក់រៀននេះរួចមក ខ្ញុំបានដឹងពីមូលហេតុ និងគោលបំណងដែលនាំឲ្យកើតមានរបបប្រល័យពូជសាសន៍រួមជាមួយនឹងការបំផ្លិចបំផ្លាញប្រទេសនាពេលនោះ។ ខ្ញុំដឹងថាខ្មែរក្រហមបានធ្វើបាបប្រជាជន និងបញ្ជូនប្រជាជនថ្មីឲ្យទៅធ្វើការជាមួយប្រជាជនចាស់។ តាមរយៈវេទិកានេះ បានធ្វើឲ្យខ្ញុំស្គាល់មេដឹកនាំគុកទួលស្លែង ស្គាល់ទីតាំងវាលពិឃាតដែលខ្មែរក្រហមបានសម្លាប់ និងធ្វើទារុណកម្មទៅលើប្រជាជន, ធ្វើឲ្យខ្ញុំស្គាល់ពីទីតាំងផ្ទះតាម៉ុក និងទីតាំងជួបប្រជុំសម្រាប់មេដឹកនាំខ្មែរក្រហមធំៗ។ ជាចុងក្រោយ ខ្ញុំចង់ឲ្យកូនខ្មែរគ្រប់រូបត្រូវឈ្វេងយល់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម ហើយចូលរួមការពារ និងទប់ស្កាត់កុំឲ្យអំពើប្រល័យពូជសាសន៍កើតឡើងម្តងទៀត»។

# មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះពិគ្រោះនិងពិនិត្យសុខភាពជូនអ្នករស់រានមានជីវិតពី

## របបខ្មែរក្រហម នៅខេត្តព្រៃវែង និងខេត្តស្វាយរៀង

ផេង ពង្សរ៉ាស៊ី



ចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារកម្ពុជា បានជួបពិគ្រោះ និងពិនិត្យសុខភាពជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមក ពីខេត្តព្រៃវែង និងខេត្តស្វាយរៀង ចំនួន២៣០នាក់។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





ចាប់ពីថ្ងៃទី១៣ដល់ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារកម្ពុជា បានជួបពិគ្រោះ និងពិនិត្យសុខភាពជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមកពីខេត្តព្រៃវែង និងខេត្តស្វាយរៀង ចំនួន ២៣០នាក់។ បញ្ជីឈ្មោះដែលបញ្ជូនមកពីមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ដែលជាសាខាមួយក្នុងចំណោមសាខាទាំង៧របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្ហាញថាឈ្មោះទាំង២៣០នាក់ នៅក្នុងបញ្ជីគឺជាអ្នករស់រានមានជីវិត មានអាយុចាប់ពី៥៥ឆ្នាំ ឡើងទៅដែលក្រុមអ្នកស្ម័គ្រចិត្តកម្ពុជានៃមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ធ្លាប់បានចុះជួប និងសម្ភាសន៍ក្នុងអំឡុងខែធ្នូ ឆ្នាំ២០២៣ និងខែមករា ឆ្នាំ២០២៤នេះ។ សូមបញ្ជាក់ថា កាលពីខែវិច្ឆិកា ឆ្នាំ២០២៣ កន្លងទៅមជ្ឈមណ្ឌលឯកសារកម្ពុជា ក៏ធ្លាប់បានជួបពិគ្រោះ និងពិនិត្យសុខភាពជូនអ្នករស់រានមានជីវិតចំនួន១២៨នាក់ មកពីស្រុកកំចាយមារ ខេត្តព្រៃវែង មួងរួចហើយ។ គម្រោងដែលបានអនុវត្តក្នុងរយៈពេលបីថ្ងៃនេះគឺដើម្បីបម្រើដល់សេចក្តីត្រូវការរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ក្នុងការថែទាំសុខភាពដែលមាន

សភាពទ្រុឌទ្រោមដោយសារជំងឺ និងផលប៉ះពាល់ដោយសាររបបខ្មែរក្រហម។

គោលបំណងដ៏មានសារសំខាន់មួយទៀតរបស់គម្រោង គឺដើម្បីបំពេញបន្ថែមនូវការបាត់បង់ភាពយុត្តិធម៌របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមម្នាក់ៗដែលបង្កដោយរបបខ្មែរក្រហម។ ហេតុនេះមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង បានបញ្ជូនអ្នកស្ម័គ្រចិត្តរបស់ខ្លួនឲ្យចុះទៅជួប និងសួរសុខទុក្ខពីបញ្ហាសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដល់គេហដ្ឋានផ្ទាល់ ដើម្បីឈ្វេងយល់ថា តើបញ្ហាសុខភាពរបស់ពួកគាត់មានសភាពយ៉ាងដូចម្តេច? ការជួបជជែកគ្នារវាងអ្នករស់រានមានជីវិត និងក្មេងៗជំនាន់ក្រោយដែលជាចៅៗរបស់ខ្លួន គឺជាយន្តការនៃការបណ្តុះការចងចាំ ការសន្ទនាអន្តរជំនាន់ ការចែករំលែក និងការផ្សះផ្សាផ្លូវចិត្ត។ អត្ថបទនេះនឹងបង្ហាញអំពីសកម្មភាពប្រចាំថ្ងៃនីមួយៗនៃការពិគ្រោះ និងពិនិត្យសុខភាពជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលអញ្ជើញមកកាន់ទីតាំងគោលដៅដែលបានកំណត់ដោយក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ដោយមានការសហការពីអាជ្ញាធរ ឃុំ ស្រុក និងអាជ្ញាធរខេត្តព្រៃវែង។ សកម្មភាពពិគ្រោះ និងពិនិត្យសុខភាពជូនអ្នករស់រានមានជីវិតទាំង២៣០នាក់ ប្រព្រឹត្តទៅរយៈពេល៣ថ្ងៃ នៅទីតាំងចំនួន២គឺ ក្នុងឃុំជីផុច ស្រុកមេសាង និងក្នុងឃុំក្រញូង ស្រុកកំចាយមារ ខេត្តព្រៃវែង។ កិច្ចការងារទាំងពីរទីតាំងនេះបានដំណើរការទៅតាមការគ្រោងទុកនិងរបៀបវារៈដូចៗគ្នា គឺនៅរសៀលថ្ងៃទី១៣ និងព្រឹកថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៤ ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងបានជួបពិគ្រោះ និងពិនិត្យសុខភាពជូនអ្នករស់រានមានជីវិតចំនួន១១៩នាក់ មកពីឃុំព្រៃឃ្នេស ឃុំជីផុច និងឃុំប្រេះ ក្នុងស្រុកមេសាង។ នៅរសៀលថ្ងៃទី១៤ និងពេញមួយថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៤ ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង បានបន្តជួបជាមួយអ្នករស់រានមានជីវិតចំនួន១១១នាក់ទៀត មកពីឃុំក្រញូង ឃុំក្របៅ ឃុំជាច ឃុំស្មោងខាងជើង និងឃុំស្មោងខាងត្បូង ស្រុកកំចាយមារ ខេត្តព្រៃវែង ព្រមទាំងអ្នករស់រានមាន



ចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារកម្ពុជា បានជួបពិគ្រោះ និងពិនិត្យសុខភាពជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមកពីខេត្តព្រៃវែង និងខេត្តស្វាយរៀង ចំនួន២៣០នាក់។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារកម្ពុជា បានជួបពិគ្រោះ និងពិនិត្យសុខភាពជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមកពីខេត្តព្រៃវែង និងខេត្តស្វាយរៀង ចំនួន២៣០នាក់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ជីវិតមកពីឃុំក្រសាំង និងឃុំអណ្តូងត្របែក ក្នុងស្រុករមាសហែក ខេត្តស្វាយរៀង។ នៅថ្ងៃដំបូងនៃការចាប់ផ្តើមអនុវត្តសកម្មភាពការងារ តំណាងអាជ្ញាធរឃុំទាំងពីរគឺឃុំជីផុច ស្រុកមេសាង និងឃុំក្រញូង ស្រុកកំចាយមារ មានមតិស្វាគមន៍ចំពោះអ្នកចូលរួមទាំងអស់ និងបានប្រកាសបើកកម្មវិធីពិនិត្យ និងពិគ្រោះពីបញ្ហាសុខភាពរបស់អ្នករស់រានមានជីវិតទាំងអស់។

លោក ព្រុំ សារឿន គឺជាជំទប់ទី១ឃុំជីផុច បានរៀបរាប់ពីប្រវត្តិរបស់គាត់ឆ្លងកាត់របបខ្មែរក្រហម ជីវិតរស់នៅក្រោមរបបខ្មែរក្រហម ការអភិវឌ្ឍន៍ភូមិឃុំនាពេលបច្ចុប្បន្ន និងផ្តាំផ្ញើដល់អ្នកចូលរួមឲ្យចែករំលែកបទពិសោធន៍របស់ខ្លួន ដល់ក្មេងៗជំនាន់ដើម្បីបន្តការចងចាំពីប្រវត្តិសាស្ត្រ។ ចំណែកលោកមេឃុំក្រញូង បានសម្តែងការត្រេកអរចំពោះវត្តមានរបស់បុគ្គលិកមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ក្នុងការផ្តល់ចំណេះដឹងថ្មីៗ ទាក់ទងនឹងការថែទាំសុខភាពដល់អ្នកភូមិរបស់គាត់ ក៏ដូចជាអ្នកឯទៀតដែលបានចូលរួមនៅក្នុងកម្មវិធីនេះ។ លោក ព្រំ សារឿន ក៏បានលើកឡើងអំពីជីវិតរបស់គាត់ឆ្លងកាត់របបខ្មែរក្រហម ដែលជួបប្រទះទុក្ខលំបាក និងជំងឺរហូតមកដល់ពេលបច្ចុប្បន្ននេះ។ បន្ទាប់មកអ្នកស្ម័គ្រចិត្តកម្ពុជា បុគ្គលិកមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង និងក្រុមគ្រូពេទ្យ បានចាប់ផ្តើមដំណើរការពិគ្រោះ និងពិនិត្យសុខភាពជូនអ្នករស់រានមានជីវិតតាមតារាងបែងចែកភារកិច្ច និងតួនាទីរៀងៗខ្លួនដូចខាងក្រោម៖

អ្នកស្ម័គ្រចិត្តកម្ពុជាម្នាក់ គឺជាអ្នកហៅឈ្មោះអ្នករស់រានមានជីវិតដែលមានឈ្មោះនៅក្នុងបញ្ជីម្នាក់ម្តងៗឲ្យមកទទួលការពិគ្រោះ និងពិនិត្យសុខភាព និងផ្ទៀងផ្ទាត់ឈ្មោះក្នុងបញ្ជីជាមួយនឹងអត្តសញ្ញាណបណ្ណដែលបាននាំយកមកតាមខ្លួន។ ការផ្ទៀងផ្ទាត់នេះគឺដើម្បីចៀសវាងការច្រឡំឈ្មោះ។ ក្នុងចំណោមឈ្មោះទាំង២៣០នាក់ មានប្រហែល១០នាក់ប៉ុណ្ណោះដែលមានខុសនាមខ្លួន និងនាមត្រកូល។ មូលហេតុ

ដែលបណ្តាលឲ្យខុសឈ្មោះដូច្នេះគឺដោយសារតែអ្នករស់រានមានជីវិតបានប្រាប់ឈ្មោះហៅក្រៅរបស់ខ្លួនទៅកាន់អ្នកសម្ភាសន៍ដែលជាអ្នកស្ម័គ្រចិត្តកម្ពុជានាពេលកន្លងមក។ ឈ្មោះដែលខុសទាំងប៉ុន្មានត្រូវបានដោះស្រាយភ្លាមៗ បន្ទាប់ពីមានការធានាអះអាងពីមេភូមិ និងអ្នកចូលរួមដែលមកពីភូមិតែមួយជាមួយនឹងអ្នកខុសឈ្មោះនោះ។ អ្នកស្ម័គ្រចិត្តកម្ពុជាម្នាក់ទៀត គឺជាអ្នកសម្របសម្រួលដល់អ្នករស់រានមានជីវិតណាម្នាក់ដែលមានបញ្ហាសុខភាព ពិបាកនឹងធ្វើដំណើរពីកៅអីមកកាន់តុពិគ្រោះ និងពិនិត្យសុខភាព។ ចំណែកអ្នកស្ម័គ្រចិត្តពីរនាក់ទៀត គឺជាជំនួយការគ្រូពេទ្យក្នុងការពិនិត្យសុខភាព និងជាអ្នកកត់ត្រាចូលក្នុងបញ្ជីអំពីប្រភេទជំងឺដែលអ្នករស់រានមានជីវិតកំពុងតែជួបប្រទះ។

អ្នកជំនាញសុខភាពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាម្នាក់ និងគ្រូពេទ្យម្នាក់ ទទួលភារកិច្ចវាស់សម្ពាធឈាម និងរកជាតិស្ករក្នុងឈាមរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម តាមរយៈឧបករណ៍វិទ្យាសាស្ត្រ។ ចំណែកវេជ្ជបណ្ឌិតពីររូបគឺ វេជ្ជបណ្ឌិត ឡាវ ហាវ៉ាន់ និង ឡុង ម៉ារ៉ាដែន គឺជាអ្នកពិគ្រោះពីបញ្ហាសុខភាពរបស់អ្នករស់រានមានជីវិតដែលកំពុងជួបប្រទះបញ្ហាប្រឈម។ វេជ្ជបណ្ឌិតទាំងពីររូប បានផ្តល់ដំបូន្មានល្អៗទាក់ទងនឹងការថែទាំសុខភាព ជាជាងការផ្តល់វេជ្ជបញ្ជាសម្រាប់អ្នករស់រានមានជីវិតយកទៅទិញថ្នាំលេបព្យាបាលជំងឺ។ លទ្ធផលនៃការពិនិត្យសុខភាពបឋមដែលស្រង់ចេញពីការពិនិត្យសម្ពាធឈាម និងការធ្វើតេស្តរកជាតិស្ករក្នុងឈាម គឺជាការកត់ត្រាចេញពីវេជ្ជបញ្ជាដែលវេជ្ជបណ្ឌិតបានសរសេរប្រគល់ឲ្យអ្នករស់រានមានជីវិតតែប៉ុណ្ណោះ។ អ្នកស្ម័គ្រចិត្តកម្ពុជាម្នាក់ ដែលស្ថិតនៅជាជំនួយការរបស់វេជ្ជបណ្ឌិត បានកត់ត្រាជាប្រចាំនូវកំណត់ត្រាប្រភេទជំងឺដែលអ្នករស់រានមានជីវិតម្នាក់ៗកំពុងជួបប្រទះ។ សូមពិនិត្យមើលពីកំណត់ត្រានេះខាងក្រោម៖ ១) ជំងឺលើសសម្ពាធឈាម មានចំនួន៧៤នាក់, ២) ជំងឺក្រពះពោះវៀនមានចំនួន៥៧នាក់, ៣) ជំងឺសន្លាក់ មានចំនួន៥៥នាក់, ៤) ជំងឺផ្លូវចិត្ត មានចំនួន១៧នាក់, ៥) ជំងឺទឹកនោមផ្អែម មានចំនួន៩នាក់, ៦) ជំងឺហឺតរ៉ាំរ៉ៃ មានចំនួន៤នាក់, ៧) ជំងឺរបេងមានចំនួន២នាក់, ៨) ជំងឺផ្សេងៗក្រៅពីប្រភេទជំងឺរ៉ាំរ៉ៃ (ប្រភេទជំងឺធម្មតា ដូចជាជំងឺផ្តាសាយ និងគ្រុនក្តៅ) មានចំនួនច្រើនជាង២០នាក់។





ចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារកម្ពុជា បានជួបពិគ្រោះ និងពិនិត្យសុខភាពជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមកពីខេត្តព្រៃវែង និងខេត្តស្វាយរៀង ចំនួន២៣០នាក់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ការិយាល័យព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន សិស្ស និស្សិត អ្នកសិក្សាស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍អំពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្សទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ ១១ ផ្លូវលេខ ២៥៦ សង្កាត់បឹងកេងកង ១... 

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ ១១ ផ្លូវលេខ ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង រស់ សំពៅ អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៨៨២ ៥០៩ ឬ

អ៊ីម៉ែល ៖ truthsampeou.r@dccam.org

សូមអរគុណ!



























# ជីវិតភូនប្រុសពុកក្នុងគុកខ្មែរក្រហម (ត)

ហង្ស ឆាំឆាន

## ២. ការរស់នៅក្នុងស្រុកកំណើតឆ្នាំ១៩៧៥ និងមុនឆ្នាំ១៩៧០

### ២.១. ទំនាក់ទំនងរវាងខ្ញុំ និងសាច់ញាតិ

ព្រឹកឡើងជាថ្ងៃសីល១៥កើត ដុះខ្ញុំនៅជាប់របងវត្ត ខ្ញុំបានរៀបចំខ្លួនចូលទៅក្នុងវត្តទាំងព្រឹកព្រលឹមដោយលោកឪពុកក៏ទៅជាមួយដែរ។ ព្រះសង្ឃក្នុងវត្តភ្ញាក់ផ្អើលវត្តមានរបស់ខ្ញុំ។ ព្រះសង្ឃមួយវត្តនេះមានចំនួន១៣អង្គ ព្រះសង្ឃខ្លះបានមកថ្វាយបង្គំខ្ញុំតាមវិន័យសង្ឃ អង្គខ្លះគេចចេញ ធ្វើហាក់ដូចជាមិនដឹង។ រីឯឧបាសក ឧបាសិកាដែលមកវត្តថ្ងៃសីលវិញក៏មិនខុសគ្នាពីព្រះសង្ឃដែលធ្លាប់គោរពស្រឡាញ់ខ្ញុំពីមុន ខ្លះនិយាយមករកខ្ញុំហាក់ដូចជាធ្លាប់ជាសត្រូវនឹងគ្នាពីកាលណា។ ខ្ញុំនៅចាំដំបូន្មានឪពុកខ្ញុំជានិច្ច មិននិយាយអ្វីទាំងអស់ ចាំស្តាប់គេបង្គាប់ឲ្យធ្វើអ្វី ធ្វើតាមគេប្រាប់ទៅ។ ថ្ងៃនោះដដែលមិត្តគឺគណៈកម្មាវត្ត បានហៅខ្ញុំទៅ សួរតែ២នាក់ថា៖ នៅភ្នំពេញបានធ្វើអ្វីខ្លះរយៈពេល៥ឆ្នាំនេះ? ខ្ញុំថា មិនបានធ្វើអ្វីទេ នៅបួសដូចតែពេលនេះ និងនិមន្តបិណ្ឌបាតធម្មតា។ ចុះបានរៀនសូត្រដល់ណាដែរ? ខ្ញុំឆ្លើយថា មិនបានរៀនទេ ព្រោះគ្មានអ្នកណាជួយ លុយឲ្យរៀនបានលុយឯណាទិញសៀវភៅ។ រយៈពេល៣ថ្ងៃក្រោយមក លោកសង្ឃមួយអង្គឈ្មោះ អ៊ូច គង្គា ជាគណៈចលនាសង្ឃស្រុកឲ្យទៅជួបសួរនាំដូចគ្នានឹងមិត្តគឺដែរ។ ២ថ្ងៃក្រោយទៀតអង្គការបើកមីទីញជ័យជម្នះ១៧មេសា ក្នុងវត្តនេះ គេឲ្យខ្ញុំចូលរួមជាមួយសង្ឃផ្សេងទៀតដែរ ដោយអង្គុយនៅលើគុសិស្សវែងពីរស្ថិតនៅខាងមុខគេ។ អ្វីដែលខ្ញុំបានឃើញ គឺប្រាប់តៗគ្នា ហើយចង្អុលមកខ្ញុំថា លោកនោះទើបហ្នឹងមកពីភ្នំពេញ តែមិនដឹងគេនិយាយគ្នាថាម៉េចទៀតទេ ខ្ញុំនៅអង្គុយដូចជាមិនដឹងអ្វីសោះ។ ខ្ញុំបានរស់នៅជាមួយសង្ឃផ្សេងៗទៀតក្នុងវត្តបឹងដោល សង្កាត់បឹងដោល ស្រុកព្រះស្តេច (កោះជ័យ) រហូតដល់ចុងខែកក្កដា ១៩៧៥។ ចាប់ពីថ្ងៃខ្ញុំទៅដល់ព្រះសង្ឃទាំងអស់បាននាំគ្នាធ្វើការដូចប្រជាជននៅតាមផ្ទះដែរ គឺជាន់រហាត់ទឹកដីកដីដាំដំណាំក្នុងវត្តបានយ៉ាងច្រើន តែមិនបានទៅធ្វើការតាមភូមិទេ និងនិមន្តទៅបិណ្ឌបាតជាធម្មតា។ សង្ឃក្នុងវត្តបានចាកសិក្ខាបទជាបន្តបន្ទាប់រហូតដល់ចុងខែកក្កដា នៅសល់តែ២អង្គគឺខ្ញុំនិងលោកតា គង់។ ខ្ញុំឃើញលោកចាកសិក្ខាបទអស់ក៏សុំលោកតាឲ្យផ្សឹកខ្ញុំនៅក្រោយគេ និងកន្លះខែក្រោយមកលោកតាគង់ ក៏ថ្វាយបង្គំព្រះដោះជីពរផ្សឹកខ្លួនឯង។ លោកតាគេមិនឲ្យទៅផ្ទះទេ គេនៅឲ្យចាំវត្តនិងចាត់ទុកគាត់ជាអ្នកជួយបម្រើការងារពេទ្យ ព្រោះក្រោយពីអស់ព្រះសង្ឃ គេយកកន្លែងនេះធ្វើជាមន្ទីរពេទ្យសង្កាត់បឹងដោល។ ក្នុងពេលជាមួយគ្នានេះ គេបានវាយព្រះបំបាក់កនោះចោលក្នុងព្រៃអស់។

### ២.២. ទំនាក់ទំនងរវាងក្រុមគ្រួសារខ្ញុំនិងប្រជាជនក្នុងភូមិ

ពេលក្លាយខ្លួនទៅជាគ្រហស្ថ



ហង្ស ឆាំឆាន ពេលបួសជាព្រះសង្ឃ។

ហើយថ្មីៗ ខ្ញុំតែងតែជម្រាបសួរដោយលើកដៃសំពះញាតិសន្តានដែលខ្ញុំធ្លាប់ស្គាល់មានចាស់ៗជាច្រើនបានសំពះតបមកខ្ញុំវិញតាមទម្លាប់ប្រពៃណីខ្មែរព្រះពុទ្ធសាសនា តែអ្វីដែលប្លែកនោះគឺកម្មាភិបាលខ្មែរក្រហម គេមិនសំពះតបមកខ្ញុំវិញទេ ថែមទាំងប្រដៅស្តីឲ្យខ្ញុំថាសម័យនេះហើយនៅសំពះអ្វីទៀត គេឈប់ប្រើហើយ ព្រោះវាជារបបសក្តិភូមិ។ ខ្ញុំពុំសូវហ៊ានដើរទៅណាក្រៅផ្ទះទេព្រោះមិនទាន់ដឹងរបៀបរស់នៅរបស់របបខ្មែរក្រហមម្យ៉ាងទៀតមើលសាច់ញាតិខ្លះក៏គេមិនសូវសប្បាយចិត្តនឹងខ្ញុំរស់នៅដែរ ព្រោះកូនគេបានស្លាប់ជាច្រើននាក់ដោយសារទាហាន លន់ នល់ និង ធីវគី បុ វៀតណាមខាងត្បូង។ ថ្ងៃមួយខ្ញុំបានជួបបង ប៉ែន សីហា គឺជាប្រធានសេនាធិការតំបន់២៤ គាត់មកលេងផ្ទះប្រពន្ធគាត់ក្បែរផ្ទះខ្ញុំ គាត់

កំឈានមកមើលខ្ញុំរួចក៏សួរថា សុខសប្បាយទេ ឆាន? ល្អ ហើយគេឲ្យធ្វើអ្វីធ្វើហ្នឹងគេទៅកុំប្រកែកណា! ខ្ញុំឆ្លើយតប បាទបង។ គាត់ក៏សើចហើយលាខ្ញុំចេញទៅមិននិយាយអ្វីច្រើនទេ។ បង ប៉ែន សីលា គឺជាឈ្មោះបដិវត្តន៍ ឈ្មោះពិតរបស់គាត់គឺ ប៉ែន សឿន គាត់គឺជាអតីតសមណនិស្សិតសាលាបាលីជាន់ខ្ពស់ ស្នាក់នៅកុដិជាមួយខ្ញុំ ឆ្នាំ១៩៦៦ គាត់បានទទួលបរិញ្ញាបត្រអក្សរសាស្ត្រខ្មែរពីសាកលវិទ្យាល័យអក្សរសាស្ត្រភ្នំពេញ។ ឆ្នាំ១៩៦៧ យើងខ្ញុំមានគ្នាចំនួន៤នាក់ គឺបង ប៉ែន សីហ ហៅ សឿន, បង ស៊ីវ ញ៉ិល, បង ម៉ុក សៅ និង ខ្ញុំ គឺជាសង្ឃនៅកុដិជាមួយគ្នា។ ពួកយើងស្រឡាញ់គ្នាណាស់ មានចិត្តដូចគ្នា និងមិនសូវចូលចិត្តលោកសង្ឃណាដែលបួសហើយប្រឡូកជាមួយនឹងនយោបាយខ្មែរក្រហម ឬខ្មែរសេរីឡើយ។ ខែឧសភា ឆ្នាំ១៩៧០ បង ប៉ែន សឿន បានមកជួបខ្ញុំតែ២នាក់ស្ងាត់ៗ និយាយណែនាំជំរុញឲ្យខ្ញុំទៅរៀនបន្ត ដោយប្រាប់ខ្ញុំថា និមន្តទៅមុនទៅ ចាំករុណារំសាយចិត្តសិនទៅតាមក្រោយ ព្រោះកូនរបស់គាត់ទើបតែស្លាប់។ ខ្ញុំក៏ចេញទៅភ្នំពេញ ដោយរង់ចាំមើលផ្លូវគាត់រហូតដល់ឆ្នាំ១៩៧៥ទើបមកជួបនៅកន្លែងដដែលវិញ។ ថ្ងៃមួយលោកឪពុកបាននាំខ្ញុំទៅលេងកន្លែងភូមិកំណើតរបស់គាត់ ដែលនៅចម្ងាយជាង២គីឡូម៉ែត្រពីភូមិកំណើតខ្ញុំ ដើម្បីឲ្យខ្ញុំបានជួបឪពុក ម្ដាយធំ និងមីងមារបង្កើតខ្ញុំ។ ពេលទៅដល់ អ្វីៗខុសពីការគិតរបស់ឪពុកខ្ញុំនិងខ្ញុំ គឺពួកគាត់ទាំង៤នាក់ មានតែម្ដាយធំម្នាក់ទេដែលចិត្តរបស់គាត់នៅតែស្រឡាញ់ខ្ញុំ។ ក្រៅពីនេះ គាត់មិនបានសប្បាយចិត្តនឹងខ្ញុំដែលបានទៅរស់នៅទីនោះទេ ជាពិសេសបងៗនិងប្អូនជីដូនមួយខ្ញុំ។ ចាប់តាំងពីពេលនោះមកខ្ញុំលែងទៅណាទៀតហើយ ដោយគ្រួសារខ្ញុំតែ៤គ្រួសារគឺ ជីតា ឪពុកធំពីរគ្រួសារទៀត គេចាត់ទុកជាគ្រួសារអនុធន គេមិនឲ្យធ្វើស្រែជាមួយសហករណ៍គេទេ គេឲ្យធ្វើជាក្រុមប្រវាស់ដៃ តែ៤គ្រួសារនេះម្ចាស់ការលើខ្លួនឯងទាំងស្រុង។ នេះគឺជាឱកាសរៀនសូត្ររបស់ខ្ញុំហើយ គឺសុំអ្នកម្ដាយទៅរៀនភ្ជួរស្រែជាមួយប្អូនៗ។ ខ្ញុំមានឈ្មោះជាកូនអ្នកស្រែពិតមែន តែការងារកសិករខ្ញុំមិនចេះធ្វើអ្វីទាំងអស់ ព្រោះខ្ញុំចេញពីគ្រួសារ ទៅនៅវត្តដើម្បីរៀនសូត្រនៅឆ្ងាយពីផ្ទះ២០គីឡូម៉ែត្រ តាំងតែខ្ញុំមានអាយុ៧ឆ្នាំ ដល់អាយុ២៨ឆ្នាំ ទើបមកស្រុកវិញ។ ប្អូនស្រីខ្ញុំប្រាប់អ្នកម៉ែថា ឲ្យលោកបងទៅភ្ជួរ តើគាត់ចេះបរគោឬ កាន់យាមនង្គ័លយ៉ាងម៉េចទៅម៉ែ? ម៉ែឆ្លើយថា បើមិនរៀនធ្វើយ៉ាងម៉េចចេះ ពួកឯងជួយប្រាប់ទៅចេះហើយ គង់តែថ្ងៃក្រោយចូលសហករណ៍ គេមិនឲ្យយើងនៅទំនេរទេកូនៗ ក្រៅពីរៀនភ្ជួររាស់ ខ្ញុំឆ្លៀតទៅរកត្រីមកផ្គត់ផ្គង់គ្រួសារបានសម្បូរហូបជាងពួកសហករណ៍ ដោយសារក្រុមប្រវាស់ដៃមានពេលទំនេរច្រើន។ ពេលរកត្រីបានហូបខ្លួនឯង និងចែកញាតិហូបមិនប្រាកដថាបានសេចក្ដីសុខទេ។ ថ្ងៃមួយប្រធានសហករណ៍ហៅខ្ញុំទៅព្រមាន ថាបើរកត្រីបានច្រើន ម៉េចមិនយកមកដាក់រួម ឲ្យគេចែក ថ្ងៃនេះអត់ឱនឲ្យម្ដងប្រយ័ត្នណា។ ដូចម្ដាយមានប្រសាសន៍មែន ខែកញ្ញា ឆ្នាំ១៩៧៥ អង្គការប្រកាសឲ្យលុបចោលក្រុមប្រវាស់ដៃ ត្រូវចូលសហករណ៍ទាំងអស់។

## ២.៣. គេឱ្យខ្ញុំរៀនក្បួនយុទ្ធសាស្ត្រ

ក្រោយពេលចូលសហករណ៍បានមួយថ្ងៃ ខ្ញុំត្រូវអង្គការប្រគល់ភារកិច្ចចំនួន២ឲ្យភ្លាម ទី១ជីកប្រឡាយនៅក្បែរផ្ទះ គឺមួយព្រឹកចាក់ដីនឹងប៉ែលបោះឡើងលើភ្លឺប្រឡាយឲ្យបាន២ម៉ែត្របណ្ដោយជម្រៅ២ម៉ែត្រ មាត់លើ២កន្លះ និងបាតក្រោម១ម៉ែត្រ។ ទី២នៅពេលល្ងាចត្រូវត្រៀមខ្លួនចូលហាត់ក្បួនយុទ្ធសាស្ត្រដើម្បីត្រៀមខ្លួនការពារជាតិក្រែងមានខ្មាំងឈ្លានពាន។ ការងារទី១ ខ្ញុំខិតខំប្រឹងធ្វើទាល់តែបាន គឺផើបម៉ោង៦ព្រឹកដល់ម៉ោង១១កន្លះ បានចប់សព្វគ្រប់តាមផែនការដូចគេ។ ឯការងារទី២ ខ្ញុំលំបាកនៅត្រង់គ្មានខោអាវស្លៀកហាត់ហ្នឹងគេ ព្រោះខ្ញុំទើបនឹងសឹក។ ២នាក់ប្អូនប្រុសខ្ញុំ មានខោអាវ២ ទើបនឹងលួចដូរមាន់ពីអ្នកថ្មីបានគឺខោប៉ាត់សាច់កាណាជា និងអាវសង់ត្រេពណ៌សបើស្លៀកទៅ ហាត់មិនយូរប៉ុន្មានវាកាត់ជាខោរីតដាក់កៅស៊ូចង្កេះទូលាយស្រួល ហាត់ណាស់។

## ២.៤. ខ្ញុំធ្លាក់ខ្លួនឈឺ

ដោយប្រឹងធ្វើការទាំងពីរនេះផ្គាប់ចិត្តអង្គការរយៈពេលប្រមាណជា២ខែ ខ្ញុំក៏ធ្លាក់ខ្លួនឈឺជាទម្ងន់ គឺហើមកដៃកជើង ក្បាលជង្គង់និងចង្កេះ។ លោកឪពុក និងអ្នកម្ដាយព្រួយបារម្ភនឹងខ្ញុំណាស់ ព្រោះគាត់ឃើញអ្នកថ្មីទើបតែនឹងស្លាប់៣នាក់កើតជំងឺហើមនេះ។ លោកឪពុកក៏ទៅជួបប្រធានពេទ្យឈ្មោះ មិត្ត សុខ ហ៊ី ដែលជាមិត្តរបស់ខ្ញុំរៀនជាមួយគ្នាកាលពីអនុវិទ្យាល័យកាលពីមុនឆ្នាំ១៩៧០។ បានដូចចិត្ត មិត្ត សុខ ហ៊ី មកខ្លួនឯងភ្លាម ហើយប្រាប់ខ្ញុំថាមិនអីទេកុំភ័យ សម្ងាញ់ព្យាបាល១ខែជាហើយ សុខសប្បាយថ្មមខ្លួន។ មួយស្របក់ក្រោយមកពេទ្យនារី រ៉េន បានយកថ្នាំស្ត្រឹបតូមីស៊ីន មកចាក់ឲ្យមួយដប ល្ងាចលោកតាមុតគ្រូខ្មែរមកស្តោះឲ្យទៀត។ ការព្យាបាលដោយយកចិត្តទុកដាក់ជាប់បានប្រហែលជា១ខែ ទើបខ្ញុំបានឡើងដើររួច ជារៀងរាល់ថ្ងៃ មិត្ត សុខ ហ៊ី តែងតែមកសួរសុខទុក្ខខ្ញុំរំឭកពីអនុស្សាវរីយ៍នៅរៀនកាលពីតូចៗជាមួយគ្នា។

## ២.៥. ក្រុមចល័តដកស្ទូង

ក្រោយពីសុខភាពបានល្អហើយ អង្គការតម្រូវឲ្យខ្ញុំចេញចល័តដកស្ទូងនៅសង្កាត់ល្វា ដែលមានចម្ងាយជាង

២០គីឡូម៉ែត្រជាមួយក្រុមយុវជនមូលដ្ឋានចំនួន ២០នាក់ ក្រោមការគ្រប់គ្រងរបស់សមមិត្តវ៉ង។ ការចល័តនេះម្ហូបអាហារត្រូវសាមីខ្លួនយកទៅផ្គត់ផ្គង់ខ្លួនឯង យើងទាំងអស់គ្នាម្នាក់ៗមានអង្ករ មាន់ទា ត្រីយកទៅរៀងៗខ្លួនដាក់ចូលគ្នា។ ខ្ញុំព្រួយណាស់តែមិនមាត់ ព្រោះមិនដែលដកសំណាប ឬស្ទូងស្រូវបានម្ដងណាទេ ពួកយើងទៅដល់ការដ្ឋាន មិត្ត វ៉ង ប្រធានក្រុមបានទៅចូលរួមប្រជុំទទួលផែនការ គឺចំនួនក្រុមចល័តមាន យុវជន នារី និងយុទ្ធជនចំនួនប្រមាណជាង២០០នាក់ចុះស្ទូងចាប់ពីព្រឹកស្អែកទៅដោយមានសំណាបគេមានត្រៀមរួចហើយសម្រាប់ព្រឹកស្អែក។ ឥឡូវខ្ញុំសុំចាត់តាំងមិត្ត ឆាន ធ្វើចុងភៅ តើសមូលហភាពព្រមទេ? គេទះដៃឯកភាពគ្នា ព្រោះចំណោមនោះខ្ញុំចាស់ជាងគេ។

ម៉ោង៤ទៀបភ្លឺ ខ្ញុំក្រោកឡើងដាំបាយ និងធ្វើម្ហូបឆ្អិនហើយ បបួលហូបប្រញាប់ប្រញាល់ឲ្យទាន់គេចុះស្ទូង។ ម៉ោង៧ ក្មេងៗចេញទៅអស់ ខ្ញុំមានការងារចុងភៅ ធ្វើជាបន្តុបន្ទាប់ជូនមិត្តរួមការងារ គេនឹងឡើងមកវិញហូបបាយនៅម៉ោង១០។ ការងារនេះមិនលំបាកទេសម្រាប់ខ្ញុំ គឺទៅរែកទឹកនៅជិតរកខុសក៏មិនឆ្ងាយ ស្លដាំ។ កាលនៅរៀនខ្ញុំធ្វើតែខ្លួនឯងជិត២០ឆ្នាំយ៉ាងស្ទាត់ តែអ្វីដែលទើសទាល់បំផុតពេលនេះគឺអាចរកមាន់ធ្វើម្ហូប។ រយៈពេល៣ថ្ងៃ ការដ្ឋានចល័តដកស្ទូងត្រូវបានបញ្ចប់ដោយជោគជ័យតាមផែនការរបស់អង្គការ ពួកយើងបានហូបបាយ មានម្ហូបឆ្ងាញ់ៗជាមួយគ្នារាល់ថ្ងៃដោយស្និទ្ធស្នាលបំផុត។ ខ្ញុំមានមោទនភាពណាស់ ព្រោះលើកទី១ហើយចាប់ពីថ្ងៃដែលចូលមករស់នៅក្នុងសង្គមថ្មីលើទឹកដីកំណើតនិងបានក្មេងៗប្រជាជនមូលដ្ឋានមិនរើសអើងខ្ញុំ។

## ២.៦. ការជួសជុលផ្លូវជាតិលេខ១

មកដល់ផ្ទះបានមួយអាទិត្យ ផែនការចល័តជួសជុលផ្លូវជាតិលេខ១១បានមកដល់ទៀត។ មុនជ័យជម្នះ១៧ មេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានប្រើប្រជាជនឲ្យទៅកាយផ្លូវជាតិលេខ១១ច្រើនកន្លែងឲ្យជ្រៅជាងភ្លឺស្រែទៅទៀត ដើម្បីទប់ស្កាត់កុំឲ្យទ័ព លន់ លន់ បើកឡានបាន។ ក្រុមយើងខ្ញុំមានគ្នាចំនួន៣០នាក់ ភាគច្រើនជាបងប្រុសត្រូវធ្វើរយៈពេល១អាទិត្យទើបត្រឡប់ទៅផ្ទះវិញ នៅពេលមានកម្លាំងថ្មីមកដូរ។

ការដ្ឋានជួសជុលថ្នល់បានប្រព្រឹត្តទៅតាមការដឹកនាំរបស់អង្គការស្រុកកោះជ័យ គឺបែងចែកមុខព្រួញតាមសង្កាត់និងសង្កាត់នីមួយៗត្រូវចែកជាក្រុមតាមភូមិ ភូមិបឹងដោល ទទួលធ្វើមុខព្រួញភូមិឡឹក គេផ្ដល់ការងារឲ្យតាមចំនួនមនុស្សគឺម្នាក់ត្រូវលើកមួយម៉ែត្រទទឹងផ្លូវរយៈពេល៧ថ្ងៃ និងមេក្រុមត្រូវត្រួតពិនិត្យតាមមើលដាក់ស្ដែងតាមកន្លែងជ្រៅបុរាក់ត្រូវមានសំណូមពរទៅអង្គការ។ ស្បៀងសម្រាប់ផ្គត់ផ្គង់កម្លាំងមិនខុសគ្នាពក្រុមចល័តមុនៗទេគឺទទួលខុសត្រូវតាមក្រុមរៀងៗខ្លួន។

## ២.៧. ការថែទាំទំនប់ពោធិ៍បូរី

ចប់ការដ្ឋានជួសជុលផ្លូវខ្ញុំបានទៅដល់ផ្ទះប្រហែល១០ថ្ងៃ ការដ្ឋានទប់ទំបន់ពោធិបូរីមកដល់ទៀត ម្ដងនេះមិនទៅជាក្រុមទេ គឺមានរទេះមួយនិងគោមួយនឹមរួមទាំងស្បៀងសម្រាប់រយៈពេល១អាទិត្យទើបចប់។ ការងារទប់ទំនប់មានការលំបាកច្រើនទី១ ត្រូវឃ្វាលគោខ្លួនឯង ទី២ ដាំបាយហូបខ្លួនឯង ទី៣ ត្រូវរកកន្លែងស្នាក់នៅខ្លួនឯង។ ម៉ោង៧ ព្រឹកត្រូវបង្ហាញខ្លួននៅលើខ្នងទំនប់ខាងកើតដោយឧបករណ៍ដូចជា ចប ប៉ែល ដាប់ទៅជាមួយសម្រាប់លើកដីដាក់រទេះរួចដឹកទៅលើទំនប់ចម្ងាយប្រហែលជា៥០០ម៉ែត្រ កាយទម្លាក់នៅកន្លែងណាដែលខ្នងទំនប់នៅទាបដើម្បីការពារកុំឲ្យទឹកជំនន់កៀនលើនាំឲ្យបាក់ទំនប់។ ម៉ោង១០ សម្រាកហូបបាយរកកន្លែងសម្រាក។ ពិតមែនតែហត់ សំខាន់ខ្ញុំមិនព្រួយរឿងជីវិតនិងបានជួបជុំគ្រួសារ។ ចប់ការដ្ឋានទំបន់រដូវដកស្ទូង និងច្រូតកាត់បានមកដល់ជាបណ្ដើរៗ ខ្ញុំត្រូវរៀនដកសំណាបបោកសំណាប រៀនស្ទូងតាមប្អូនៗគេបង្ហាញឲ្យធ្វើ អ្វីៗបានប្រព្រឹត្តទៅដោយរលូននិងសប្បាយចិត្តព្រោះបានស្និទ្ធស្នាលជាមួយសាច់ញាតិជាច្រើន។ តែចៃដន្យពេលរៀនច្រូតស្រូវខ្ញុំមិនប្រយ័ត្នច្រូតដៃខ្លួនឯងមុតយ៉ាងខ្លាំង ហូរឈាមយ៉ាងច្រើន។ អ្នកខ្លះគេអាណិតខ្ញុំ យកថ្នាំជក់និងកំបោរបិទរបួសឲ្យ អ្នកខ្លះចំអកលេងផង មែនផង ថាហ្នឹងហើយ សមមុខហើយ ជាកូនអ្នកស្រែគិតតែពីបួសរៀនយូរពេកភ្លេចកំណើតខ្លួន ទើបវាអញ្ចឹងទៅ។

## ២.៨. រដូវច្រូតកាត់អ្នកភូមិបឹងដោល

រដូវច្រូតស្រូវភូមិបឹងដោលឆ្នាំនេះកើតស្រូវច្រើន អង្គការភូមិបានស្នើសុំកម្លាំងច្រូតស្រូវពីសង្កាត់កំពង់សីងនិងភូមិផ្សេងៗទៀតក្នុងសង្កាត់បឹងដោលមកជួយសម្រុកច្រូតស្រូវកុំឲ្យស្រូវទុំជ្រុះលបាក់កពិបាកច្រូត។ កម្លាំងប្រមាណជា៥០០នាក់បានមកស្នាក់នៅតាមផ្ទះប្រជាជន រួមនឹងកម្លាំងក្នុងភូមិប្រយុទ្ធច្រូតស្រូវកន្លះខែទើបឈប់ នៅប៉ុន្មានទៀតអ្នកភូមិច្រូតបង្ហើយខ្លួនឯង។ រូបខ្ញុំនិងយុវជនក្នុងភូមិទាំងអស់ទទួលបន្ទុកដឹកកណ្ដាប់តាមស្រែដែលច្រូតហើយមកដាក់ទីលានបញ្ជាន់។ សប្បាយចិត្តណាស់យើងធ្វើការផងជជែកគ្នាលេងផង ហាក់ដូចជាមិនចេះហត់ទេម្នាក់ៗ អ្នកខ្លះបានជួបមិត្តចាស់ អ្នកខ្លះបានស្គាល់មិត្តថ្មីរាប់រកគ្នាយ៉ាងសប្បាយដូចបាត់បង់អស់ការរើសអើងអ្នកចាស់ថ្មីទៀតហើយ។

(តនៅលេខក្រោយ)

*រូបក្របមុខ និង ក្របក្រោយ ៖*
*ប្លង់វិទ្យាស្ថានស្លឹករឹតនៃមជ្ឈមណ្ឌលឯកសារកម្ពុជា គូរដោយស្ថាបត្យករ ហ្សាហា ហាឌីដ។*
*(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*



**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
*ផ្ទះលេខ១១ ផ្លូវ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ ៖ (៨៥៥) ៧៨ ៦៩៨ ៣៣៣*
DC-Cam/PIR: #11 ◆ Street 256 ◆ Sangkat Chatomuk ◆ Khan Daun Penh ◆ Phnom Penh ◆ Cambodia 1110
Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org
A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 290, February 2024 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.